ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ ជីវភាពស្ត្រីកម្ពុជាដែលមើលរំលង

◆ ការអភិរក្សសំណង់ស្ថាបត្យកម្មបុរាណបែបព្រះពុទ្ធសាសនា

◆ វេទិកាប្រវត្តិសាស្ត្រគ្រួសារនៅខេត្តក្បូងឃ្មុំ សង្ខេបសាច់រឿង

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៥៥ ខែមីនា ឆ្នាំ២០២១

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៥៥ ខែមីនា ឆ្នាំ២០២១

## មាតិកា

**សំបុត្រ**

- វីរភាពស្ត្រីកម្ពុជាដែលមើលរំលង.............១
- ការអភិរក្សសំណង់ស្ថាបត្យកម្មបុរាណបែបព្រះពុទ្ធសាសនា ............................. ៤

**ផ្នែកឯកសារ**

- សូ សាផនះ លេខាស្រុកកំពង់រោទិ៍ .......... ៦

**ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ**

- យោង គីម ចែករំលែកបទពិសោធន៍ក្នុងរបបខ្មែរក្រហម ........................ ១៤
- ខ្ញុំស្ម័គ្រចិត្តតស៊ូជាមួយខ្មែរក្រហម .......... ១៨
- ហ៊ីង ហោះ តួសម្ដែងក្នុងកងសិល្បៈខ្មែរ......២០
- អណ្ដូងសាកសពរបស់ប្រជាជនថ្មីនៅក្នុងភូមិ.. ២២
- ខាន់ លួត ៖ អតីតកម្មករកំពង់ផែ..........២៥
- រស់ ភិរុណះ អតីតសន្តិសុខទួលជ្រែស...... ២៩

**ផ្នែកច្បាប់**

- សាលក្រមសំណុំរឿង០០២/០២ ........... ៣៥

**ផ្នែកវេទិកាសាធារណៈ**

- វេទិកាប្រវត្តិសាស្ត្រគ្រួសារនៅខេត្តត្បូងឃ្មុំ.. ៤៤
- របាយការណ៍ និងបទសម្ភាសន៍សង្ខេប ក្នុងវេទិកាប្រវត្តិសាស្ត្រគ្រួសារនៅស្រុកគីរីវង់ខេត្តតាកែវ ថ្ងៃទី៨ ដល់ ១១ ខែកុម្ភៈ ឆ្នាំ២០២១....... ៥៤

**ផ្នែកស្រាវជ្រាវរកគ្រួសារ**

«ដេះដង់ធូលី» រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

- លី យូស៊ីប និង លី ស្មែល ៖ អ្នកនេសាទ...៥៩



កងចល័តនារីកំពុងស្ទូងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩)

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥៣.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ៖** រី លក្ខិណា, សួត វិចិត្រ, ហ៊ាន ពិសី, លី កុកឆាយ, មីន សាណាស់, កែវ សុភី, ផាត ចាន់សុនិតា, វេនី ខកហៀល និង ប៉ាង ពីវ័ន្ត, **អ្នកនិពន្ធ និងស្រាវជ្រាវ៖** ដារ៉ារដ្ឋ មេត្តា **អ្នកបកប្រែ៖** អ៊ុន សុដាវី **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន **ជំនួយការនិពន្ធនាយក៖** អ៊ុន សុដាវី **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ផេង វ៉េង
Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ជីវភាពស្ត្រីកម្ពុជាដែលមើលរំលង

អ៊ុន សុជាទី



ស្ត្រីនៅព្រះបរមរាជវាំង ឆ្នាំ១៦៨៨។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទិវានារីអន្តរជាតិ តែងតែប្រារព្ធធ្វើឡើងនៅថ្ងៃទី៨ ខែមីនា ជារៀងរាល់ឆ្នាំ។ ទិវានារីអន្តរជាតិ កើតចេញពីការក្រោកឈរឡើងរបស់ស្ត្រីប្រឆាំងនឹងការរំលោភបំពានទៅលើលក្ខខណ្ឌការងាររបស់ខ្លួននៅក្នុងសហរដ្ឋអាមេរិកនាចុងសតវត្សរ៍ទី១៩។

មនុស្សភាគច្រើនយល់ឃើញថា ស្ត្រី គឺជាភេទទន់ខ្សោយ ហើយគ្មានកម្លាំងស្មើនឹងបុរស។ នៅក្នុងប្រទេសកម្ពុជា តាមរយៈប្រពៃណីទំនៀមទំលាប់ពីបុរាណមក ស្ត្រី ត្រូវបានអប់រំឲ្យធ្វើជាមេផ្ទះ គោរពប្រណិប័តន៍ប្តី និងឪពុកម្តាយ ព្រមទាំងមើលថែរក្សាកូនៗនៅក្នុងផ្ទះ។ ជាទូទៅ ស្ត្រី ត្រូវបានចាត់ទុកថាជាមនុស្សដែលមានអត្តចរិតទន់ភ្លន់ សុភាពរាបសា ព្រមទាំងមានចិត្តអំណត់ខ្ពស់។ ប៉ុន្តែប្រសិនបើយើងក្រឡេកមើលទៅតាមស្ថានភាពជាក់ស្តែង ស្ត្រី គឺមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយក៏មានភាពរឹងមាំជាយូរលង់ណាស់មកហើយនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា។

នៅក្នុងរបបខ្មែរក្រហម ស្ត្រីនិងក្មេងស្រី គឺជាកម្លាំងមួយដ៏សំខាន់ដែលបានជួយជ្រោមជ្រែងដល់ក្រុមកុម្មុនីស្ត

ខ្មែរក្រហមឡើងកាន់កាប់អំណាច និងគ្រប់គ្រងប្រទេសកម្ពុជា ដែលហៅថារបបកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហមនៅរវាងឆ្នាំ១៩៧៥ ដល់ ១៩៧៩។ នៅក្នុងរបបខ្មែរក្រហម ស្ត្រី និងក្មេងស្រី បានចូលរួមចំណែកនៅក្នុងការជួយបំពេញកិច្ចការងារនានាដល់ក្រុមខ្មែរក្រហមរួមមាន ធ្វើជាគ្រូពេទ្យ ក្រុមឃោសនាកេណ្ឌកម្លាំងទ័ពយុវជន អ្នកផ្គត់ផ្គង់អាហារ អ្នកគ្រប់គ្រងនៅតាមតំបន់ និងអ្នកដឹកជញ្ជូនអាវុធដល់កងទ័ពខ្មែរក្រហមក្នុងពេលធ្វើសង្គ្រាម។

អំឡុងពេលត្រឹមតែ ៣ឆ្នាំ ៨ខែ និង២០ថ្ងៃ របបខ្មែរក្រហម បានបំផ្លិចបំផ្លាញប្រទេសកម្ពុជាស្ទើរតែគ្រប់វិស័យទាំងអស់។ ខ្មែរក្រហមបានសម្លាប់ប្រជាជនប្រមាណ ២លាននាក់ និងបន្សល់ទុកប្រជាជនប្រមាណ ៥ លាននាក់ ដែលភាគច្រើនគឺជាស្ត្រី។ ចាប់តាំងពីពេលនោះមក ទាំងស្ត្រី និងក្មេងស្រី បានទទួលរងនូវការប៉ះទង្គិចយ៉ាងខ្លាំងទាំងជីវភាពរស់នៅ និងបញ្ហាផ្លូវចិត្តដែលកើតមានឡើងដោយសារតែការបែកបាក់ និងព្រាត់ប្រាស់មនុស្សជាទីស្រឡាញ់របស់ខ្លួន។ រឿងរ៉ាវទាំងអស់នេះបានផ្តល់ផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ស្ត្រីទៅហើយ ប៉ុន្តែស្របពេលនោះ ស្ត្រី មានកាតព្វកិច្ចប្រឈមមុខតស៊ូជម្នះទៅលើការកសាងប្រទេសកម្ពុជាឡើងវិញបន្ថែមទៀត។ ស្ត្រី បានតស៊ូប្រឹងប្រែងគ្រប់បែបយ៉ាង ដើម្បីស្រោចស្រង់ប្រទេសកម្ពុជាថែមទាំងបាននាំយកនូវស្នាមញញឹម និងសុភមង្គលត្រឡប់មកជូនដល់ប្រជាជនកម្ពុជាវិញ។

រហូតមកដល់សព្វថ្ងៃនេះ យើងសង្កេតឃើញថា ស្ត្រីនៅតែជាកម្លាំងចលករមួយយ៉ាងសំខាន់ដែលបានចូលរួមគ្រប់វិស័យទាំងអស់នៅក្នុងប្រទេសកម្ពុជា។ ស្ត្រី គឺមិនមែនគ្រាន់តែជាជំហរ និងជាទីពឹងរបស់ក្រុមគ្រួសារតែប៉ុណ្ណោះនោះទេ ប៉ុន្តែស្ត្រី ក៏បានចូលរួមចំណែកនៅក្នុងការអភិវឌ្ឍន៍ប្រទេសជាតិយ៉ាងសកម្មដូចបុរសដែរ។

ទោះបីជាយ៉ាងនេះក្តី ការយល់ឃើញចំពោះស្ត្រី គឺមិនបានធ្វើឡើងទៅតាមស្ថានភាពដែលបានកើតឡើងនោះទេ។ ភាគច្រើន ស្ត្រី ត្រូវបានបកស្រាយនៅក្នុងន័យទន់ខ្សោយ ថែមទាំងត្រូវការការជួយជ្រោមជ្រែងនិងយកចិត្តទុកដាក់ពីអ្នកនៅជុំវិញខ្លួនទៅវិញ។

មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងរៀបចំកម្មវិធីរាំរបាំបុរាណដែលមានចំណងជើងថា «ស្នេហាមួយដែលមិនមែនជារឿងព្រេងនិទាន» នៅក្នុងបណ្ណាល័យសម្តេចម៉ែ ដើម្បីអបអរទិវានារីអន្តរជាតិនាថ្ងៃ ៨ ខែមីនា ឆ្នាំ២០២១។ «ស្នេហាមួយដែលមិនមែនជារឿងព្រេងនិទាន» គឺជារឿងរ៉ាវស្នេហារបស់ព្រះករុណា ព្រះមហាវីរក្សត្រ សម្តេចឪ និងសម្តេចព្រះមហាក្សត្រី សម្តេចម៉ែ ដែលមានរយៈពេលជាច្រើនឆ្នាំមកហើយ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានអញ្ជើញឯកអគ្គរាជទូតស្ត្រី និងភរិយារបស់ឯកអគ្គរាជទូតប្រចាំនៅក្នុងប្រទេសកម្ពុជា ព្រមទាំងសិល្បៈករ និងបុគ្គលិកស្ត្រីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចូលរួមទស្សនាការរាំរបាំបុរាណដែលមានចំណងជើងថា «ស្នេហាមួយដែលមិនមែនជារឿងព្រេងនិទាន» និងអបអរទិវានារីអន្តរជាតិនៅក្នុងបណ្ណាល័យសម្តេចម៉ែ។

ជ្រិន ជ័យស័ក្ត ភេទប្រុស អាយុ ២៣ គឺជាវិចិត្រករដែលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈឯកទេសស្ថាបត្យកម្ម។ ជ័យស័ក្ត មានស្រុកកំណើតនៅឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ ជ័យស័ក្ត គឺជាវិចិត្រករម្នាក់ដែលនឹងចូលរួមគូររូបការរាំរបាំបុរាណ ដែលមានចំណងជើងថា «ស្នេហាមួយដែលមិនមែនជារឿងព្រេងនិទាន» នៅក្នុងបណ្ណាល័យសម្តេចម៉ែនាថ្ងៃប្រារព្ធពិធីអបអរទិវានារីអន្តរជាតិ។ ជ័យស័ក្ត បានចែករំលែកអំពីការយល់ឃើញរបស់ខ្លួនចំពោះទិវានារីអន្តរជាតិថា៖

ខ្ញុំធ្លាប់ឮអំពីទិវានារីអន្តរជាតិ ជាយូរមកហើយនៅក្នុងប្រទេសកម្ពុជា។ ខ្ញុំយល់ឃើញថា សព្វថ្ងៃនេះ ស្ត្រីនិងបុរស ទទួលបានសិទ្ធសេរីភាពស្មើៗគ្នា។ ស្ត្រី ជាច្រើនបានចូលរួមចំណែកនៅក្នុងកិច្ចការងារសង្គមនិងទទួលបានឱកាសដូចបុរស។ នៅក្នុងសង្គមខ្មែរ បុរសភាគច្រើនមានឱកាសច្រើនជាងស្ត្រី ព្រោះដោយសារតែវប្បធម៌និងប្រពៃណីរបស់ខ្មែរយើងពីមុនមក។ កាលពីមុន ស្ត្រីភាគច្រើនមិនបានទទួលការអប់រំបានជ្រៅជ្រះនោះទេ ព្រោះស្ត្រីមានកាតព្វកិច្ចក្នុងការមើលថែរក្សាផ្ទះ និងកូនៗ។ ទាំងអស់នេះ គឺជាឧបសគ្គមួយសម្រាប់ស្ត្រី ហើយខ្ញុំគិតថានៅ

ពេលនោះ ស្ត្រី ក៏មិនចង់រស់នៅក្នុងស្ថានភាពដូច្នោះដែរ។ រហូតមកដល់បច្ចុប្បន្ននេះ វិស័យអប់រំនៅក្នុងប្រទេសកម្ពុជា មានភាពរីកចម្រើនជាងមុន ដែលនេះគឺជាឱកាសមួយធ្វើឲ្យស្ត្រីអាចយល់ដឹងបានច្រើនអំពីសិទ្ធនិងកាតព្វកិច្ចរបស់ខ្លួននៅក្នុងសង្គម។ សម្រាប់ខ្ញុំ ស្ត្រី ចាញ់បុរសត្រឹមតែកម្លាំងកាយប៉ុណ្ណោះ ព្រោះនេះគឺធម្មជាតិជាអ្នកបង្កើតមក ប៉ុន្តែចំពោះការតស៊ូនិងការសិក្សារៀនសូត្រវិញ ស្ត្រីគឺមិនអន់ជាងបុរសនោះទេ។ ខ្ញុំធ្លាប់ធ្វើការងារដែលមានស្ត្រីជាប្រធានក្រុមរបស់ខ្ញុំ ហើយខ្ញុំក៏ធ្លាប់ត្រូវបានស្ត្រីស្តីបន្ទោសឲ្យនៅពេលដែលខ្ញុំនិយាយលេងសើចជ្រុល ហួសហេតុចំពោះគាត់។ សកម្មភាពទាំងអស់នេះ បានបង្ហាញថា ស្ត្រី ក៏មានសមត្ថភាពនៅក្នុងការដឹកនាំ និងមិនខ្លបខ្លាចក្នុងការតវ៉ានោះទេ។

ខ្ញុំសង្ឃឹមថា ការប្រារព្ធពិធីអបអរទិវានារីអន្តរជាតិ ដែលមានការជួបជុំគ្នារវាងស្ត្រីដែលជាអ្នកដឹកនាំនៅក្នុងបរិវេណបណ្ណាល័យសម្តេចម៉ែនេះ នឹងអាចជួយបង្ហាញអំពីសក្តានុពលរបស់ស្ត្រីទាំងអស់។ ខ្ញុំក៏រំពឹងទុកដែរថា រូបគំនូររបស់ខ្ញុំអំពីការរាំរបាំបុរាណ ដែលមានចំណងជើងថា «ស្នេហាមួយដែលមិនមែនជារឿងព្រេងនិទាន» នៅក្នុងកម្មវិធីនេះ នឹងចូលរួមចំណែកអបអរដល់ស្ត្រីទាំងអស់នៅក្នុងប្រទេសកម្ពុជា ព្រមទាំង ស្ត្រីផ្សេងៗទៀតលើសកលលោក។

**ពេជ្រ ពិនិត្យ** ភេទប្រុស អាយុ២៦ គឺជាអ្នកលេងភ្លេងបុរាណម្នាក់។ ពិនិត្យ មានស្រុកកំណើតនៅក្នុងខេត្តកណ្តាល។ ពិនិត្យ បានចែករំលែកការយល់ឃើញរបស់គាត់ចំពោះទិវានារីអន្តជាតិថា៖

ខ្ញុំធ្លាប់ឮអំពីទិវានារីអន្តរជាតិនេះ តាំងតែពីខ្ញុំរៀននៅអនុវិទ្យាល័យមកម្ល៉េះ។ ខ្ញុំគិតថា ការប្រារព្ធទិវានារីអន្តរជាតិនេះឡើង គឺដើម្បីលុបបំបាត់ការរើសអើង និងការរំលោភបំពានផ្សេងៗទៅលើស្ត្រី។ ខ្ញុំគាំទ្រឲ្យមានការប្រារព្ធពិធីទិវានារីអន្តរជាតិនេះឡើងជារៀងរាល់ឆ្នាំ ព្រោះស្ត្រីភាគច្រើនបានទទួលរងការរំលោភបំពានជាងបុរស។ ខ្ញុំគិតថា ស្ត្រីមិនទន់ខ្សោយនោះទេ ព្រោះស្ត្រីបានបង្ហាញអំពីភាពខ្លាំងរបស់ខ្លួនតាមរយៈការដោះស្រាយបញ្ហា និងការហ៊ានប្រឈមមុខចំពោះអំពើដែលរំលោភបំពានដល់ខ្លួន។ ខ្ញុំសង្ឃឹមថា ការចូលរួមលេងភ្លេងរបស់ខ្ញុំសម្រាប់ការរាំរបាំបុរាណ ដែលមានចំណងជើងថា «ស្នេហាមួយដែលមិនមែនជារឿងព្រេងនិទាន» ក្នុងកម្មវិធីអបអរទិវានារីអន្តរជាតិនៅក្នុងបណ្ណាល័យសម្តេចម៉ែនាថ្ងៃខាងមុខនេះ នឹងអាចជួយរំឭកអំពីគុណតម្លៃរបស់ស្ត្រី ដែលមនុស្សមួយចំនួនតែងតែមើលរំលង។



*រូបរាប់ពីឆ្វេង៖ សេរី វណ្ណកុសន និង សុខ ណាលីស កំពុងហាត់សមសម្តែងសិល្បៈនៅបណ្ណាល័យសម្តេចម៉ែ។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

# ការអភិរក្សសំណង់ស្ថាបត្យកម្មបុរាណបែបព្រះពុទ្ធសាសនា

*សោម ប៊ុនថន*



*សំណង់ស្ថាបត្យកម្មបុរាណបែបព្រះពុទ្ធសាសនាចំនួន២ ដែលបានកសាងឡើងនៅពុទ្ធសករាជ ២៤៧៤ ត្រូវនឹងគ្រឹស្តសករាជ ១៩៣១ នៅវត្តលង្កាដែលត្រូវបានថែរក្សា និងជួសជុលឡើងវិញ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅប្រទេសកម្ពុជា មានសំណង់ស្ថាបត្យកម្មជាច្រើនសម័យកាលបានបន្សល់ទុក រួមមាន សំណង់បេតិកភណ្ឌមុនសម័យអង្គរ សម័យអង្គរ សម័យក្រោយអង្គរ ស្ថាបត្យកម្មសំណង់សម័យអាណានិគមដែលមានអាយុកាលមួយសតវត្សរ៍ គឺចាប់ពីឆ្នាំ១៨៦៣ ដល់ឆ្នាំ១៩៥៣ និងស្ថាបត្យកម្មបែបទំនើប។

ដោយសារការអភិវឌ្ឍន៍នូវបច្ចេកវិទ្យា និងសំណង់ស្ថាបត្យកម្ម អគារដែលមានរចនាបទនាំចូលពីបរទេស និងមានកម្ពស់ច្រើនជាន់បានរីកលូតលាស់យ៉ាងឆាប់រហ័សនៅប្រទេសកម្ពុជា ស្របពេលដែលសំណង់បេតិកភណ្ឌដូចជា សំណង់អគាររដ្ឋបាលសាធារណៈ សំណង់អគារផ្នែកសាសនា សំណង់អគារលំនៅឋាន មានការថយចុះ និងមានការកែប្រែខុសពីសភាពដើម។ សំណង់បេតិកភណ្ឌបុរាណទាំងនោះ មានការផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយជីវភាពវប្បធម៌ សាសនា សង្គម សេដ្ឋកិច្ច និងប្រវត្តិសាស្ត្ររបស់ប្រជាជនខ្មែរ។

រហូតមកទល់សព្វថ្ងៃ មានសំណង់បេតិកភណ្ឌបុរាណដែលមានអាយុកាលរាប់រយឆ្នាំ នៅសេសសល់តិចតួចប៉ុណ្ណោះនៅក្នុងទីក្រុងភ្នំពេញ និងតាមបណ្តាខេត្តនានាក្នុងប្រទេសកម្ពុជា ដែលជាសំណង់សម័យក្រោយអង្គរតាមបែបព្រះពុទ្ធសាសនា រួមមាន សំណង់ព្រះវិហារបុរាណ និងវត្តអារាម។

នៅឆ្នាំ២០១៨ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតគម្រោងសំណង់ស្ថាបត្យកម្មវត្តខ្មែរ។ សំណង់វត្តខ្មែរ បានកើតឡើងតាំងពីឆ្នាំ ១៩២៧ ដែលមានរូបថតដាក់តាំងនៅសារមន្ទីរជាតិ និងនៅក្នុងរជ្ជកាល ហ្លួងព្រះបាទស៊ីសុវត្ថិមុនីវង្ស នៅក្នុងកម្មវិធីតាំងតុ ដែលជាកម្មវិធីប្រកួតប្រជែងស្ថាបត្យកម្មវត្តអារាមសង់ពីបេតុងរបស់ព្រះបរមរាជវាំង។ គម្រោងនេះ គឺជាការសិក្សារួមរវាង តម្លៃវប្បធម៌ សិល្បៈ ស្ថាបត្យកម្ម ប្រវត្តិសាស្ត្រ និងការលើកស្ទួយព្រះពុទ្ធសាសនា។ នៅសតវត្សរ៍ទី ២១ ស្ថាបត្យកម្មបែបទំនើប បានបង្កឲ្យប៉ះពាល់ដល់សំណង់បែបបុរាណដែរ ពិសេសសំណង់វត្តអារាម។ ថ្វីដ្បិតតែរដ្ឋាភិបាលមានច្បាប់ការពារសំណង់បេតិកភណ្ឌបែបបុរាណ ប៉ុន្តែជារឿយៗ សំណង់បេតិកភណ្ឌបែបបុរាណនៅតាមវត្តអារាមបានបាត់បង់ម្តងមួយៗ និងជាបន្តបន្ទាប់។ ព្រះវិហារមួយចំនួនត្រូវបានរុះរើ ដោយគ្មានច្បាប់អនុញ្ញាត និងគ្មានការសុំអនុញ្ញាតពីស្ថាប័នដែលពាក់ព័ន្ធ។ ដូច្នេះ គម្រោងថែរក្សាស្ថាបត្យកម្មសំណង់វត្តអារាមគឺជាការចាំបាច់បំផុត ក្នុងការស្រង់ឯកសារចំនួនវត្តសម្រាប់កូនខ្មែរជំនាន់ក្រោយឲ្យដឹងពីអត្តសញ្ញាណរបស់ខ្មែរ ហើយគម្រោងនេះនឹងបោះពុម្ពជាសៀវភៅ។

ថ្មីៗនេះ សំណង់បេតិកភណ្ឌបុរាណបែបព្រះពុទ្ធសាសនា ដែលជាហោត្រៃបុរាណ ដែលជាស្នាព្រះហស្តសម្តេចព្រះរាម ស៊ីសុវត្ថិ ថាវេតវង្សនារីវង្ស និង ព្រះអង្គម្ចាស់ នរោត្តម សិង្ហារា បានកសាងនៅពុទ្ធស័ករាជ ២៤៧២ មកទល់ពេលនេះមានអាយុកាល ៩២ ឆ្នាំ ស្ថិតនៅក្នុងវត្តស្វាយពពែ ក្នុងក្រុងភ្នំពេញ ត្រូវបានវាយកម្ទេចចោល ខណៈពេលវត្តលង្កាកំពុងខិតខំប្រឹងប្រែងថែរក្សា និងជួសជុលសំណង់ស្ថាបត្យកម្មបុរាណបែបព្រះពុទ្ធសាសនាចំនួន ២ ដែលបានកសាងឡើងនៅពុទ្ធសករាជ ២៤៧៤ ត្រូវនឹងគ្រិស្តសករាជ ១៩៣១ និងមានអាយុកាល៩០ឆ្នាំមកហើយ។

សម្តេចព្រះមហាអរិយវង្សបណ្ឌិត សៅរ៍ ចន្ទថុល្ល ព្រះអនុប្រធានទី៣ ថេរសភា ព្រះពុទ្ធសាសនានៅព្រះរាជាណាចក្រកម្ពុជា និងជាព្រះចៅអធិការវត្តលង្កា ព្រះកុសុមារាម មានសង្ឃដីកាថា ព្រះអង្គមានព្រះទ័យរីករាយ ដែលមានពុទ្ធបរិស័ទជួយជួសជុលសំណង់បុរាណបែបព្រះពុទ្ធសាសនានៅក្នុងវត្តលង្កា ហើយពុទ្ធបរិស័ទនឹងទទួលផលបុណ្យកុសល។ ព្រះអង្គសម្តែងព្រះទ័យសោកស្តាយចំពោះសំណង់ស្ថាបត្យកម្មបុរាណដែលជាភស្តុតាងតាំងពីយូរយារណាស់មកហើយ ត្រូវបានបាត់បង់។

ស៊ិន ពៅរ៉ា គឺជានិស្សិតផ្នែកស្ថាបត្យកម្ម និងជាប្រធានគម្រោងសំណង់ស្ថាបត្យកម្មវត្តខ្មែរ មានប្រសាសន៍ថា ស្ថាបត្យកម្មសំណង់បុរាណបែបពុទ្ធសាសនាត្រូវតែការពារ ដោយសារវត្តអារាម បានរងគ្រោះយ៉ាងធ្ងន់ធ្ងរនៅក្នុងអំឡុងពេលសង្គ្រាមនៅក្នុងរបបសាធារណរដ្ឋខ្មែរ និងរបបខ្មែរក្រហម។ រហូតមកដល់បច្ចុប្បន្ន សំណង់ស្ថាបត្យកម្មបុរាណបែបព្រះពុទ្ធសាសនានៅសល់តិចតួចប៉ុណ្ណោះ។ ពៅរ៉ា បន្តថា វត្តអារាម គឺជាកន្លែងអប់រំ កន្លែងរក្សាគម្ពីរព្រះពុទ្ធសាសនា វប្បធម៌ ប្រវត្តិសាស្ត្រ ចម្លាក់ក្បូរក្បាច់ ដូច្នេះ នៅពេលបាត់បង់វត្តអារាម យើងនឹងបាត់បង់អ្វីៗទាំងអស់។ ការបាត់បង់ស្ថាបត្យកម្មបុរាណបែបព្រះពុទ្ធសាសនានឹងផ្តល់ផលលំបាកដល់ស្ថាបត្យករ និងអ្នកសិក្សាស្រាវជ្រាវអំពីស្ថាបត្យកម្មបែបព្រះពុទ្ធសាសនាឲ្យបានស៊ីជម្រៅខណៈដែលស្ថាបត្យកម្មរបស់ខ្មែរ និងស្ថាបត្យកម្មរបស់ថៃប្រហាក់ប្រហែលគ្នា។



សំណង់ស្ថាបត្យកម្មបុរាណបែបព្រះពុទ្ធសាសនាចំនួន២ ដែលបានកសាងឡើងនៅពុទ្ធសករាជ ២៤៧៤ ត្រូវនឹងគ្រិស្តសករាជ ១៩៣១ នៅវត្តលង្កាដែលត្រូវបានថែរក្សា នឹងជួសជុលឡើងវិញ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សូ សាផនៈ លេខាស្រុកកំពង់រោទិ៍ តំបន់២៣

*រី លក្ខិណា*



*ស្តូបតម្កល់អដ្ឋិធាតុជនរងគ្រោះក្នុងរបបខ្មែរក្រហមនៅឃុំធ្នូក ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ សូ សាផន អាយុ៨២ឆ្នាំ។ ខ្ញុំកើតនៅភូមិបុសមន ឃុំបុសមន ស្រុករំដួល តំបន់២៣ ខេត្តស្វាយរៀង។

ក្រោយថ្ងៃរំដោះភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំត្រូវនៅក្រោមការដឹកនាំរបស់ បងសូ លេខាតំបន់២៣ និងឈ្មោះ ធុច អនុលេខាតំបន់ ២៣។ នៅខែឧសភា ឆ្នាំ១៩៧៥ បងសូ បានសរសេរសំបុត្រមួយច្បាប់ឲ្យនីសារ ឈ្មោះ សុក យកមកឲ្យខ្ញុំនៅមន្ទីរស្រុកកំពង់រោទិ៍។ ក្នុងសេចក្តីសំបុត្រនោះ គឺឲ្យខ្ញុំចូលរួមប្រជុំនៅក្រុងស្វាយរៀង ក្នុងសាលាវិទ្យាល័យសោរិយាវង្ស។ ពេលដែលទទួលបានសំបុត្រហើយ រយៈពេលពីរថ្ងៃ ខ្ញុំក៏មកចូលរួមប្រជុំ ហើយអ្នកដែលចូលរួមប្រជុំមានចំនួន២៧នាក់។ ពេលប្រជុំ បងសូ បាននិយាយថា ថ្ងៃនេះខ្ញុំអញ្ជើញមិត្តទាំងអស់មកប្រជុំដើម្បីពិនិត្យសភាពការណ៍នៅក្នុងតំបន់២៣ និងពិនិត្យសភាពការណ៍ទូទាំងប្រទេសឲ្យច្បាស់នូវសកម្មភាពរបស់បក្សកុម្មុយនីស្តដឹកនាំ និងការដឹកនាំរបស់បក្សឥណ្ឌូចិន។ នៅក្នុងសង្គ្រាមសម័យវាយចក្រពត្តិអាមេរិក បក្សកុម្មុយនីស្តឥណ្ឌូចិនវាយអាមេរិកឈ្នះទាំងស្រុង បានឯករាជ្យនៅលើទឹកដីប្រទេសវៀតណាមភាគខាងត្បូង។ ឯបក្សកុម្មុយនីស្តកម្ពុជា ក៏បានវាយចក្រពត្តិអាមេរិកបានឈ្នះទាំងស្រុង។ តែពេល

វាយឈ្នះចក្រពត្តិហើយ បក្សកុម្មុយនីស្តកម្ពុជានៅតែប្រឆាំងនឹងបក្សកុម្មុយនីស្តឥណ្ឌូចិនដដែល។ ដូច្នេះយើងត្រូវធ្វើផែនការរដ្ឋប្រហារវាយកម្ពុជាឲ្យបានឆាប់រហ័ស ដែលសភាពការណ៍នៅកម្ពុជាអំណោយផលឲ្យយើង។ ពិនិត្យទៅកម្ពុជាមានកងទ័ពតិចអាវុធនៅខ្សោយសេដ្ឋកិច្ចទើបចេញពីសង្គ្រាម ឯរដ្ឋអំណាចក៏មិនទាន់រឹងប៉ឹងដែរ។ ប្រជាជនកំពុងខ្វះខាតខោអាវស្លៀកពាក់ ខ្វះថ្នាំសង្កូវព្យាបាលមិនទាន់មានជម្រកជ្រកនៅគ្រប់គ្រាន់។ សភាពការណ៍ដូចខ្ញុំជម្រាបខាងលើនេះ គឺខ្ញុំសូមលើកផែនការគឺ៖

១) សាខាបក្សឥណ្ឌូចិនដែលបង្កប់នៅកម្ពុជា មានឈ្មោះ កែវ មាស គឺជាលេខា។ សៀន អាន គឺអនុលេខា។ យ៉ា ជាសមាជិក។ នង សួនជាសមាជិក។ ឈូក សមាជិក និងខ្ញុំក៏ជាសមាជិកបក្សកុម្មុយនីស្តឥណ្ឌូចិន។ កម្លាំងនេះសម្រាប់ធ្វើសកម្មភាពអប់រំនយោបាយ អូសទាញប្រជាជនចេញពីបដិវត្តន៍កម្ពុជា ហើយកសាងកម្លាំងបង្កប់នៅកម្ពុជាវិញ។ ត្រូវចាត់តាំងបង្កប់នៅក្នុងសហករណ៍ តាមភូមិ តាមឃុំ និងតាមស្រុកដែលមិត្តម្នាក់ៗទទួលខុសត្រូវ។ ពេលចាត់តាំងហើយ ត្រូវប្រគល់ភារកិច្ចឲ្យធ្វើសកម្មភាព ដាក់ថ្នាំបំពុលក្នុងបាយ សម្លាប់សមាជិកសហករណ៍ លួចដុតជង្រុកស្រូវ និងយកគោក្របីទៅឲ្យយួន ឈ្មោះ ហៃ ហ៊ីង ប្រធានឃុំថៃទ្រី ស្រុកមុខវ៉ាវ។ ចាត់តាំងកម្លាំងខាងក្នុងឲ្យគប់គ្រាប់បែក និងចាំបាញ់កម្មាភិបាលរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលចុះទៅធ្វើការតាមស្រុករបស់ខ្លួន។

២) ត្រូវក្តាប់កម្លាំងយោធា និងកសាងកម្លាំងយោធាថ្មី ឯកម្លាំងដែលក្តាប់បានហើយ មានកងពលទី១ ឈ្មោះ ចក្រី យោធាតំបន់២៤។ មិត្តឈូក ទទួលខុសត្រូវយោធាតំបន់២៣។ យើងមានបីវរសេនាតូច មានឈ្មោះ ម៉ាន លេខាវរសេនាតូច២៣, សាត លេខាវរសេនាតូចលេខ២៨, សា៉ៈនលេខាវរសេនាតូច២៦។ ឯយោធាស្រុកគ្រប់ស្រុកមាន៨កងអនុសេនាធំទៀត។ បញ្ចូកសាងកម្លាំងយោធាក្នុងឆ្នាំ១៩៧៦។ ត្រៀមសេដ្ឋកិច្ចនៅតាមស្រុកនីមួយៗឲ្យបានស្រូវ១៥000ថាំង ដើម្បីត្រៀមធ្វើរដ្ឋប្រហារនៅថ្ងៃ៣០ ខែកញ្ញា ឆ្នាំ១៩៧៦។

បង សូ បញ្ជាក់ថា ផ្ទះសម្ងាត់របស់ខ្ញុំដែលសម្រាប់លាក់កម្មាភិបាលរបស់យួន សម្រាប់មកទាក់ទងមាននៅភូមិតាហោ ឃុំសង្ឃ័រ ស្រុកប្រសូត្រ មានឈ្មោះ មិត្តចុល ទទួលការពារ។ ផ្ទះមួយទៀតនៅភូមិបាក់រនាស់ ឃុំសង្ឃ័រ មានឈ្មោះ ជុន (អ្នកនិយាយគេអូតំបន់២៣) ជាអ្នកការពារ។ ផ្ទះទី៣ នៅភូមិហែកសំណាញ់ ឃុំម៉ឺនជ័យ ស្រុកសំរោង មានឈ្មោះសាជន ជាអ្នកការពារ។ ផ្ទះទី៤ នៅភូមិបុសកបុបាស នៅភូមិក្តីស្លា ជាផ្ទះគ្រួសាររបស់ខ្ញុំសម្រាកតែម្តង អ្នកការពារឈ្មោះ មឿន និង តឿ ជាកូនរបស់ខ្ញុំ ហើយមាន នារីវ៉ាត, នារីវ៉ែន និងនារីណាត ក៏ជួយការពារដែរ។

ក្រោយពីបងសូ ខទ្ទេសនាមផែនការចប់ហើយ អង្គប្រជុំទាំងមូលក៏ត្រូវបិទ។ ពេលចេញទៅដល់ស្រុកវិញ ខ្ញុំបានពិភាក្សាជាមួយមិត្ត សារិន នៅមន្ទីរស្រុកកំពង់រោទិ៍។ ខ្ញុំនិយាយថាយើងត្រូវកសាងកម្លាំងស្នូលនៅតាមសហករណ៍ឲ្យបាន ១៣នាក់ ក្នុងពេលដាប់ឆ្នាំ១៩៧៥។



អដ្ឋិធាតុជនរងគ្រោះពីរបបខ្មែរក្រហមនៅឃុំធ្លក ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ (ដេង ពងរ្ស៉ាសុី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

យើងធ្វើសកម្មភាពតាមរូបភាពលួចបំផ្លាញ អាវ៉ាសែ នារី-យុវជន ហើយសមាសភាពដែលត្រូវរើសយក គឺកូនសិស្ស ក្រុមអាវ៉ាសែ ឲ្យបាន ៥០នាក់ គឺងាយរកទេ ប៉ុន្តែកម្លាំងស្នូល ១៣នាក់ នោះពិបាករកណាស់។

បន្ទាប់ពីពិភាក្សាជាមួយ សារិន ហើយ គឺចាប់ពីខែមិថុនា ខែកក្កដា ខែសីហា ឆ្នាំ១៩៧៥ ខ្ញុំនិង សារិន កសាងកម្លាំងបានរួមមានឈ្មោះ គឹម សុក, កឹម ទឹម, ចាន់ គង់, ស សុន, ញ៉ុញ ពិសិត, ប្រាជ្ញ សាមី, អ៊ុក ដាន, ហែម សាលី, មុំ យ៉ាត, នេត ចឹម, សេក ហឿន, សៅ ណាន់ និង មាន យ៉ាត់។ ពេលខ្ញុំកសាងបានហើយ នៅខែកក្កដា ឆ្នាំ១៩៧៥ ដដែល ខ្ញុំបានហៅ សារិន, មិត្តហឿន, មិត្តណាន់, មិត្តយ៉ាត, មិត្តសុក, មិត្តគង់, មិត្តសុន, មិត្តពិសិត, មិត្តសាមី, មិត្តដាន មកប្រជុំនៅភូមិខ្សែត។ ខ្ញុំជម្រាបថា ខ្ញុំអញ្ជើញមិត្តមកថ្ងៃនេះ ដើម្បីឲ្យសហករណ៍យើងផ្តល់ស្រូវ៥០០បាវ និងគោ ក្របី១០នឹម យកទៅឲ្យឈ្មោះ ហៃ ហ៊ីង នៅភូមិសព្វទ័ព ស្រុកមុខវ៉ា ក្នុងដីយួន។

នៅខែកញ្ញា ឆ្នាំ១៩៧៥ ឈ្មោះ សុក ត្រូវជានីសាររបស់បង សូ បានយកសំបុត្រ ២ច្បាប់ មកឲ្យខ្ញុំ និងមិត្តសារិន។ សំបុត្រទី១ ផ្ញើទៅឲ្យ សៅ ខាន់ ទីប្រឹក្សាយោធារបស់ភូមិភាគទី៥។ មួយច្បាប់ទៀតផ្ញើមកឲ្យខ្ញុំ ខ្លឹមសារសំបុត្រទី២ ដាក់ថា សូមជម្រាបមក មិត្តជន និង មិត្តសារិន សូមជ្រាប៖ «នៅដើមខែកញ្ញា ឆ្នាំ១៩៧៥នេះ មិត្តទាំងពីរនាក់ត្រូវទៅជួប ជិន សុក និង ណាំ ឡុង នៅស្រុកមុខវ៉ា ដើម្បីទទួលយកគ្រាប់កាំភ្លើង ១០៥ មីលីម៉ែត្រ ចំនួន២០០គ្រាប់។ គ្រាប់៦០មីលីម៉ែត្រ ចំនួន៤០០គ្រាប់ និងគ្រាប់កាំភ្លើងដៃចំនួនមួយម៉ឺនកេះ។ គ្រាប់នេះត្រូវដឹកយកមកដាក់ទៅផ្សារកំពង់រោទិ៍ កន្លែងផ្ទះមិត្តម៉ាន ហើយនិងដាក់នៅក្នុងវត្តក្តីកណ្តាល មានមិត្តហឿន ជាអ្នកយាម។ ចុងក្រោយដាក់ឈ្មោះ ក្រូច គឺបងសូ»។

ទទួលសំបុត្រហើយបាន ៣ថ្ងៃ ទើបខ្ញុំជិះម៉ូតូទៅជួបមិត្ត ហឿន នៅផ្សារកំពង់រោទិ៍។ ខ្ញុំថា ខ្ញុំស្នើឲ្យមិត្តទាំង២នាក់ ការពារផ្លូវតាមព្រែកកំពង់រោទិ៍ និងផ្លូវចូលវត្តកណ្តាល ដើម្បីឲ្យខ្ញុំដឹកគ្រាប់មកទុកនៅកន្លែងទាំងពីរនេះ។ ហឿន និងម៉ាន ថា ខ្ញុំនឹងការពារផ្លូវឲ្យបងបាន ប៉ុន្តែគ្រាប់ច្រើនពេក ខ្ញុំមិនដឹងជាយកទៅដាក់នៅកន្លែងណាបានទេ។ ខ្ញុំមានយោបល់ថាដាក់នៅក្នុងលេណដ្ឋានសម្ងាត់របស់យើង គឺ២-៣កន្លែងវាអស់ហើយ។ ពេលប្រាប់មិត្តម៉ានហើយ ប្រហែលម៉ោង៩យប់ ខ្ញុំនិងមិត្តសារិន ក៏ជិះទូកទៅឡើងនៅភូមិប៊ិនហ៊ីប ដីយួន។ ទៅដល់ភូមិប៊ិនហ៊ីប ខ្ញុំនិងមិត្តសារិន ក៏ឡើងរកជួបនីសាស្រុកមុខវ៉ា ចម្ងាយពីមាត់ទន្លេគឺតៀង ចំនួន៥០០ម៉ែត្រ។ ដល់ជួបនីសាស្រុក ខ្ញុំក៏ហុចសំបុត្រទី២ ទៅឲ្យនីសាឈ្មោះ ថាន់ រួចខ្ញុំចាំនៅក្នុងមន្ទីរ១៥នាទី ក៏ឃើញរ៉ឺម៉កម៉ូតូមកដឹកខ្ញុំ និងសារិន ចូលទៅក្រុងកៀងគៀង។ រួចមកនីសាចុះទៅផ្ទះថ្មមួយជិតនោះ ហើយ ជិន សុក និងណាំ ឡុង ចេញមកទទួលខ្ញុំទាំងពីរនាក់ រួចនាំខ្ញុំចូលទៅក្នុងផ្ទះ។ ដំបូងខ្ញុំនិយាយថា «កាលពីខែកក្កដា ខែសីហា ខ្ញុំបានផ្តល់ស្រូវឲ្យមិត្ត ៥០០បាវ ក្របី និងគោ១០នឹម តើមិត្តបានទទួលគ្រប់គ្រាន់ហើយឬនៅ?» ។ ជិន សុក និយាយថា «សប្បាយរីករាយណាស់ ព្រោះខ្ញុំសព្វថ្ងៃកំពុងតែខ្វះខាត»។ ណាំ ឡុង ប្រាប់ខ្ញុំវិញថា គ្រាប់កាំភ្លើងដែល សៅ ខាន់ ផ្ញើតាមរយៈខ្ញុំ ដើម្បីផ្ញើទៅមិត្តសូ ខ្ញុំបានរៀបដាក់ក្នុងទូកគ្រប់ចំនួនអស់ហើយ។ មិត្តមកហើយ នៅតែចេញដំណើរទៅឲ្យដល់កន្លែងដែលមិត្តកំណត់ទេ។ ខ្ញុំទៅកន្លែង ណាំ ឡុង បានបន្តិចក៏ធ្វើដំណើរមកវិញ ហើយយួនដែលជួយដឹកគ្រាប់ចំនួន ៥នាក់ យកមកដាក់ឲ្យនៅផ្សារកំពង់រោទិ៍។ ពេលមកដល់ផ្សារកំពង់រោទិ៍ ខ្ញុំបានប្រាប់ មិត្តម៉ាន និងមិត្តហឿន ថាមិត្តថែរក្សាគ្រាប់នេះឲ្យបានគង់វង្ស រវាងតែ២-៣ថ្ងៃទៀតទេ។ បងសូ យកឡានមកដឹកចូលក្រុងស្វាយរៀងវិញ។

នៅខែតុលា ឆ្នាំ១៩៧៥ ខ្ញុំបានជិះម៉ូតូជាមួយនីសារឈ្មោះ មាក ចាន់ ទៅជួបមិត្តអាង និងបង ប្រាក់ សំបាត់ នៅភូមិបារាំង។ ខ្ញុំបាននិយាយថា បងសូ ឲ្យខ្ញុំមកទទួលយកមនុស្សពីកន្លែងបង និងមិត្តចំនួន ៣០ នាក់ ឥឡូវនៅត្រង់ណា? មិត្តអាង ឆ្លើយថា ខ្ញុំទុកនៅផ្ទះប្រជាជនថ្មីឈ្មោះ ពៅ ចេន ក្នុងភូមិបារាំង ឃុំបាសាក់ ស្រុកស្វាយរៀង។ ពេលបងសំបាត់ ប្រគល់មនុស្ស (យួន) ឲ្យខ្ញុំហើយ ខ្ញុំក៏សួរពីសកម្មភាពអប់រំប្រជាជនដែលប្រឆាំង

នឹងបដិវត្តន៍កម្ពុជាបានកម្រិតណា? បងសំបាត់ ថាការបំផុសឲ្យប្រជាជនស្រឡាញ់កម្មសិទ្ធិឯកជននេះ គឺបានឆាប់រហ័សណាស់ និងមានការចាត់តាំងឲ្យលួចគោ ក្របី ហើយយកទៅលក់ឲ្យយួនដែលកន្លងមកយកទៅលក់បានមួយចំនួនដែរ។ មិត្តអាង បន្តថា វស្សារាមិញនេះ បានចាត់តាំងកម្លាំងឲ្យស្ទូងស្រូវបត់គល់និងទប់ទឹកឲ្យរលួយស្រូវ ខូចអស់៤-១០ហិកតាដែរ។ យើងនិយាយគ្នារហូតដល់ជិតយប់ ទើបខ្ញុំនាំកងទ័ព៣០នាក់ ដើរឆ្លងភូមិកាខ្លង ឆ្លងមកភូមិអំពិល ហើយយកមកលាក់ទុកនៅផ្ទះប្រជាជនថ្មីឈ្មោះ ម៉ុក សារុន, ម៉ុក ហែម, សៅ ធី, ស តាក់ និង យីវ សន។

នៅខែវិច្ឆិកា ឆ្នាំ១៩៧៥ ខ្ញុំ និង សារិនបានចុះទៅពង្រីកកម្លាំងតាមព្រំដែន មានឃុំត្នោត ឃុំសំឡី។ ខ្ញុំចុះទៅកសាងកម្លាំងនៅឃុំពីរនេះដើម្បីងាយលាក់ការណ៍នៅពេលចេញចូលទៅទាក់ទងជាមួយយួន ព្រោះប្រជាជននៅម្តុំនោះមានឥទ្ធិពលទៅលើយួនច្រើន។ កម្លាំងដែលខ្ញុំកសាងបានពេលនោះមានឈ្មោះ សុន, វ៉ន, ញឹម, នៅ (នារី), គុន, អ៊ុក ប៉ាល់, សឿន, កែវ លី និង គ្រេង។ ពេលអប់រំបានហើយ ខ្ញុំបានប្រគល់ភារកិច្ចឲ្យកសាងកម្លាំងថែមទៀត នៅដាច់ឆ្នាំ១៩៧៥ ក្នុងមួយនាក់រកកម្លាំងឲ្យបាន ២នាក់ និងឲ្យអប់រំប្រជាជនឲ្យស្រឡាញ់បក្សកុម្មុយនីស្តឥណ្ឌូចិន ហើយឲ្យស្អប់បក្សកុម្មុយនីស្តកម្ពុជា។ ក្រៅពីនេះ ខ្ញុំបានប្រាប់ឲ្យអ្នកទាំងនោះដឹងថា បើមានទ័ពយួនចូលមកត្រូវយកលាក់ និងជួយខបត្តម្ភបាយទឹក។ ពេលខ្ញុំកសាងកម្លាំងបានហើយ នៅខែវិច្ឆិកា ឆ្នាំ១៩៧៥ ដដែល ខ្ញុំបានឆ្លងទៅជួបជាមួយបង សំអន និង មិត្តឈាង នៅមន្ទីរស្រុកចន្ទ្រា។ ខ្ញុំសួរបង សំអន ថា «ការទាក់ទងជាមួយយួនមានការលំបាក និងស្រួលយ៉ាងណាខ្លះ?» បង សំអន ថា «ការទាក់ទងយួនឥឡូវមានការលំបាក ព្រោះមានកងទ័ពភូមិភាគនៅតាមផ្លូវជាតិលេខ១១។ ខ្ញុំបាននាំយួនចូលមកហើយ បានជួបបាញ់គ្នានៅក្បែរព្រៃកូនគគីរ។ ក្រោយមកទៀតខ្ញុំបានយកកងទ័ពយួន មកលាក់ដើម្បីត្រៀមផែនការរបស់យើង



រូបគំនូរលើជញ្ជាំងសាលាបុណ្យ។ (ដេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ផែនទីភូមិធ្វកក្នុងរបបខ្មែរក្រហមលើជញ្ជាំងសាលាបុណ្យ។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅខែកញ្ញា ឆ្នាំ១៩៧៦ នៅក្នុងស្រុកចន្ទ្រាបានមួយចំនួនទៀតៗ ពិភាក្សាជាមួយបងសំអន ហើយខ្ញុំក៏ត្រឡប់មកមន្ទីរវិញ។

នៅថ្ងៃបន្ទាប់ បងសូ បានហៅខ្ញុំ និងមិត្តៗមកពី ៥ស្រុកទៀតឲ្យរាយការណ៍អំពីការកសាងកម្លាំងបង្កប់នៅក្នុងសហករណ៍ និងការលាក់មនុស្ស តើដំណើរការយ៉ាងម៉េចខ្លះ? ពេលបងសូ មានយោបល់ចប់ហើយ ខ្ញុំក៏បានរាយការណ៍ថា កម្លាំងស្នូលដែលខ្ញុំកសាងបាន គឺបាន២៨នាក់ ហើយ ៥០ នាក់ ទៀតគ្រាន់តែចាត់តាំងបានត្រឹមឲ្យដើរលួចៗ កាលពីខែមិថុនា ខែកក្កដា នេះ ខ្ញុំបានផ្តល់ស្រូវទៅឲ្យយួន ៥០០បាវ ក្របី គោ ១០នឹម និងយកកងទ័ពយួនមកលាក់បាន ៣០នាក់ មានមិត្តញ៉ៅប និងហួយ អ្នកចិញ្ចឹមឲ្យបាយទឹកៗ មិត្តសុផល មិត្តសាលីវ មិត្តសយ បានរាយការណ៍ថា គាត់នាំយួនមកវាយកងទ័ពភាគបានដុំៗដែរ និងចេញស្រូវ គោ គ្រប់ទៅឲ្យយួនបានជាបន្តបន្ទាប់ៗ មិត្តយើងរាយការណ៍ចប់ហើយ បងសូ លើកថា នៅខែធ្នូ ឆ្នាំ១៩៧៥ មានការប្រជុំរបស់យើងមួយនៅក្រុងស្វាយរៀង ដើម្បីពិនិត្យផែនការរបស់យើងៗ ឯអ្នកនៅស្រុកកំពង់រោទិ៍ ចាំទទួលយួន ២នាក់ គឺ សៅ ខាន់ និង ទី ធីន លេខាភូមិភាគទី ៥ ឲ្យមកចូលរួមប្រជុំជាមួយយើងៗ

ដល់ខែធ្នូ ឆ្នាំ១៩៧៥ ខ្ញុំ, មិត្តសារិន, មិត្តណាន់, មិត្តយ៉ាត បានអុំទូកទៅយកមិត្តយួនទាំងពីរនាក់នៅមន្ទីរស្រុកមុខវ៉ាៗ ម៉ោង៧យប់ ខ្ញុំបាននាំមិត្តយួនទាំង ២នាក់ទៅដល់ផ្សារកំពង់រោទិ៍ ហើយខ្ញុំបានគេអូឲ្យ បងសូ យកឡានមកដឹកយកទៅដាក់នៅមន្ទីរតំបន់ ២៣ ឯក្រុងស្វាយរៀងៗ យួន ២នាក់នេះ បានសម្រាកនៅកន្លែងបងសូ ៣ថ្ងៃ ទើបគាត់ហៅកម្លាំងមកចូលប្រជុំៗ ពេលប្រជុំ បងសូ មានយោបល់ថា ខ្ញុំអញ្ជើញមិត្តទាំងអស់មកប្រជុំ ដើម្បីពិនិត្យលើផែនការរបស់យើងដែលយើងដាក់ហើយ កាលពីខែឧសភា ឆ្នាំ១៩៧៥ៗ តើយើងធ្វើបាន «ខ» ណាខ្លះ? ហើយ «ខ» ណាដែលត្រូវធ្វើបន្តទៅទៀត និងខ្ញុំសូមសរុបជូនអង្គប្រជុំទាំងមូលថា «ការកសាងកម្លាំងបង្កប់នៅក្នុងសហករណ៍យើងធ្វើបានមួយ

ចំនួនធំហើយ។ កម្លាំងយោធា កសាងមួយស្រុកឲ្យបាន ១ អនុសេនាធំក៏បានហើយដែរ។ ផែនការប្រមូលផលស្រូវនៅតាមព្រំដែន មានស្រុកខ្លះធ្វើបានស្រុកខ្លះធ្វើមិនទាន់បាន។ ការដឹកគ្រាប់មកត្រៀមផែនការវាយបក្សនៅខែកញ្ញា ឆ្នាំ១៩៧៦ ក៏លាក់បានមួយចំនួនធំហើយដែរ។

បងសូ សរុបចប់ គាត់ក៏លើកផែនការសម្រាប់អនុវត្តនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៦ ថា «មុខសញ្ញាយោធាដែលត្រូវវាយគឺនៅដដែល មានយោធាស្រុកកំពង់រោទិ៍ ស្រុកស្វាយរៀង ស្រុកចន្ទ្រា និងកងទ័ពយួន នៅខេត្តឡុងអាងនៅពីក្រោយការវាយចូលក្រុងស្វាយរៀង ហើយចាប់ដៃជាមួយយោធាបងឈូក តំបន់ ២៤។ មុខសញ្ញាខាងជើងផ្លូវលេខ១មានស្រុកក្រសាំង យោធាស្រុកប្រសូត្រ យោធាស្រុកសំរោង ស្រុករមាសហែក និងកងតំបន់ ២៣ វាយឡើងទៅខេត្តព្រៃវែង ហើយមានយោធាខេត្តតៃនិញនៅពីក្រោយ។

បន្ទាប់មក ទី ធីង និយាយថា «ខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គប្រជុំទាំងមូល។ ខ្ញុំនឹងនាំកម្លាំងយោធារបស់ខ្ញុំ មានកងពលលេខ៥, កងពលលេខ២ និងកងពលលេខ២៩ ហើយមានកងពិសេសមួយចំនួន កាំភ្លើងធំគ្រប់ធុនរថក្រោះ មកជួយមិត្តខាងកម្ពុជាឲ្យបានសម្រេចនៅថ្ងៃ៣០ ខែកញ្ញា ឆ្នាំ១៩៧៦នេះ។

នៅខែកក្កដា ឆ្នាំ១៩៧៦ បងសូ បានផ្ញើសំបុត្រមួយច្បាប់ឲ្យមកខ្ញុំ និងមិត្តសារិនតាមរយៈ បងឆុំ។ ខ្លឹមសារសំបុត្រ «សូមមិត្តផន និងមិត្តសារិន ទៅទាក់ទងជាមួយឈ្មោះ ជិន សុក នៅស្រុកមុខវ៉ា និង ណាំ ឡុង ដើម្បីទទួលយកកាំភ្លើងពីមិត្ត សៅ ខាន និង ទី ធីង ផ្ញើកាំភ្លើងមកឲ្យ។ កម្លាំងដែលខ្ញុំឲ្យទៅពីតំបន់សម្រាប់ជួយដឹកជញ្ជូនមានឈ្មោះ មិត្តសារ៉ន, មិត្តសាមឿន, មិត្តពិន, មិត្តសុខុម, មិត្តស៊ា, មិត្តទាប, មិត្តយ៉ាន, មិត្តឆុំ និងមិត្តថាន់ ជាអ្នកបើកឡាន។ ថ្ងៃដែលមិត្តត្រូវចេញទៅដោយជួបជុំគ្នានៅផ្ទះពេទ្យ នៅផ្សារកំពង់រោទិ៍ ដល់ល្ងាចចាំចេញដំណើរ»។ ដល់ល្ងាចថ្ងៃទី១៥ ខែកក្កដា ខ្ញុំបានចេញដំណើរទៅដល់ផ្ទះពេទ្យ ហើយជុំគ្នាក៏អុំទូកទៅដល់ស្រុកមុខវ៉ា នៅភូមិបិនហ៊ឹប ខាងដីខ្មែរគឺភូមិថ្មី ស្រុកកំពង់រោទិ៍ ហើយខ្ញុំក៏បានហុចសំបុត្រទៅឲ្យនីរសារ។ នីរសារយកសំបុត្រទៅបាត់មួយភ្លែត ក៏ ណាំ ឡុង មកដល់ ហើយបានយកសំបុត្រទៅឲ្យ ជិន សុក។ ក្រោយមកជិន សុក ក៏ប្រគល់អាវុធ និងគ្រាប់មកឲ្យខ្ញុំ។ ល្ងាចម៉ោង៦ ទើបខ្ញុំយកគ្រាប់ដាក់លើទូក ហើយអុំយកមកដាក់នៅកន្លែងមិត្តម៉ាន នៅផ្សារកំពង់រោទិ៍។

នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៦ ខ្ញុំបានទទួលសំបុត្រពីបងសូ មួយច្បាប់ដែលមានខ្លឹមសារ «សភាពការណ៍ប្រែប្រួលហើយ មិនល្អទេ ដូច្នេះផែនការរបស់យើងត្រូវគ្រោះថ្នាក់ហើយ មិត្តត្រូវមានការប្រុងប្រយ័ត្ន។ កងទ័ពមិត្តដែលដកមកដាក់នៅខាងមុខនោះ ឥលូវត្រូវយកទៅដាក់កន្លែងដដែលវិញ ដើម្បីកុំឲ្យគេចាប់អារម្មណ៍។ ឯកងទ័ពវៀតណាម ៣០នាក់ ដែលខ្ញុំឲ្យមិត្តយកមកទុកនៅភូមិអំពិលនោះ មិត្តត្រូវឲ្យគេយកចេញឲ្យអស់នៅយប់នេះ»។ ពេលទទួលសំបុត្រហើយខ្ញុំភ័យណាស់ ហើយរត់ទៅជួប មិត្តសារិន ភ្លាម។ ខ្ញុំប្រាប់សារិនថាផែនការរដ្ឋប្រហាររបស់យើងត្រូវបែកការណ៍ហើយ។ បងសូ ឲ្យយើងទៅដកទ័ពចេញឲ្យអស់ពីព្រំដែនស្រុកស្វាយរៀង។ ពេលប្រាប់ សារិន ហើយ ខ្ញុំបានទៅប្រាប់ឲ្យយួន នៅភូមិអំពិលចេញពីស្រុកកំពង់រោទិ៍ទៅវៀតណាមឲ្យអស់។ ចាប់ពីពេលនោះមក ខ្ញុំត្រូវផ្អាកទាក់ទងគ្នាមួយរយៈ ដោយអង្គការចាប់ ធុច, យ៉ា, សុផាត និង ជ័យ សារី។

នៅខែមេសា ឆ្នាំ១៩៧៧ បងសូ បានហៅខ្ញុំ មិត្តសារិន, មិត្តសាលីវ, មិត្តសំអន, មិត្តសារ៉េត, មិត្តឆែម, មិត្តស៊ែល, មិត្តទាប, បងឆុំ, បងយ៉ាន ទៅប្រជុំនៅផ្ទះគាត់នៅភូមិពោធិតាហោ ស្រុកប្រសូត្រ។ បងសូ និយាយថា ខ្ញុំអញ្ជើញមិត្តមកប្រជុំនេះ បន្ទាប់ពីមានផែនការបរាជ័យនៅថ្ងៃ៣០ ខែកញ្ញា ឆ្នាំ១៩៧៦មកយើងត្រូវធ្វើសកម្មភាពបន្តទៅទៀត។ យើងត្រូវធ្វើសកម្មភាពនៅតាមស្រុកនីមួយៗ ត្រូវចាត់តាំងកម្លាំងឲ្យនាំយួនចូលមកស៊ើបការណ៍កន្លែងយោធាភាគបោះ

នៅ ហើយនិងពិនិត្យភូមិសាស្ត្រដាក់ទ័ព។ ត្រូវវាយតាមច្រកណាហើយត្រូវដកទៅវិញតាមច្រកណា ប្រសិនបើចាញ់ ហើយកម្លាំងរបស់យើងឲ្យទៅនៅក្នុងដីយួនជិតដីកម្ពុជា។ គណៈទាក់ទង ត្រូវទាក់ទងឲ្យជាប់ឡើងវិញ ចាំនាំកម្មាភិបាលយួនសំខាន់ៗឲ្យមកជួបពិភាក្សាជាមួយខ្ញុំ។ បងសូ ថាយើងចុះទៅក្តាប់សភាពការណ៍ ហើយផែនការវាយយ៉ាងម៉េចអីយ៉ាងម៉េច ចាំខ្ញុំជម្រាបមិត្តនៅពេលខាងក្រោយ ព្រោះខ្ញុំមិនទាន់បានជួបពិភាក្សាជាមួយលេខាភាគទី៥នៅឡើយ។ បន្ទាប់ពីពិភាក្សារួចខ្ញុំក៏ត្រឡប់ទៅកន្លែងសម្រាកវិញ។

នៅខែតុលា ឆ្នាំ១៩៧៧ ដល់ផែនការវាយ ខ្ញុំបានចាត់តាំងមិត្តហឿន, មិត្តណាន់, មិត្តយ៉ាត ឲ្យនាំទ័ពយួនមួយវរសេនាតូច មកវាយកងទ័ពភាគលេខ ២៦៩ កំពុងធ្វើស្រែនៅព្រៃវល្លិ៍។ ថ្ងៃនោះទ័ពភាគបូព៌ាស្លាប់អស់ជាង១០នាក់ រួចទ័ពយួនបោះទ័ពនៅព្រៃវល្លិ៍នេះទៀត។ ដល់ខែធ្នូ ឆ្នាំ១៩៧៧ កងទ័ពស្រុកទាំងអស់ និងកងតំបន់២៣ បានបើកផ្លូវគ្រប់មុខសញ្ញាទាំងអស់ឲ្យយួនវាយចូលមកយកខេត្តស្វាយរៀង។ ចំណែកកងទ័ពស្រុកកំពង់រោទ៍ ខ្ញុំបានបញ្ជាឲ្យមិត្តហឿន, មិត្តណាន់, មិត្តយ៉ាត បញ្ជាឲ្យថយរហូតដល់ស្រុកមានជ័យថ្មី ៣០គីឡូពីព្រំដែន។ ពេលយួនវាយចូលមកខ្លាំងខ្ញុំបានបំផុសយុទ្ធជនឲ្យបាញ់គោ ប្រូតស្រូវ បាញ់ជ្រូក ចាប់មាន់ និងទា។ ខ្ញុំបានចាត់តាំងមិត្តហឿន, មិត្តណាន់, មិត្តយ៉ាត ឲ្យបញ្ជាយុទ្ធជនឲ្យឡើងលើផ្ទះប្រជាជននៅជិតវត្តស្វាយជ្រុំនៅភូមិត្បែងតាហោង ឡើងទៅកើបស្រូវប្រជាជន។

នៅថ្ងៃទី២ ខែមករា ឆ្នាំ១៩៧៨ បងសូ ហៅខ្ញុំ មិត្តសារ៉េត, មិត្តសាលីវ, មិត្តសាផល, បងសំអន, បងខសុរ៉ាហ៍, បងសយ, មិត្តឆែម ទៅជួបនៅលើផ្ទះរបស់គាត់នៅភូមិក្តីស្លា ស្រុកមានជ័យថ្មី។ បងសូ និយាយថាសភាពយោធារបស់យើងឥឡូវធ្ងន់ធ្ងរហើយ ដោយកងទ័ពកម្ពុជាត្រូវវាយកងទ័ពវៀតណាមចេញពីក្រុងស្វាយរៀង ៩គីឡូទៅខាងកើត។ មើលទៅមិនអាចទប់ទល់នឹងបដិវត្តន៍កម្ពុជាបានទេ ដូច្នេះយើងត្រូវតែធ្វើផែនការដើម្បីវាយទប់ទល់វិញ។ ទី១) ត្រូវវាយកម្ទេចគណៈបញ្ជាការសមរភូមិខេត្តស្វាយរៀង មានបងតាល់, បងណាត, បងពីន, បងខៀវ និងគណៈបញ្ជាការកាំភ្លើងធំ និងបញ្ជាការរថក្រោះ។ ទី២) ត្រូវក្តាប់កន្លែងទីបញ្ជាការបោះនៅដោយបោកគ្រាប់បែក ឬបាញ់នៅពេលសមរភូមិកំពុងច្របូកច្របល់។ ទី៣) រៀបចំចាត់តាំងកម្លាំងរបស់តំបន់ប្រគល់ឲ្យ មិត្តឆែម ឲ្យរៀបកម្លាំងតាមកម្ទេចគណៈបញ្ជាការនៅខាងស្រុកសំរោង និងនៅតំបន់២៤ ដោយរួមជាមួយកម្លាំងយោធាស្រុកប្រសូត្រ មាន សាលីវ ទទួលខុសត្រូវ។

ក្រោយពីទទួលផែនការហើយ ខ្ញុំបានចាត់តាំងហឿន ទៅចាំបាញ់នៅភូមិព្រៃនេង ។ ណាន់ នៅចាំបាញ់ក្បែរស្ពានទន្លាង។ យ៉ាត នៅចាំបាញ់ត្រង់ផ្សារប្រសូត្រ។ ប៉ុន្តែអ្នកទាំងនោះត្រៀមចាំបាញ់ចំនួន៤-៥ ថ្ងៃ មិនបានជួបកម្លាំងរបស់ខ្ញុំក៏លែងចាំទៅ។

នៅថ្ងៃទី៩ ខែមករា ឆ្នាំ១៩៧៨ បងថាន់បានបើកឃ្លាំងដឹកកាំភ្លើងអាកា២០ដើម ដែលយួនជំនួយនោះមកឲ្យខ្ញុំនៅវត្តស្វាយជ្រុំ។ បងថាន់ ថា កាំភ្លើងនេះ បងសូ ឲ្យខ្ញុំដឹកយកមកឲ្យបងសម្រាប់បំពាក់ឲ្យកម្លាំងដែលកសាងបាន រួចបងថាន់ ហុចសំបុត្រមួយច្បាប់មកឲ្យខ្ញុំ។ ខ្លឹមសារសំបុត្រដាក់ថា «សូមជម្រាបមក មិត្តផន ខ្ញុំប្រគល់កាំភ្លើងឲ្យ២០ដើម មានថាន់ អ្នកទៅដឹកឲ្យមិត្តយកកាំភ្លើងនេះទៅ សម្រាប់បំពាក់ឲ្យកម្លាំងរបស់យើងដែលយើងកសាងបាន»។ ពេលទទួលកាំភ្លើងនេះហើយ ខ្ញុំបានយក១០ដើម ទៅឲ្យ មិត្តណាន់ ដើម្បីចែកដល់កម្លាំងដែលចាំបាញ់គណៈបញ្ជាការបច្ចុប្បន្ន ១០ដើមនេះ ពេលអង្គការដកកងស្រុកកំពង់រោទ៍ ទៅនៅក្នុងកងតំបន់២៣ កាំភ្លើងនេះក៏ទៅនៅក្នុងកងតំបន់២៣ដែរ។ អ្នកទទួលកាំភ្លើងនេះរួមមាន ប្រាក់ សំរិត, កែវ ឡេន, គង់ ម៉ាប់, ចាន់ ឿន, សារិត, ចែម, កែវ វុទ្ធី, បាត់ សុខុម, ហេង ប៊ុន និង កែវ យី។

ផែនការដែលត្រូវកំណត់វាយនៅខែមិថុនា ឆ្នាំ១៩៧៨ ពេលរដូវធ្លាក់ភ្លៀង ដើម្បីកុំឲ្យប្រជាជនកម្ពុជាធ្វើស្រូវបានហូប។ បងសំអន លើកឡើងថា ផែនការខាងក្នុងកម្ពុជា ចាត់តាំងកម្លាំងយោធាតំបន់ ស្រុក ដកចម្រូង និងគ្រាប់

បែកឲ្យអស់ ដើម្បីឲ្យស៊ើបការណ៍ចូលបាន។ យោធារបស់តំបន់ដែលនៅជួរមុខ នៅធ្នូក នៅចន្ទ្រា សំរោងទួលស្ពីរ ហូតដល់បារិតខាងលើ មិនឲ្យដាក់គ្រាប់បែក និងចម្រូងទេ។

ខាងក្នុងចាំទទួលទ័ពបន្ទួរចូលមកបង្កប់នៅត្រង់ចំណុចភូមិបាត់ត្រាស់ ឃុំដូង ហើយនិងតាមផ្លូវឃុំតាសួស ស្រុកក្រសាំងមានតែពីរស្រុកនេះទេដែលសម្រាប់ទទួលទ័ពយកមកលាក់សម្រាប់ធ្វើផែនការខាងក្រោយនេះ។ សៅ ខាន់ ថាវិធីប្រយុទ្ធរបស់យើងលើកនេះ គឺវាយពីចំហៀង វាយពីមុខ និងវាយពីក្រោយ។ ការប្រជុំក៏ចប់ ខ្ញុំ, បងសំអន, មិត្តឈាង, មិត្តសារិន ក៏ត្រឡប់មកផ្ទះវិញ។ ខ្ញុំនិងបងសំអន ទៅរាយការណ៍ឲ្យបងសូនៅមន្ទីរតំបន់ នៅលើភ្នំខ្យាច់ស។ ខ្ញុំរាយការណ៍ថា ផែនការវៀតណាម ត្រូវវាយនៅខែមេសា ខែមិថុនា ឆ្នាំ១៩៧៨ នេះទៀតហើយ ក្រៅពីនេះខ្ញុំបានរាយការណ៍ពីកម្លាំងទ័ព អាវុធ រថក្រោះ ឲ្យបងសូ ដឹង។ បងសូ ថាខ្ញុំត្រូវទាក់ទងឲ្យជាប់តាមគេអូ ឬតាមរយៈគណៈទាក់ទងឈ្មោះ អាង និង ប្រាក់ សំបាត់ នៅស្រុកស្វាយរៀង។ រាយការណ៍ហើយខ្ញុំត្រឡប់មកមន្ទីរវិញ ដល់ខែមីនា ឆ្នាំ១៩៧៨ អង្គការចាប់ខ្លួនខ្ញុំតែម្ដង។



ផែនទីភូមិធ្លកក្នុងរបបខ្មែរក្រហមលើជញ្ជាំងសាលាបុណ្យ។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# យោង គីម
## ចែករំលែកបទពិសោធន៍ក្នុងរបបខ្មែរក្រហម ក្នុងអំឡុងវេទិកាប្រវត្តិសាស្ត្រគ្រួសារ

***រី លក្ខិណា***

តាមរយៈវេទិកាប្រវត្តិសាស្ត្រគ្រួសារ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម បានចុះទៅសម្ភាសន៍ជនជាតិភាគតិចស្ទៀង នៅក្នុងឃុំចំនួន៣ គឺឃុំជាំតាម៉ៅ, ឃុំជាំក្រវៀន និងឃុំទន្លូង នៃស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម បានសម្រេចចិត្តជ្រើសរើសឃុំជាំតាម៉ៅមុនគេដើម្បីធ្វើការសម្ភាសន៍ជនជាតិភាគតិចស្ទៀង ក្នុងការធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសារ។ ឃុំជាំតាម៉ៅ មានចំនួន ៣ភូមិដែលមានជនជាតិស្ទៀងរស់នៅគឺភូមិទួលគ្រួស, ភូមិកន្ទួត និងភូមិស្រែតាពិច។

ជាដំបូងក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម បានទាក់ទងទៅ ពៅ ផូរ គឺជាមេឃុំជាំតាម៉ៅ ដើម្បីសុំការអនុញ្ញាតចុះធ្វើការក្នុងភូមិសាស្ត្រឃុំជាំតាម៉ៅ។ លោកមេឃុំបានសហការយ៉ាងល្អ និងបានអនុញ្ញាតឲ្យចុះទៅតាមភូមិដែលមានជនជាតិស្ទៀងរស់នៅ។ បន្ទាប់មកក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានទាក់ទងទៅមេភូមិទួលគ្រួស ប៉ុន្តែមេភូមិជាប់រវល់នៅចម្ការ ក្រុមការងារបានទាក់ទងទៅមេភូមិស្រែតាពិច ហើយក៏បានចុះទៅធ្វើការនៅទីនោះវិញ។

ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មធ្លាប់បានឮភូមិស្រែតាពិច នៅពេលចុះទៅសម្ភាសន៍ជនជាតិស្ទៀងនៅឃុំទន្លូង។ ប្រជាជននៅឃុំទន្លូងប្រាប់ថា នៅពេលដែលមជ្ឈិមបានចោទប្រកាន់ថាភូមិភាគបូព៌ាក្បត់ គឺខ្មែរក្រហមបានជម្លៀសប្រជាជនពីឃុំទន្លូងឲ្យមករស់នៅភូមិស្រែតាពិចវិញ។

ភូមិស្រែតាពិច មានចម្ងាយប្រមាណ២០គីឡូម៉ែត្រពីថ្នល់ជាតិលេខ៧ត្រង់ចំណុចភូមិក្តុល។ នៅក្រោយផ្ទះរបស់ប្រជាជនមានវាលស្រែពណ៌បៃតងស្រងាត់។ ប្រជាជនដែលមានវ័យចាស់ៗភាគច្រើននៅផ្ទះ ចំណែកកូនៗដែលមានកម្លាំងអាចបំពេញការងារទៅធ្វើចម្ការ ហើយកុមារៗទៅរៀន។ ក្នុងភូមិស្រែតាពិច មានបឋមសិក្សាមួយឈ្មោះថា បឋមសិក្សាស្រែតាពិច មានពីរអគារ គឺអគារមួយសង់ពីថ្ម និងអគារមួយទៀតសង់ពីឈើ។ ប្រសិនបើសិស្សចង់បន្តការសិក្សានៅវិទ្យាល័យ សិស្សត្រូវជិះទៅរៀននៅវិទ្យាល័យក្តុល ដែលមានចម្ងាយប្រមាណ២០គីឡូម៉ែត្រពីភូមិស្រែតាពិច។

ពេលក្រុមការងារបានធ្វើដំណើរសំដៅទៅផ្ទះមេភូមិ និងប្រាប់ពីគោលបំណងរបស់ក្រុមការងារចុះមកធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសារ មេភូមិបានណែនាំមនុស្សមួយចំនួនដែលមានវ័យចាប់ពី៦០ឆ្នាំឡើងទៅ។ បន្ទាប់មក ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានទៅជួបក្រុមគ្រួសាររបស់តា យោង គីម។ យោង គីម បានរៀបរាប់ពីប្រវត្តិរបស់គាត់ប្រាប់ក្រុមការងារដូចខាងក្រោម៖



យោាយ គីម អាយុ៧៩ឆ្នាំ គឺជាជនជាតិស្ទៀង នៅភូមិព្រែកកាតែខាងកើត ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម។ (ការត ស្រីឡែន/មជ្ឈមណ្ឌលឯកសារកម្ពុជា)



យោាយ គីម ផ្តល់បទសម្ភាសន៍ដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម នៅផ្ទះរបស់គាត់នៅភូមិព្រែកកាតែខាងកើត ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម ក្នុងវេទិកាប្រវត្តិសាស្ត្រគ្រួសារ។ (ការត ស្រីឡែន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ យោាយ គីម មានអាយុ៧៩ឆ្នាំ គឺជាជនជាតិស្ទៀង។ ខ្ញុំមានស្រុកកំណើតនៅភូមិព្រែកកាតែខាងកើត ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម។ សព្វថ្ងៃខ្ញុំរស់នៅភូមិស្រែតាពិច ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ប្រពន្ធរបស់ខ្ញុំឈ្មោះ ឌី ទី អាយុ៧១ឆ្នាំ។ ខ្ញុំមានកូនប្រុសចំនួន៤នាក់ និងបានស្លាប់អស់ចំនួន ២នាក់ នៅក្នុងរបបខ្មែរក្រហមដោយសារអត់អាហារ។ ខ្ញុំមានឪពុកឈ្មោះ យោាយ និងម្តាយឈ្មោះ គីម និងមានបងប្អូនបង្កើតចំនួនពីរនាក់ ស្រីមួយនាក់ និងប្រុសមួយនាក់។

## ជីវិតពីកុមារភាព

កាលពីក្មេងខ្ញុំរៀនបានត្រឹមថ្នាក់ទី៣ នៅវត្តកន្ទួតដែលនៅសម័យនោះនៅក្នុងភូមិមិនទាន់មានសាលារៀននៅឡើយ។ វត្តកន្ទួត ស្ថិតនៅក្នុងសង្កាត់ជាំតាម៉ៅ។ នៅពេលបារាំងចូលមកកាប់ដីព្រៃដើម្បីដាំកៅស៊ូ ប្រជាជននៅក្នុងភូមិព្រែកកាតែខាងកើតមិនហ៊ានតវ៉ាងទីលំនៅជិតបារាំងឡើយ ព្រោះខ្លាចគោ ក្របីចូលទៅស៊ីកៅស៊ូរបស់បារាំង។ ប្រសិនបើធ្វើឲ្យមានការខូចខាតផលដំណាំកៅស៊ូ ប្រជាជនត្រូវសងប្រាក់ឲ្យបារាំងមិនខាន។ ប្រជាជនបាននាំគ្នាភៀសខ្លួនពីភូមិចូលទៅរស់នៅក្នុងព្រៃ ហើយប្រជាជនមួយចំនួនទៀតដែលមានសាច់ញាតិបានទៅរស់នៅភូមិព្រែកតាពូក និងភូមិបេងកោង ដែលមានចម្ងាយឆ្ងាយពីចម្ការកៅស៊ូរបស់បារាំង។ ពេលខ្ញុំនៅក្មេងខ្ញុំធ្លាប់បានឃើញជនជាតិបារាំងមកសាលាសង្កាត់ជាំតាម៉ៅ ហើយខ្ញុំបានសួរព្រះសង្ឃថាអ្នកទាំងនោះគឺជាជនជាតិអ្វី បានជាមានមាឌធំ មានច្រមុះធំ? ព្រះសង្ឃបានប្រាប់ខ្ញុំថា «ជនជាតិបារាំង»។ ជនជាតិបារាំងបានដើរក្នុងព្រៃដើម្បីរកក្រុមខ្មែរឥស្សរៈដែលប្រឆាំងនឹងបារាំងដែរ។

## ជំនឿរបស់បងប្អូនជនជាតិស្ទៀង

កាលពីសម័យមុន ជនជាតិភាគតិចស្ទៀងនៅក្នុងភូមិតែងតែនិយាយភាសាស្ទៀងលើកលែងតែពេលដែលចេញក្រៅភូមិ ទើបជនជាតិភាគតិចស្ទៀងនាំគ្នានិយាយភាសាខ្មែរ។ ចំណែកជំនឿជនជាតិភាគតិចស្ទៀងជឿទៅលើអារក្ខ អ្នកតា និងពេលខែចូលឆ្នាំ ប្អុំបិណ្ឌ ជនជាតិស្ទៀងនាំគ្នាទៅវត្តដូចប្រជាជនខ្មែរដែរ។ នៅពេលឈឺស្កាត់ម្តងៗ ជនជាតិភាគតិចស្ទៀងបន់ដល់អ្នកតា ដោយមានពាក្យថា «ប្រសិនបើកូនចៅធ្វើខុស សូមកុំប្រកាន់ទោស ជួយឲ្យកូនចៅជាសះស្បើយ



ប្រពន្ធរបស់ យោយ គីម។
(គាត ស្រីឡែន/មជ្ឈមណ្ឌលឯកសារកម្ពុជា)



យោយ គីម, ប្រពន្ធ និងចៅៗរបស់គាត់។ (គាត ស្រីឡែន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

កូនចៅនឹងលេងភ្លេងអារក្ខសែនមាន់ស្ងោរ» ។ ចំណែកថ្នាំវិញ ជនជាតិភាគតិចស្ទៀងប្រើតែឫសឈើ ថ្នាំបុរាណដោយមិនទៅព្យាបាលនៅមន្ទីរពេទ្យឡើយ។ នៅខែវស្សាជនជាតិភាគតិចស្ទៀងតែងតែកាប់ព្រៃរានដីដើម្បីដាំចម្ការ និងស្រូវ។ ជនជាតិភាគតិចស្ទៀងដាំស្រូវនៅទីតាំងដដែលរយៈពេល៣ឆ្នាំ ទើបផ្លាស់ប្តូរទៅកន្លែងថ្មីទៀត។ ពេលជនជាតិភាគតិចស្ទៀងប្រមូលផលស្រូវបានហើយ ត្រូវយកទៅបង់ពន្ធឲ្យរាជការសង្កាត់ទន្ទឹង។ ក្រៅពីធ្វើចម្ការ ជនជាតិភាគតិចស្ទៀងប្រកបរបរបោចវល្លិ៍ និងចាប់សត្វព្រៃសម្រាប់ធ្វើម្ហូប។ នៅខែប្រាំងជនជាតិភាគតិចចាមតែងតែយកត្រីឆ្អើរ ត្រីងៀត ប្រហុក មកដូរនឹងស្រូវជាមួយជនជាតិភាគតិចស្ទៀង។ នៅសម័យនោះ ប្រសិនបើខ្ញុំចង់សាងសង់ផ្ទះធំ ខ្ញុំត្រូវតែសុំការអនុញ្ញាតពីមេព្រៃទើបអាចកាប់ឈើបាន ទោះបីសម្បូរព្រៃឈើក៏ដោយ។ ជនជាតិស្ទៀងគ្មានរឿងនិទានជាប្រវត្តិជនជាតិរបស់ខ្លួនឡើយ គឺខ្ញុំធ្លាប់ឮតែរឿងទុំទាវប៉ុណ្ណោះ។ នៅជិតស្រែរបស់ខ្ញុំ មានស្រែមួយហៅថាស្រែត្នោត មានដើមត្នោតមួយដើម ហើយមានរឿងដំណាលថា ពេលដែលព្រះមហាក្សត្រឲ្យនិរទេសក្រុមគ្រួសារ អរជូន ចេញពីពោធិ៍ដើងខាល ក្រុមគ្រួសារ អរជូន បានមកធ្វើស្រែនៅនឹងស្រែត្នោត។ ប្រជាជននៅក្នុងស្រុកភូមិតែងតែហៅស្រែនោះថា គឺជាស្រែរបស់ អរជូន។ សព្វថ្ងៃដើមត្នោតបានបាក់ហើយ គឺនៅតែព្រៃរបោះបន្តិចបន្តួច ចំណែកផ្ទះក៏មិនសេសសល់ស្លាកស្នាមដែរ។

## រដ្ឋប្រហារទម្លាក់សម្តេចព្រះបាទនរោត្តម សីហនុ

នៅឆ្នាំ១៩៧០ បន្ទាប់ពីខ្ញុំរៀបការបានរយៈពេល៣ខែ ទាហាន លន់ នល់ បានចូលមកក្នុងភូមិរបស់ខ្ញុំជ្រើសរើសបុរសៗឲ្យចូលធ្វើជាទាហាន ដើម្បីយាមប្រចាំការនៅព្រំដែនកម្ពុជា-វៀតណាម ត្រង់តំបន់ចាន់មូល។ ខ្ញុំបានឃើញការទម្លាក់គ្រាប់បែកនៅព្រំដែនវៀតណាមត្រង់ទន្លេចាមដើម្បីតាមរកវៀតកុង។ នៅពាក់កណ្តាលឆ្នាំ១៩៧០ ខ្ញុំត្រឡប់មកភូមិវិញ ខ្ញុំបានឃើញទាហានអាមេរិកចូលមកក្នុងភូមិជាមួយទាហានធីវគី ហើយក៏ចាប់ផ្តើមមានការទម្លាក់គ្រាប់បែកបេ-៥២ចាប់តាំងពីពេលនោះមក។ រណ្តៅបេ-៥២មួយចំនួនបាននៅសេសសល់ក្នុងចម្ការរបស់ខ្ញុំរាល់ថ្ងៃ។ ខ្ញុំធ្លាប់បានឃើញថៅកែៗអង្ករ បានដឹកអង្ករយកឲ្យវៀតណាមនៅតាមព្រំដែនទន្លេចាម។ ខ្ញុំបានឃើញទាហានអាមេរិកចូលមកក្នុងភូមិខ្ញុំតែម្តងគត់ ហើយភាគច្រើនទាហានទាំងនោះនៅតែក្នុងបន្ទាយប៉ុណ្ណោះ។ ក្រៅពីនោះ ខ្ញុំបានឃើញបន្ទាយរបស់ទាហានអាមេរិកពីរ

ទៅបើកន្លែងទៀត ដូចជា នៅពងទឹក និងនៅទន្លេងជាដើម។ នៅឆ្នាំ១៩៧១ ទាហានអាមេរិកបានដកកងទ័ពចេញអស់ពីបន្ទាយ ក្រោយមកក៏មិនមានយន្តហោះចូលមកភូមិ និងការទម្លាក់គ្រាប់បែកដែរ។ ក្រោយពេលដែលទាហានអាមេរិកដកចេញអស់ ស្រាប់តែខ្ញុំឃើញកងទ័ពវៀតកុងចូលមកក្នុងភូមិជាញឹកញាប់។ កងទ័ពវៀតកុងយកអង្រឹង និងខោអាវ មកដោះដូរជាមួយមាន់ ហើយប្រសិនបើកងទ័ពវៀតកុងចង់ហូបឪឡឹក បន្លែ គឺត្រូវសុំអនុញ្ញាតពីម្ចាស់ចម្ការ និងប្រជាជននៅក្នុងភូមិ។

នៅពេលខ្មែរក្រហមទទួលបានជ័យជម្នះនៅឆ្នាំ១៩៧៥ ក្រុមគ្រួសារខ្ញុំ និងជនជាតិភាគតិចស្ទៀងផ្សេងទៀតបានភៀសខ្លួនទៅនៅភូមិភ្នំ ពីព្រោះភូមិរបស់ខ្ញុំកើតមានជំងឺអាសន្នរោគ។ ខ្ញុំ និងជនជាតិភាគតិចស្ទៀងបានចុះមកនៅភូមិព្រែកតាពូកវិញ ព្រោះនៅលើភូមិភ្នំមិនមានប្រភពទឹកប្រើប្រាស់។ មុនដំបូង ខ្មែរក្រហមចាត់តាំងប្រជាជនឲ្យធ្វើការក្នុងក្រុមប្រវាស់ដៃដែលមានសមាជិក១២គ្រួសារក្នុងមួយក្រុម។ ពេលដែលប្រជាជនបានផលដំណាំត្រូវចែកគ្នាតាមសមាជិកគ្រួសារនីមួយៗ។ ក្រោយមកខ្មែរក្រហមបង្ខំប្រជាជនឲ្យដាក់ទ្រព្យសម្បត្តិរួម ដែលធ្វើឲ្យខ្ញុំហូបមិនគ្រប់គ្រាន់។ ខ្មែរក្រហមជម្លៀសខ្ញុំ និងអ្នកភូមិទៅរស់នៅភូមិស្ទឹងត្រី ឃុំដាំក្រវៀន។ មូលហេតុដែលខ្មែរក្រហមជម្លៀសអ្នកភូមិ រួមទាំងគ្រួសារខ្ញុំឲ្យទៅនៅភូមិស្ទឹងត្រី ព្រោះខ្មែរក្រហមយល់ឃើញថា អ្នកភូមិរបស់ខ្ញុំជាភូមិគំរូមិនមានប្រជាជនរត់ទៅប្រទេសវៀតណាម។ ចំណែកអ្នកភូមិមួយចំនួនធំនៅខាងស្ទឹងត្រីពីមុនមកបានរត់ចូលទៅខាងប្រទេសវៀតណាមអស់ហើយ។ ពេលទៅដល់ភូមិស្ទឹងត្រី ខ្ញុំត្រូវចាត់តាំងឲ្យធ្វើស្រែ ចំណែកប្រពន្ធរបស់ខ្ញុំលើកភ្លឺស្រែ និងកាស់គល់ឈើ។ កាលពីជំនាន់ខ្មែរក្រហម ឃុំដាំក្រវៀន ស្ថិតនៅក្នុងស្រុកត្រមូង តំបន់២១ ភូមិភាគបូព៌ា។ អេង គឺជាប្រធានសង្កាត់នៅដាំក្រវៀន។ នៅរដូវប្រាំង ខ្មែរក្រហមបានឲ្យខ្ញុំទៅលើកទំនប់អាងមាត់ខ្មុង។

នៅឆ្នាំ១៩៧៨ ខ្មែរក្រហមបានជម្លៀសខ្ញុំ និងអ្នកភូមិឲ្យទៅស្រុកស្នួល ខេត្តក្រចេះ ព្រោះខ្លាចវៀតណាមមកទាន់។ ពេលនោះនៅស្រុកស្នួល មានមនុស្សស្លាប់យ៉ាងច្រើន ព្រោះមិនមានអាហារហូបគ្រប់គ្រាន់ និងមានជំងឺគ្រុនចាញ់។ កូនរបស់ខ្ញុំម្នាក់ស្លាប់នៅស្រុកស្នួលដោយសារតែអត់អាហារ។ ចំណែកម្តាយខ្ញុំបានស្លាប់បន្ទាប់ពីសម្រាលកូននៅមន្ទីរពេទ្យស្រែស្បូវ។ ខ្ញុំរស់នៅស្រុកស្នួលរយៈពេលខ្លី ខ្មែរក្រហមក៏បញ្ជូនខ្ញុំទៅឃុំថ្មគ្រែ បន្ទាប់មកបញ្ជូនតាមកាណូតទៅស្រុកស្ទឹងត្រង់ ក្នុងភូមិភាគកណ្តាល។ ចុងក្រោយខ្ញុំ និងក្រុមគ្រួសារបានទៅរស់នៅក្នុងភូមិស្វាយភ្លើង ឃុំស្វាយភ្លើង ស្រុកបារាយណ៍ ខេត្តកំពង់ធំ។ ប្រជាជនចាស់នៅភូមិស្វាយភ្លើងមានចិត្តល្អ និងបានឲ្យអំពៅខ្ញុំហូប។

ខ្មែរក្រហមបានហាមមិនឲ្យជនជាតិភាគតិចស្ទៀងក្នុងភូមិនិយាយភាសាស្ទៀងទេ បើមិនស្តាប់ទេ ខ្មែរក្រហមនឹងយកអ្នកទាំងនោះទៅអប់រំ ដូច្នេះហើយទើបខ្ញុំមិនសូវនិយាយភាសាស្ទៀងរហូតមកដល់សព្វថ្ងៃ។

## ក្រោយរបបខ្មែរក្រហម

នៅពេលដែលកងទ័ពវៀតណាមចូលមកដល់ ខ្ញុំសប្បាយចិត្តណាស់ ព្រោះបានត្រឡប់មកផ្ទះវិញ។ ខ្ញុំនិងក្រុមគ្រួសារបានធ្វើដំណើររយៈពេល១០ថ្ងៃ ទើបមកដល់ភូមិស្រែតាពិច និងបានរស់នៅទីនេះរហូតមកដល់សព្វថ្ងៃ។ ខ្ញុំតែងតែនិយាយរឿងរ៉ាវដែលខ្ញុំធ្លាប់បានឆ្លងកាត់ពីជំនាន់ខ្មែរក្រហមប្រាប់ដល់កូនចៅរបស់ខ្ញុំ ដើម្បីជាការក្រើនរំឭក កុំឲ្យរបបខ្មែរក្រហមត្រឡប់មកវិញ។ ខ្ញុំមិនចង់ឲ្យកូនចៅរបស់ខ្ញុំជួបបញ្ហាលំបាក អត់ឃ្លាន ដូចជាខ្ញុំធ្លាប់ជួបទេ។

សព្វថ្ងៃជនជាតិភាគតិចស្ទៀងលែងសូវប្រើវិធីបុរាណដើម្បីព្យាបាលជំងឺទៀតហើយ គឺពេលឈឺថ្កាត់ម្តងៗជនជាតិស្ទៀងទៅកាន់មណ្ឌលសុខភាព ឬក៏មន្ទីរពេទ្យ។ ប៉ុន្តែជំនឿលើអារក្ខ នៅតែរក្សាដដែល។

# ខ្ញុំស្ម័គ្រចិត្តកស៊ូជាមួយខ្មែរក្រហម

អ៊ុន សុជាទី

អោម វឿន ភេទស្រី អាយុ៦៤ ឆ្នាំ រស់នៅភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់។ វឿនបានរៀបរាប់អំពីរឿងរ៉ាវជីវិតរបស់គាត់តស៊ូជាមួយខ្មែរក្រហមថា៖

ខ្ញុំមានស្រុកកំណើតនៅភូមិក្តីរុន ឃុំខ្វាវ ស្រុកទ្រាំង ខេត្តតាកែវ។ ឪពុករបស់ខ្ញុំឈ្មោះ អោម អេប បានស្លាប់ចោលខ្ញុំតាំងតែពីខ្ញុំមានអាយុ៣ឆ្នាំមកម៉្លេះ។ ម្តាយរបស់ខ្ញុំឈ្មោះ ឃឹម ភុន ។ ម្តាយរបស់ខ្ញុំស្លាប់នៅក្នុងអំឡុងឆ្នាំ១៩៨៨។ ខ្ញុំមានបងប្អូនចំនួន ៤នាក់ ហើយខ្ញុំគឺជាកូនទី៣ ក្នុងចំណោមបងប្អូនរបស់ខ្ញុំ។

តាំងពីតូចមក ខ្ញុំមិនដែលបានទទួលបានការអប់រំជាផ្លូវការនៅក្នុងសាលារៀននោះទេ។ ខ្ញុំបានត្រឹមតែចូលរៀនអក្ខរកម្មជាមួយនឹងចាស់ៗនៅក្នុងភូមិបានរយៈពេលត្រឹមតែមួយឆ្នាំប៉ុណ្ណោះ។ ក្រោយមក ខ្ញុំក៏ឈប់រៀនមកជួយម្តាយរបស់ខ្ញុំធ្វើស្រែចម្ការចិញ្ចឹមជីវិត។

នៅពេលដែលខ្ញុំមានអាយុ១៧ឆ្នាំ ខ្ញុំបានចាកចេញពីផ្ទះមករស់នៅជាមួយក្រុមខ្មែរក្រហម។ នៅពេលនោះខ្ញុំតែងតែឮអ្នកស្រុកនិយាយតៗគ្នាថា ខ្មែរក្រហមតស៊ូវាយប្រឆាំងជាមួយអាមេរិកកាំង។ អំឡុងឆ្នាំ១៩៧៤ ខ្ញុំនិងមិត្តភក្តិនៅក្នុងភូមិរបស់ខ្ញុំជាច្រើននាក់ បានចេញមកស្ម័គ្រចិត្តតស៊ូជាមួយខ្មែរក្រហម។ ដំបូង ខ្ញុំបានចាកចេញពីផ្ទះទៅរស់នៅក្នុងកងនារីតំបន់១៣ ជាមួយនឹងខ្មែរក្រហមដែលមានទីតាំងនៅម្តុំភ្នំដិនក្បែរព្រំប្រទល់ប្រទេសវៀតណាម។ នៅក្នុងកងនារី ខ្មែរក្រហមបានឲ្យខ្ញុំនិងនារីផ្សេងទៀតទៅសមរភូមិត្រៀមជាមួយកងយុទ្ធជនដើម្បីការពារព្រំដែន។ នៅពេលនោះ ខ្ញុំទទួលបានកាំភ្លើង១ដើមទុកជាប់នឹងខ្លួនដើម្បីការពារសុវត្ថិភាព។ ទោះបីជាខ្ញុំចេញទៅការពារសមរភូមិ ប៉ុន្តែខ្ញុំមិនបានប៉ះទង្គិចគ្នាជាមួយកងទ័ពវៀតណាមនោះទេ។ ខ្ញុំ គ្រាន់តែនៅក្នុងជួរត្រៀមតាមពីក្រោយតែប៉ុណ្ណោះ។ ខ្ញុំ ក៏បានចូលរួមហាត់កងទ័ពនៅឯវត្តមួយក្បែរផ្សារទន្លាប់។ ខ្ញុំបានហាត់ចូលវាយបន្ទាយ។ ខ្ញុំត្រូវរត់លូនចូលតាមរបងលួសជាមួយនារីនិងបុរសជាច្រើននាក់ទៀត។ ខ្ញុំបានហាត់កងទ័ពនេះបានប្រហែលជា១ខែ ហើយក៏ឈប់ទៅ។ ប្រធានកងវរសេនាធំរបស់ខ្ញុំឈ្មោះ សុខា ហើយខ្ញុំគឺជាកូនក្រុមសមាជិក។ ខ្ញុំរស់នៅឯភ្នំដិនបានរយៈពេលប្រហែល៦ខែ។



អោម វឿន ភេទស្រី អាយុ៦៤ឆ្នាំ នៅភូមិរបស់គាត់នៅភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់។

នៅខែចុងឆ្នាំ១៩៧៤ ខ្ញុំបានចាកចេញមកនៅរស់នៅតំបន់ត្រពាំងរូង ខេត្តកោះកុង។ នៅទីនោះ ខ្ញុំនៅតែបន្តធ្វើជាកងទ័ពខ្មែរក្រហមដដែល ប៉ុន្តែនៅក្នុងកងផ្សេងពីមុន ព្រោះនៅពេលនោះ ខ្មែរក្រហមបានបញ្ចូលកងទ័ពដែលមកពីភ្នំដិនចូលទៅក្នុងកងតូចៗរួមជាមួយគ្នាទាំងអស់។ ខ្ញុំធ្វើជាកងទ័ពខ្មែរក្រហមបានប្រហែលជា ៣ខែ ខ្ញុំបានផ្លាស់ប្តូរមកធ្វើជាគ្រូពេទ្យនៅឃុំអណ្តូងទឹកវិញ។ ប្រធានពេទ្យតំបន់១១នោះមានឈ្មោះថា ពូសឹង។ ខ្ញុំចេះតែរៀនពេទ្យតាមការអនុវត្តជាក់ស្តែងព្រោះខ្ញុំមិនចេះអក្សរនោះទេ។ នៅពេលដែលមានអ្នករបួសយកចូលមក

ក្នុងមន្ទីរពេទ្យ ខ្ញុំបានជួយលាងរបួស និងជួយព្យាបាលរបួសខ្លះៗដែរ។ នៅពេលនោះ ខ្ញុំចេះចាក់ថ្នាំ និងអាចព្យាបាលជំងឺធម្មតាៗបាន ប៉ុន្តែប្រសិនបើមានអ្នកជំងឺឈឺធ្ងន់ៗនោះ ខ្ញុំមិនអាចព្យាបាលបានទេ។ ខ្ញុំចេះតែព្យាបាលរបួស និងជំងឺគ្រុនតិចតួចតែប៉ុណ្ណោះ។ ប្រជាជនភាគច្រើនមានជំងឺគ្រុនចាញ់ ហើយប្រជាជនខ្លះទៀតខ្វះជីវជាតិ ដែលមានរូបរាងហើមនិងស្លេកស្លាំង។ អ្នកជំងឺណាដែលខ្វះជីវជាតិ ខ្ញុំព្យាបាលដោយប្រើថ្នាំជាតិដែកនិងវីតាមីន។ នៅក្នុងមន្ទីរពេទ្យនោះ គឺមានគ្រូពេទ្យច្រើនណាស់ ប៉ុន្តែនៅពេលដែលមានអ្នករបួសច្រើនពេក អ្នកគ្រប់គ្រងមន្ទីរពេទ្យ បានបំបែកគ្រូពេទ្យឲ្យចេញទៅតាមទីតាំងផ្សេងៗគ្នា។ ចំណែកខ្ញុំ នៅតែបន្តព្យាបាលអ្នកជំងឺនិងអ្នករបួសនៅតែក្នុងមណ្ឌលទេ។ អ្នករបួសភាគច្រើន ដែលបញ្ជូនមកកាន់មន្ទីរពេទ្យ គឺជាកងទ័ពដែលបញ្ជូនមកពីសមរភូមិ។ ខ្ញុំធ្វើជាគ្រូពេទ្យនៅឃុំអណ្ដូងទឹកចាប់តាំងពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៨។

នៅក្នុងរបបខ្មែរក្រហម ខ្ញុំមិនដែលមកលេងស្រុកកំណើតនោះទេ។ ខ្ញុំចេះតែគិតនៅក្នុងចិត្តថា ម្ដាយឪពុក និងបងប្អូនរបស់ខ្ញុំបានស្លាប់អស់ហើយ ព្រោះយើងបែកគ្នាយូរពេក ថែមទាំងមិនដែលបានទទួលដំណឹងពីគ្នាទៅវិញទៅមកនោះទេ។

នៅពេលកងទ័ពវៀតណាមចូលមកក្នុងប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៧៩ ខ្ញុំបានសម្រេចចិត្តមិនរត់ទៅស្រុកកំណើតនោះទេ ព្រោះស្រុកកំណើតរបស់ខ្ញុំនៅឆ្ងាយពេក។ ខ្ញុំរត់ទៅតាមអង្គភាពរបស់ខ្មែរក្រហមនៅតាមជួរព្រំដែន។ មុនដំបូង ខ្ញុំរត់គេចពីកងទ័ពវៀតណាមចូលទៅក្នុងព្រៃ ហើយក៏វង្វេងផ្លូវពាសពេញព្រៃនោះ។ ក្រោយមក ខ្ញុំបានសម្រេចចិត្តរត់ទៅតាមចាស់ៗដែលបានរត់ចូលព្រៃជាមួយគ្នា។ នៅពេលដែលពួកគាត់នាំខ្ញុំទៅទីណា ខ្ញុំតែងតែដើរទៅតាមគាត់។ នៅពេលនោះ ខ្ញុំមិនហ៊ានត្រឡប់មកផ្ទះជួបឪពុកម្ដាយ និងសាច់ញាតិរបស់ខ្ញុំនោះទេ ព្រោះខ្ញុំខ្លាចកងទ័ពវៀតណាមណាស់។ ចាស់ៗដែលរស់នៅជាមួយខ្ញុំនោះ តែងតែនិយាយតៗគ្នាថា កងទ័ពវៀតណាមនឹងយកក្បាលខ្មែរទៅដុំធ្វើជាចង្ក្រាន។ ចំណែកឯនៅតាមផ្លូវវិញ ខ្ញុំតែងតែឮប្រជាជននិយាយថា កងទ័ពវៀតណាមនឹងចាប់យកប្រជាជនខ្មែរទៅដាក់គុក។ ដូច្នេះខ្ញុំខ្លាចកងទ័ពវៀតណាមណាស់។

ខ្ញុំបានរត់ទៅរស់នៅក្នុងជំរំ «៨» នៅលើទឹកដីថៃ ហើយក្រោយមកខ្ញុំបានត្រឡប់មកនៅក្នុងទឹកដីខ្មែរវិញ នៅតាមជួរព្រំដែននៅម្ដុំអូរល្ហុង ខាងស្រុកសំឡូតវិញ ព្រោះនៅក្នុងជំរំ «៨» ជនជាតិថៃនិយាយតែភាសាថៃទេ។ ខ្ញុំបានសម្រេចចិត្តត្រឡប់ចូលមករស់នៅក្នុងទឹកដីខ្មែរវិញ ព្រោះយើងអាចនិយាយភាសាខ្មែរបានដូចគ្នា។ ខ្ញុំធ្លាប់បានត្រឡប់ចូលទៅជំរំ «៨»ម្ដងម្កាលវិញដែរ។ បន្ទាប់ពីពេលដែលខ្ញុំត្រឡប់មកពីជំរំ «៨»វិញ ខ្ញុំនៅតែបន្តធ្វើការជាមួយនឹងខ្មែរក្រហមនៅក្នុងអង្គភាពដឹកជញ្ជូន។ ខ្ញុំធ្លាប់បានដឹកជញ្ជូនទៅកាន់ខេត្តកំពង់ស្ពឺ។ ខ្ញុំធ្វើការងារនៅក្នុងកងដឹកជញ្ជូនរហូតដល់ខ្ញុំរៀបការ។

ខ្ញុំរៀបការនៅពេលដែលខ្ញុំមានអាយុ៣០ឆ្នាំ នៅតំបន់កញ្ចែ ក្បែរព្រំប្រទល់ប្រទេសថៃ។ ប្ដីរបស់ខ្ញុំឈ្មោះ នាក់ ផេង ហើយគាត់មានអាយុតិចជាងខ្ញុំមួយឆ្នាំ។ ប្ដីរបស់ខ្ញុំមានស្រុកកំណើតនៅក្នុងខេត្តកំពត។ គាត់គឺជាជនពិការ ហើយគាត់មិនអាចធ្វើការងារអ្វីបាននោះទេ។ ក្រុមគ្រួសាររបស់ខ្ញុំ រស់នៅតំបន់កញ្ចែមិនបានប៉ុន្មានផង ខ្ញុំក៏បានផ្លាស់មករស់នៅភូមិអូរនោង ឃុំតាតោក ស្រុកសំឡូត ខេត្តបាត់ដំបងវិញ។ ខ្ញុំរស់នៅទីនោះរហូតដល់ឆ្នាំ ១៩៩៥ ។ បន្ទាប់មក អង្គភាពពិការ ដែលមាន តាសយ គឺជាអ្នកគ្រប់គ្រង បានផ្លាស់ក្រុមគ្រួសាររបស់ខ្ញុំឲ្យត្រឡប់មករស់នៅក្នុងឃុំអណ្ដូងទឹកវិញ។ នៅពេលដែលខ្ញុំត្រឡប់មកដល់ភូមិវិញ គឺមានសុទ្ធតែព្រៃដុះទ្រុបទ្រុល ហើយមានប្រជាជនតែ៤០គ្រួសារនោះទេ។ ខ្ញុំបានដាំស្រូវ ដាំសណ្ដែក និងល្ពៅសម្រាប់ផ្គត់ផ្គង់ដល់ជីវភាពគ្រួសារ។

បន្ទាប់ពីស្ថានភាពសង្គ្រាមស្ងប់ស្ងាត់បន្តិចក្នុងឆ្នាំ ១៩៩៨ ខ្ញុំបានត្រឡប់ទៅលេងស្រុកកំណើតហើយស្នាក់ជាមួយបងស្រីរបស់ខ្ញុំអស់រយៈពេល១សប្ដាហ៍។ នៅពេលនោះ ម្ដាយរបស់ខ្ញុំ បានស្លាប់បាត់បង់ជីវិតទៅហើយ។ ចំណែកឯប្អូនប្រុស និងបងប្រុសរបស់ខ្ញុំ ក៏បានស្លាប់ដែរ។ សមាជិកក្រុមគ្រួសាររបស់ខ្ញុំ គឺនៅសល់តែបងស្រីរបស់ខ្ញុំនិងខ្ញុំតែប៉ុណ្ណោះ។ ក្រោយៗមកទៀត ខ្ញុំមិនធ្លាប់បានទៅសួរសុខទុក្ខបងស្រីរបស់ខ្ញុំទៀតនោះទេ ប៉ុន្តែបងស្រីរបស់ខ្ញុំបានមកលេងជាមួយខ្ញុំបានចំនួន ២ ដង។ ខ្ញុំចង់ទៅលេងស្រុកកំណើតឲ្យបានញឹកញាប់ណាស់ ប៉ុន្តែខ្ញុំខ្វះខាតសោហ៊ុយនៅក្នុងការធ្វើដំណើរ។ សព្វថ្ងៃនេះ ខ្ញុំមានកូនចំនួន ៥ នាក់ គឺកូនស្រីចំនួន៣នាក់ និងកូនប្រុសចំនួន២នាក់។

# ហ៊ីង ហោះ៖ តួសម្តែងក្នុងកងសិល្បៈខ្មែរក្រហម

ស្ងួត វិចិត្រ



ហ៊ីង ហោ អាយុ៥៧ឆ្នាំ និងប្រពន្ធរបស់គាត់នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (ស្ងួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ហ៊ីង ហោ ភេទប្រុស អាយុ៥៧ឆ្នាំ មានទីកន្លែងកំណើតនៅភូមិរុន ឃុំដានរុន ស្រុកសូទ្រនិគម ខេត្តសៀមរាប។ ហោ បាននិយាយរៀបរាប់ពីជីវិតក្នុងកងកុមារ និងការងារនៅក្នុងកងសិល្បៈខ្មែរក្រហមថា «កាលពីឆ្នាំ១៩៧៣ ខ្ញុំបានរស់នៅជួបជុំជាមួយម្តាយ។ ឪពុករបស់ខ្ញុំគឺជាកងទ័ពខ្មែរក្រហមក្នុងតំបន់រំដោះខេត្តសៀមរាប។ ស្ថានភាពនៅក្នុងភូមិរបស់ខ្ញុំនៅពេលនោះគឺច្របូកច្របល់ណាស់ ហើយមនុស្សម្នាជាច្រើនបាននាំគ្នារត់ចូលទៅក្នុងព្រៃ ដើម្បីគេចខ្លួនពីការទម្លាក់គ្រាប់បែករបស់ទាហាន លន់ នល់។

នៅអំឡុងពេលហេតុការណ៍នោះកើតឡើង ខ្ញុំក៏បានឃើញយន្តហោះជាច្រើនគ្រឿងរបស់កងទ័ព លន់ នល់ មកទម្លាក់គ្រាប់បែកនៅលើភូមិឋានរបស់ខ្ញុំ ជាពិសេសនៅជាយៗភូមិដែលមានកងទ័ពខ្មែរក្រហម។ កងទ័ពជើងអាកាសទាំងនោះ ថែមទាំងបានដាក់ការសង្ស័យមកលើភូមិរបស់ខ្ញុំថា មានកងទ័ពខ្មែរក្រហមជាច្រើនកំពុងលាក់ខ្លួននៅក្នុងភូមិ។ មិនយូរប៉ុន្មាន គ្រាប់បែកមួយគ្រាប់បានធ្លាក់ចំកណ្តាលភូមិរបស់យើង។ សំណាងល្អគ្រាប់បែកប្រវែង១.៥ម៉ែត្រនោះមិនផ្ទុះ។ ទោះបីជាយ៉ាងនេះក្តីប្រជាជននៅក្នុងភូមិបានទទួលរងការគំរាមកំហែងយ៉ាង

ធ្ងន់ធ្ងរពីហេតុការណ៍ទម្លាក់គ្រាប់បែកនេះ។ ប្រជាជនក្នុងភូមិមានការភ័យខ្លាច និងព្រាត់ប្រាស់ក្រុមគ្រួសារជាបន្តបន្ទាប់ នៅពេលដែលអ្នកទាំងនោះបាននាំគ្នារត់ចូលទៅសម្ងំលាក់ខ្លួនក្នុងព្រៃ។ ប្រជាជនមួយចំនួនបានបន្សល់ខ្លួនរស់នៅក្នុងព្រៃក្នុងរយៈពេលខ្លីរួចហើយក៏នាំគ្នាត្រឡប់មកកាន់លំនៅឋានរបស់ខ្លួនវិញ។ ប្រជាជនមួយចំនួនធំទៀតបានបន្តរស់នៅជាមួយខ្មែរក្រហមក្នុងព្រៃរយៈពេលយូរ។ ប្រជាជនដែលត្រឡប់មករស់នៅក្នុងភូមិឋានរបស់ខ្លួនវិញក៏បានប្រទះឃើញនូវគ្រាប់បែកដែលមិនទាន់ផ្ទុះស្ថិតនៅចំកណ្ដាលភូមិ និងបាននាំគ្នាប្រញាប់ប្រញាល់ទៅដោះយកក្បាលគ្រាប់នោះចេញ និងចូកយករំសេវដាក់ដោយឡែកដើម្បីបង្ការគ្រោះថ្នាក់នៅពេលក្រោយ។ ប្រជាជនដែលត្រឡប់ទៅក្នុងភូមិទាំងនោះ ក៏ទទួលរងនូវការគំរាមកំហែង និងការឈឺចាប់ដោយការចាប់ខ្លួនពីសំណាក់ទាហាន លន់ នល់, ការទម្លាក់គ្រាប់បែក និងការឆក់ប្លន់ទ្រព្យសម្បត្តិនៅក្នុងភូមិដែលជំរុញឲ្យប្រជាជននៅក្នុងភូមិ ដែលរត់ចូលព្រៃបានចូលរួមជាមួយចលនាខ្មែរក្រហមកាន់តែច្រើនឡើង។

ដោយសារតែមានការចូលរួមពីប្រជាជន និងមកពីគ្រប់មូលដ្ឋានកើនឡើងជាមួយខ្មែរក្រហមពីមួយថ្ងៃទៅមួយថ្ងៃ ដូច្នេះហើយ កងទ័ព លន់ នល់ បានទទួលរងភាពបរាជ័យ។ ទីក្រុងភ្នំពេញទាំងមូល បានធ្លាក់ទៅក្នុងការគ្រប់គ្រងរបស់ខ្មែរក្រហមទាំងស្រុងនៅក្នុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។

បន្ទាប់ពីជ័យជម្នះរបស់ខ្មែរក្រហម ខ្ញុំត្រូវបានបញ្ជូនទៅធ្វើការងារក្នុងកងកុមារ។ កុមារនៅពេលនោះមិនទទួលបានការរៀនសូត្រពេញលេញ និងការហូបចុកគ្រប់គ្រាន់ទេ។ កុមារនៅក្នុងកងរបស់ខ្ញុំ ដែលមានគ្នាចន្លោះពី៥០នាក់ទៅ១០០នាក់ បានចំណាយពេលវេលារបស់ខ្លួនស្ទើរតែទាំងស្រុងទៅលើការងារបម្រើអង្គការរបស់ខ្មែរក្រហម។ ជារៀងរាល់ថ្ងៃ យើងដើររើសអាចម៍គោ, កាប់ដើមទន្ទ្រានខែត្រ និងធ្វើជីដាក់ស្រែ។ យើងទទួលបានរបបមួយកូនចានតូចក្នុងមួយពេល។ ប្រធានកងរបស់យើងបានផ្ដល់របបអាហារស្មើៗគ្នា ដោយមិនគិតពីកូនរបស់ប្រជាជនចាស់ ឬប្រជាជនថ្មីឡើយ។

ខ្ញុំបានរស់នៅក្នុងកងកុមារ រហូតដល់ខ្ញុំមានវ័យធំល្មមដែលអាចសម្ដែងជាតួក្នុងកងសិល្បៈបាន។ ខ្ញុំបានសម្ដែងជាតួតុក្កតាកំប្លែងនៅក្នុងរឿង «អ៊ុណាវបុស្បា» ដែលបានដកស្រង់ចេញពីរឿងប្រលោមលោកខ្មែរ។ រឿងនេះ បានបែងចែកជាឈុតឆាកកម្សត់បែបស្នេហា និងតុក្កតាកំប្លែង។ ការសម្ដែងរឿងនេះ មានការប្រើស្គរដៃ ឬជួនកាលជំនួសដោយធុងដងទឹកទៀតផង ដែលញ៉ាំងឲ្យបរិយាកាសមានភាពសប្បាយរីករាយ។ យើងបានជ្រើសរើសអ្នកសម្ដែងប្រមាណពី១០ទៅ១២នាក់នៅក្នុងសហករណ៍។

ខ្ញុំមិនធ្លាប់ទៅសម្ដែងនៅក្រៅភូមិទេ ដោយសារខ្ញុំនៅមានភាពខ្មាស់អៀន។ ខ្ញុំចាំបានថា រឿង «អ៊ុណាវបុស្បា» មិនដែលបានសម្ដែងដល់វគ្គបញ្ចប់ទេ ដោយសារពេលខ្លះក្រុមរបស់ខ្ញុំខ្វះតួអង្គសម្ដែង និងពេលខ្លះទៀតអ្នកទស្សនាបានបបួលគ្នាទៅដេកអស់។ ជាទូទៅ យើងបានសម្ដែងដល់យប់ជ្រៅ ដោយមិនកំណត់ពេលវេលាជាក់លាក់សម្រាប់សម្ដែងទេ។ គោលបំណងនៃការសម្ដែងរបស់យើង គឺគ្រាន់តែចង់សម្រាលបន្ទុកនឿយហត់របស់ប្រជាជនក្នុងសហករណ៍តែប៉ុណ្ណោះ។

នៅក្នុងតួបែបតុក្កតាកំប្លែង ខ្ញុំបានធ្វើឲ្យមនុស្សគ្រប់គ្នាទាំងចាស់ទាំងក្មេងបានសើចលេងសប្បាយរីករាយ បើទោះបីជាជីវិតនៅតាមសហករណ៍បានប្រឈមនូវការលំបាក និងស្ថិតនៅក្នុងស្ថានភាពអត់ឃ្លានយ៉ាងណាក៏ដោយ។



ហ៊ីង ហោ ផ្ដល់បទសម្ភាសន៍ដល់ក្រុមស្រាវជ្រាវមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៅក្នុងវេទិកាប្រវត្តិសាស្ត្រគ្រួសារ។ (សួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# អណ្តូងសាកសពរបស់ប្រជាជនថ្មីនៅក្នុងភូមិ

**ហ៊ាន ពិសី**



ម៉ន យាន នៅផ្ទះរបស់គាត់នៅស្រុកអន្លង់វែង ខេត្ត ឧត្តរមានជ័យ។ (ហ៊ាន ពិសី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ម៉ន យាន ភេទស្រី អាយុ៥៨ឆ្នាំ មានទីកន្លែងកំណើតនៅក្នុងភូមិចំការអណ្តូង ឃុំចំការអណ្តូង ស្រុកចំការលើ ខេត្តកំពង់ចាម។ យាន ចែករំលែកពីបទពិសោធន៍ជីវិតតស៊ូតាំងពីកុមារ រួមជាមួយនឹងរឿងរ៉ាវជាច្រើនអំឡុងពេលធ្វើដំណើរមកដល់អន្លង់វែងថា ៖

នៅក្នុងទសវត្សន៍ឆ្នាំ១៩៧០ ខ្ញុំឃើញមានការទម្លាក់គ្រាប់បែកយ៉ាងសន្ធឹកសន្ធាប់នៅភូមិចំការអណ្តូង។ ពេលនោះស្ថានភាពនៅក្នុងភូមិចលាចល និងពោរពេញទៅដោយរណ្តៅគ្រាប់បែក។ ក្នុងឆ្នាំ១៩៧៥ គ្រួសារខ្ញុំ និងប្រជាជនក្នុងភូមិចំការអណ្តូងត្រូវបានជម្លៀសចេញម្តងបន្តិចៗទៅកាន់ឃុំស្តឹ ស្រុកចំការលើ ខេត្តកំពង់ចាម។ សម័យនោះ ខ្ញុំមិនស្គាល់ថា តើមេខ្មែរក្រហមជានរណានោះទេ គឺខ្ញុំគ្រាន់តែធ្វើទៅតាមអ្វីដែលខ្មែរក្រហមបង្គាប់ប៉ុណ្ណោះ។ ខ្មែរក្រហមបានបញ្ជូនឲ្យខ្ញុំទៅធ្វើការងារនៅក្នុងកងកុមារ។ ការងារដែលខ្ញុំទទួលបាននៅកងកុមារ គឺកាប់ទន្ទ្រានខែត្រធ្វើជី និងដកស្មៅស្រូវ។ ក្រោយមកខ្ញុំមានវ័យធំបន្តិច ខ្ញុំត្រូវបានខ្មែរក្រហមជ្រើសរើសយកទៅនៅភូមិប្រើសមាស ដើម្បីជួយការងាររែកដី និងលើកទំនប់នៅក្នុងកងចល័តនារី។ ចំណែកម្តាយរបស់ខ្ញុំត្រូវបានខ្មែរក្រហមបញ្ជូនទៅនៅរោងម៉ាស៊ីនកិនស្រូវរបស់សហករណ៍ ចំណែកឪពុកខ្ញុំគឺធ្វើស្រែក្នុងជំនាន់នោះ។ បន្ទាប់មកខ្មែរក្រហមបានផ្លាស់ឪពុករបស់ខ្ញុំមកធ្វើជាចុងភៅនៅភូមិប្រើសមាសវិញ។ ខ្ញុំមិនសូវជួបការលំបាកប៉ុន្មានទេទាក់ទងនឹងការហូបចុក។ ខ្ញុំទទួលបានបាយ បបរហូបឆ្អែតគ្រប់គ្រាន់ ហើយក៏គ្មាននរណាម្នាក់អត់ឃ្លានដែរ។ បន្ទាប់ពីទំនេរពីការងារ កុមារទាំងអស់ត្រូវបានខ្មែរក្រហមអនុញ្ញាតឲ្យរៀននៅក្រោមដើមឈើ ឬក្នុងព្រៃ។ ខ្មែរក្រហម មិនមានសាលារៀនសៀវភៅសិក្សាសម្រាប់កុមារទេ។ រឿងរ៉ាវដែលធ្វើឲ្យខ្ញុំតក់ស្លុតខ្លាំងបំផុត ខ្ញុំឃើញអណ្តូងមានសាកសពក្នុងភូមិប្រើសមាស។ ខ្ញុំនៅចាំថា ពេលនោះកុមារទាំងអស់ត្រូវបានហាមឃាត់មិនឲ្យទៅក្បែរអណ្តូងនោះឡើយ។ ទោះបីជាមានបម្រាមក្តី កុមារៗនៅតែចង់ដឹងអំពីអណ្តូងនោះដដែល។ កុមារប្រមាណ៤ទៅ៥នាក់រួមទាំងខ្ញុំផង បានប្រទះឃើញសាកសពដែលហើមស្អុយទុក

បោលឃ្លូវថ្ងៃពេញក្នុងអណ្តូងទឹក។ សាកសពទាំងនោះមានពាក់ឯកសណ្ឋានស៊ីវិលធម្មតាទាំងអស់ ទើបខ្ញុំយល់ថាសាកសពរបស់ប្រជាជនថ្មី ឬប្រជាជន១៧មេសា ដែលបានជម្លៀសមកតំបន់របស់ខ្ញុំ។ ទាំងនេះគឺជាទិដ្ឋភាពមួយដែលបានដិតជាប់ក្នុងអារម្មណ៍ខ្ញុំរហូតមក។

នៅឆ្នាំ១៩៧៩ កងទ័ពវៀតណាមចាប់ផ្តើមវាយលុកចូលមកប្រទេសកម្ពុជា។ ប្រជាជននៅតាមសហករណ៍ទាំងអស់ចាប់ផ្តើមរំសាយ និងរស់នៅប្រកបរបរធ្វើស្រែចម្ការទៅតាមគ្រួសាររៀងៗខ្លួន។ ទោះបីជាយ៉ាងណាប្រជាជននៅក្នុងភូមិតែងតែលួចបញ្ជូនអង្ករទៅឲ្យកងទ័ពខ្មែរក្រហមដែលកំពុងខ្វះស្បៀងនៅក្នុងព្រៃ។ ប្រជាជនត្រូវបានរៀបចំជាក្រុម នារីប្រមាណជា ៦ទៅ៧នាក់ ក្នុងមួយក្រុមក្នុងនោះក៏មានខ្ញុំម្នាក់ដែរ មានតួនាទីជញ្ជូនស្បៀងចូលព្រៃឲ្យកងទ័ពខ្មែរក្រហមដោយសម្ងាត់។

រហូតក្រោយមកឆ្នាំ១៩៨៤ គ្រួសាររបស់ខ្ញុំ និងប្រជាជនផ្សេងទៀតចាប់ផ្តើមរត់ភៀសខ្លួនចេញពីភូមិទៅរស់នៅជាមួយកងទ័ពខ្មែរក្រហមនៅក្នុងព្រៃ បន្ទាប់ពីកងទ័ពវៀតណាមចាប់ផ្តើមសង្ស័យថា ប្រជាជនបានចុះចូលជាមួយខ្មែរក្រហម។ ការភៀសខ្លួននេះ ប្រជាជនគ្មានការព្រួយបារម្ភទេ ព្រោះយើងដឹងថានៅពេលចេញពីភូមិចូលដល់ក្នុងព្រៃគឺមានសុវត្ថិភាពដោយមានកងទ័ពខ្មែរក្រហមចាំការពារ។

នៅឆ្នាំ១៩៨៧ ខ្ញុំបានរៀបការជាមួយប្តីខ្ញុំឈ្មោះ ប៉ាន សំអ៊ុន ដែលជាអតីតយោធាខ្មែរក្រហមដែរ។ ការរៀបការរបស់ខ្ញុំនៅពេលនោះគ្មានការបង្ខិតបង្ខំទេ គឺរៀបចំឡើងដោយមានចាស់ទុំជួយចាត់ចែងទៅតាមប្រពៃណី។ បន្ទាប់ពីរៀបការបានប៉ុន្មានថ្ងៃ ស្ត្រី និងកុមារទាំងអស់ត្រូវបានបញ្ជូនឲ្យទៅកាន់មូលដ្ឋានក្រោយដែលមានទីតាំងនៅលើភ្នំដងរែក ស្របពេលដែលខ្ញុំកំពុងមានផ្ទៃពោះប្រាំពីរខែ។ អំឡុងពេលធ្វើដំណើរតាមផ្លូវទៅកាន់ភ្នំដងរែកនោះដែរ ស្ត្រី និងកុមារភាគច្រើនជួបនូវការលំបាកយ៉ាងខ្លាំង ជាពិសេសសម្រាប់ស្ត្រីមានផ្ទៃពោះដូចខ្ញុំ។ ខ្ញុំគ្មានកម្លាំងសម្រាប់ធ្វើដំណើរដូចស្ត្រីឯទៀតឡើយ ដូច្នេះប្តីរបស់ខ្ញុំសម្រេចចិត្តឈប់សម្រាកដាំបាយហូបដើម្បីឲ្យ



ម៉ន យាន និងប្តីឈ្មោះ ប៉ាន សំអ៊ុន ព្រមទាំងកូនស្រីឈ្មោះ អ៊ុន វ៉ាន់ដា ក្នុងវេទិកាប្រវត្តិសាស្ត្រគ្រួសារក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (ហ៊ាន ពិសី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំអាចមានកម្លាំងបន្តដំណើរទៅមុខទៀត។ យើងដាំបាយឆ្អិនហើយមិនទាន់បានហូបផង ស្រាប់តែកងទ័ពវៀតណាមតាមមកទាន់នៅពេលនោះ។ ប្តីខ្ញុំខំប្រឹងគ្រាខ្ញុំឲ្យរត់បន្តទាំងត្រដាបត្រដួស ខណៈពេលដែលខ្ញុំស្ទើរតែដើរលែងរួចទៅហើយ។

លុះយើងធ្វើដំណើរឆ្ងាយបន្តិច ដោយឃើញសភាពខ្ញុំមិនស្រួល ប្តីរបស់ខ្ញុំបាននិយាយប្រាប់ខ្ញុំថា «ឈប់រត់ទៅ! សម្រាកសិនទៅឯង បើសិនជាយើងត្រូវស្លាប់ឲ្យស្លាប់ទៅចុះ» ទើបខ្ញុំសម្រេចចិត្តឈប់នៅត្រង់ «អណ្តូងបរ» ដែលជាឈ្មោះអណ្តូងទឹក។ យើងសម្រាកដាំបាយហូបនៅទីនោះ។ បន្ទាប់មកទើបយើងបន្តដំណើររហូតដល់ជើងភ្នំ និងបន្តឡើងទៅអាងក្បាលលាវ។ ខណៈពេលធ្វើដំណើរឡើងភ្នំប្រជាជនជាច្រើននាក់រងរបួស

និងស្លាប់ដោយសារជាន់គ្រាប់មីនដែលដាក់រាយប៉ាយនៅក្នុងផែនការក-៥។ យើងត្រូវចំណាយពេលមួយយប់ ទើបកងកម្លាំងខ្មែរក្រហមនៅខាងលើភ្នំអាចចម្លងប្រជាជនរួចពីគ្រោះថ្នាក់បាន។ ចាប់តាំងពីពេលនោះមកខ្ញុំបានបន្តទៅរស់នៅក្នុងជំរំដងទង់ ក្នុងប្រទេសថៃ។ ខ្ញុំ និងគ្រួសារបានរស់នៅទីនោះរហូត និងមានកូនចំនួនពីរនាក់ ទើបខ្ញុំបានវិលត្រឡប់មកប្រទេសខ្មែរវិញក្នុងឆ្នាំ១៩៩៨។ ក្រោយពេលកងកម្លាំងខ្មែរក្រហមធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា គឺខ្ញុំចង់ត្រឡប់ទៅស្រុកកំណើត។ ប៉ុន្តែដោយសារនៅទីនោះគ្មានរបរសម្រាប់ចិញ្ចឹមគ្រួសារ ខ្ញុំក៏សម្រេចចិត្តមករស់នៅភូមិអូររុន ក្នុងស្រុកអន្លង់វែងនេះវិញរហូតដល់បច្ចុប្បន្ន។ ជីវិតរបស់ខ្ញុំធ្លាប់វេទនាលំបាកច្រើនមកហើយដោយសារសង្គ្រាម ដូច្នេះខ្ញុំមិនចង់ឲ្យរឿងរ៉ាវក្នុងរបបខ្មែរក្រហមទាំងអស់នោះវិលត្រឡប់មកជាថ្មីឡើយ។ ជារឿយៗខ្ញុំតែងតែលើកយកពីផលលំបាកនៃជីវិតក្នុងសម័យកាលនោះឲ្យកូនបានដឹងបំណងចង់ឲ្យកូនចៅជំនាន់ក្រោយស្វែងយល់អំពីផលប៉ះពាល់ដែលទទួលរងពីរបបខ្មែរក្រហម។



ម៉ន យាន និងប្តីឈ្មោះ ប៉ាន សំអ៊ុន ព្រមទាំងកូនស្រីឈ្មោះ អ៊ុន វ៉ាន់ដា ជាមួយក្រុមស្រាវជ្រាវមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងក្នុងវេទិកាប្រវត្តិសាស្ត្រគ្រួសារ។ (ហ៊ាន ពិសី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ខាន់ លួត ៖ អតីតកម្មករកំពង់ផែកំពង់សោម ជាមួយជនជាតិចិន

**សុខ វណ្ណៈ**

*នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ របបកម្ពុជាប្រជាធិបតេយ្យបានឡើងកាន់អំណាច ហើយប្រជាជនភាគច្រើនស្គាល់ថា ជារបបខ្មែរក្រហម ឬ របប ប៉ុល ពត។ របបខ្មែរក្រហមមានកៅអីនៅអង្គការសហប្រជាជាតិពិតមែន តែរបបមួយនេះបានគាំទ្ររបបកុម្មុយនីស្ត។ នៅក្នុងរបបកម្ពុជាប្រជាធិតេយ្យមានស្ថានទូតបរទេសតិចតួចបំផុតនៅក្នុងប្រទេសកម្ពុជា។ ស្ថានទូតចិនប្រចាំនៅប្រទេសកម្ពុជាបានជួយគាំទ្ររបបខ្មែរក្រហមទាំងសម្ភារយោធា និងស្បៀងអាហាររហូតដល់ឆ្នាំ១៩៩១។*

## ពីកុមារភាព

ខ្ញុំមានស្រុកកំណើតនៅភូមិពោធិ៍ធំ ឃុំពោធិ៍អង្ក្រង ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ។ ខ្ញុំរស់នៅជាមួយឪពុកម្តាយរហូតពេញវ័យ។ ខ្ញុំមានឪពុកឈ្មោះ ឌី ណុប និងម្តាយឈ្មោះ ម៉ៅ យ៉ាន។ ឪពុកម្តាយខ្ញុំគឺជាកសិករ ។

ខ្ញុំរៀនបានត្រឹមថ្នាក់ទី១០ចាស់ នៅសាលាបឋមសិក្សាវត្តពោធិ៍។ ខ្ញុំមានបងប្អូនបង្កើតចំនួនប្រាំបីនាក់ គឺប្រុសបួននាក់ និងស្រីចំនួនបួននាក់។ នៅពេលប្រទេសជាតិធ្លាក់ចូលទៅក្នុងសង្គ្រាមស៊ីវិល និងមានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅឆ្នាំ១៩៧០ នៅក្នុងភូមិរបស់ខ្ញុំបានក្លាយជាតំបន់រំដោះ ដែលមានចលនាខ្មែរក្រហមចូលមកឃោសនាពេញភូមិ។ ខ្ញុំមានវ័យជំទង់បានទៅចូលរួមមើលកម្លាំងប្រជាជន កម្លាំងយុវជនមួយចំនួនធ្វើមហាបាតុកម្មនៅម្តុំផ្សារអង្គតាសោម។ កាលនោះត្រូវបានទាហានខាងលោកសេនាប្រមុខ លន់ នល់ បាញ់បង្ក្រាប អ្នកចូលរួមបាតុកម្មទាំងនោះ ហើយក្រោយមកបាតុកម្មក៏ត្រូវបានរំសាយអស់។ បន្ទាប់មក មានការទម្លាក់គ្រាប់បែកពីខាងទាហាន លន់ នល់ ដែលមានការជួយគាំទ្រពីសហរដ្ឋអាមេរិច។ គ្រាប់បែកទម្លាក់នៅតាមស្រុកស្រែចម្ការ បានធ្វើឲ្យប្រជាជនជួបគ្រោះថ្នាក់ដល់អាយុជីវិត និងធ្វើឲ្យកូនចៅអ្នកស្រុករស់នៅតាមជនបទមានកំហឹងឈឺចាប់ និងរួមកម្លាំងគ្នាចូលធ្វើយោធាខាងប្រជាជាតិក្រោយមកទើបបានដឹងថាជាខ្មែរក្រហម។



ខាន់ លួត (សួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

## ជីវិតជាយោធាខ្មែរក្រហម

នៅខែកុម្ភៈ ឆ្នាំ១៩៧៤ ខ្ញុំបានស្ម័គ្រចិត្ត ចូលធ្វើយោធាខ្មែរក្រហមជាមួយមិត្តភក្តិនៅក្នុងភូមិតាមរយៈការឃោសនារបស់ខ្មែរក្រហម។ ដំបូងខ្ញុំបានចូលធ្វើជាយោធាស្រុកបរសេដ្ឋបានរយៈពេលខ្លី បន្ទាប់មកក៏ឡើងជាយោធាតំបន់ ៣៣ ។ ខ្ញុំនៅក្មេងអង្គការចាត់តាំងឲ្យខ្ញុំរែកបាយយកទៅឲ្យយុទ្ធជនដែលជាបងៗនៅសមរភូមិលង្វែក នៅផ្លូវជាតិលេខ៥។ កាលនោះប្រធានវរសេនាធំលេខ២១ ឈ្មោះ តាមៀញ តាស្រល់ នៅក្នុងកងពលទី១។ ក្រោយមកទៀត ខ្ញុំបានឡើងវាយនៅក្នុងសមរភូមិផ្ទាល់។ អង្គភាពពេលនោះមានបីគដែលមួយអង្គភាពមានចំនួនយោធាប្រហែលជា៣០០ទៅ៤០០នាក់ ឡើងទៅវាយតាមសមរភូមិជាមួយទាហានលន់ នល់ នៅម្តុំជីទាវម៉ោ ឆកឈើនាង រហូតដល់ចោមចៅខាងលិចផ្លូវរទេះភ្លើងសំដៅមកទីក្រុងភ្នំពេញ។ នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ អង្គភាពខ្ញុំមិនបានវាយចូលទីក្រុងភ្នំពេញដោយផ្ទាល់ទេ គឺអង្គការបានចាត់តាំងឲ្យមកវាយនៅម្តុំដោះកញ្ជរតាមផ្លូវជាតិលេខ៤ ខាងលិចត្រែងត្រយឹងរហូតដល់វាលវិញ បន្ទាប់មកខ្ញុំបានឡើងជិះរថយន្តមកក្រុងកំពង់សោមតែម្តង។

## ជីវិតក្រោយចប់សង្គ្រាម

នៅឆ្នាំ១៩៧៥ ខ្ញុំបានមកដល់ក្រុងកំពង់សោម និងបានចូលធ្វើការងារនៅក្រសួងពាណិជ្ជកម្ម ផ្នែកកម្មករលីសែងនៅផែ។ ពេលទៅដល់កំពង់សោមមុនដំបូង ខ្ញុំបានឃើញប្រជាជនកំពុងធ្វើដំណើរចេញពីក្រុងហើយប្រជាជនទាំងនោះនាំគ្នាដេកតាមផ្លូវថ្នល់មិនដឹងថា ទៅកន្លែងណាខ្លះទេ។ ពេលនោះនៅក្នុងក្រុងកំពង់សោមមានតែកម្មាភិបាលខ្មែរក្រហមយោធា និងកម្មកររស់នៅ។ អង្គភាពខ្ញុំមួយអនុសេនាតូចមានគ្នាជាង៣០នាក់ ត្រូវសម្រាកនៅអូរត្រេះមួយសប្តាហ៍ ទើបអង្គការចាត់តាំងឲ្យមកលីសែងនៅកំពង់ផែដែលមានអ្នកក្តាប់កំពង់ផែឈ្មោះ តាគ្រិន។ កប៉ាល់មុនដំបូងដែលខ្ញុំបានឃើញនោះគឺកប៉ាល់របស់ប្រទេសចិន ព្រោះមានទាំងអក្សរចិន និងជនជាតិចិននិយាយភាសាចិន។ កាលនោះខ្ញុំស្តាប់មិនបានទេ តែប្រធានវរសេនាតូចឈ្មោះ ម៉ុន ជាអ្នកនិយាយប្រាប់ថា កប៉ាល់មួយគ្រឿងអាចដឹកទំនិញបាន ១០.០០០តោន ហើយកប៉ាល់ខ្លះអាចដឹកបាន៨០០០តោន មកជួយប្រទេសកម្ពុជាដែលជាមិត្ត។ ជំនួយដំបូងរបស់ប្រទេសចិនដែលខ្ញុំបានលីសែងរួមមាន អង្ករ កំណាល់រទេះភ្លើង និងដងរែកសម្រាប់លើកដីលើកទំនប់។ អីវ៉ាន់ទាំងនោះត្រូវដឹកជញ្ជូនតាមរថយន្តបន្តមកដាក់នៅឃ្លាំងខាងលើរួចហើយរថយន្តមកដឹកបន្តទៅតំបន់ និងភូមិភាគផ្សេងៗ។ កប៉ាល់ប្រទេសចិនបានដឹកអីវ៉ាន់ចេញពីប្រទេសកម្ពុជាវិញរួមមាន៖ គ្រាប់ឈូក, សំឡីកប្បាស គ, ដើមស្រល់ខ្នាតធំៗ, កៅស៊ូ, គ្រាប់សរ៉ែង, ដូងទុំ និងឆ្អឹងសត្វជាដើម។ កម្មករមានទាំងយុវជន យុវនារីរាប់រយរាប់ពាន់នាក់សរុបទាំងអង្គភាពផ្សេងៗ។ នៅពេលនោះកម្មករធ្វើការងារនៅក្រុងកំពង់សោមទោះបីលំបាកបន្តិចតែមានអាហារហូបចុកគ្រប់គ្រាន់។ នៅកំពង់ផែ អង្គការហាមមិនឲ្យជក់បារីទេ ប៉ុន្តែមានជនជាតិចិនលួចលាក់ឲ្យកម្មករខ្មែរម្តងមួយសុងពីរសុង។ ខ្ញុំធ្វើការងារជាកម្មករកំពង់ផែបានប្រហែលបួនប្រាំថ្ងៃក្រោយមកឃើញមានព្រឹត្តិការណ៍ថ្មីកើតឡើងបន្ទាប់ពីចប់សង្គ្រាម ៥ឆ្នាំ។ ខ្ញុំបានឃើញដោយផ្ទាល់ គឺមានយន្តអាមេរិចមកទម្លាក់គ្រាប់បែកនៅផែកំពង់សោម។ ពេលនោះខ្ញុំដឹងថា មានជនជាតិចិនចំនួនពីរនាក់ត្រូវរបួស និងបានដឹងថាមានការទម្លាក់នៅតាមកោះមួយចំនួនទៀត ដោយមានឆេះឃ្លាំងនៅកំពង់សោមមួយកន្លែង ។ យន្តហោះទាំងនោះបានទម្លាក់ចន្លោះពីម៉ោង៩ព្រឹកនិងចន្លោះម៉ោង១២ថ្ងៃត្រង់។ កាលនោះខ្ញុំមិនមែននៅខាងយោធាមិនសូវរឿងរ៉ាវពីការទម្លាក់ទេ គ្រាន់តែឮតាមគ្នាថា មកពីយោធាខ្មែរក្រហមទៅចាប់កប៉ាល់ដឹកទំនិញរបស់អាមេរិចដែលបានធ្វើដំណើរឆ្លងកាត់តាមផ្លូវសមុទ្រអន្តរជាតិជិតកោះពូលូវៃ។

នៅឆ្នាំ១៩៧៧ ខ្ញុំបានឃើញកប៉ាល់ប្រទេសចិន និងកប៉ាល់ចិនហុងកុងចូលផែកំពង់សោមកាន់តែច្រើនឡើងៗ។ កប៉ាល់ទាំងនោះដឹកទំនិញចូលមក រួមមាន ដែក និងគ្រឿងសំណង់ បន្ទាប់មកទៀតឃើញមានការនាំចូលសម្ភារយោធាកាន់តែច្រើនឡើងៗ មានទាំងរថយន្តថ្មីៗរាប់រយគ្រឿង រថក្រោះជាច្រើនគ្រឿង កាំភ្លើងតូចធំគ្រប់ប្រភេទ និងចុងក្រោយឃើញមានទាំងគ្រឿងសម្រាប់យន្តហោះដឹកមកទាំងឡាំងធំៗ។ ពេលនោះ ខាងកំពង់ផែប្រើរថយន្តស្ទូចចេញពីកប៉ាល់ដោយលែងប្រើកម្លាំងកម្មករលីសែង ហើយមកប្រើសុទ្ធតែគ្រឿងចក្របញ្ចូរវិញ។ កម្មករគ្រាន់ជួយរៀបចំដាក់បញ្ចូលឃ្លាំងប៉ុណ្ណោះ ដើម្បីរៀបចំដាក់ក្នុងទូររទេះភ្លើង និង ទំនិញមួយចំនួនធំដឹកតាមរថយន្តមកទីក្រុងភ្នំពេញ។

នៅអំឡុងឆ្នាំ១៩៧៧ ដដែល ខ្ញុំរួមទាំងអង្គភាពមួយអនុសេនាតូចមានគ្នា៣៦នាក់ អង្គការចាត់តាំងឲ្យមកធ្វើការងារនៅរោងចក្រប្រេងកាតជាមួយជនជាតិចិនវិញ។ ខ្ញុំបានដឹងថា ជនជាតិចិនមានច្រើនរាប់រយនាក់សុទ្ធជាអ្នកជំនាញបច្ចេកទេស ស្នាក់នៅកន្លែងផ្សេងពីកម្មករខ្មែរ។ នៅវេលាម៉ោង៧ព្រឹក ជនជាតិចិនទាំងនោះជិះរថយន្តក្រុងមកធ្វើការ ហើយនៅពេលល្ងាចបានត្រឡប់ទៅវិញ។ ខ្ញុំនៅចាំឈ្មោះជនជាតិចិនពីរនាក់ទីមួយឈ្មោះ ឡោសៀ និងទីពីរ ឈ្មោះ ឡោ ជីង។ ជនជាតិចិនទាំងនោះមានវិន័យណាស់និងមិនស្រែកឡូឡាទេ។ ខ្ញុំបានដឹងថា ជនជាតិចិនទាំងនោះមកប្រទេសកម្ពុជាធ្វើការនៅតាមគម្រោងជាច្រើនរួមមានដូចជា សាងសង់អគារ សាងសង់កំពង់ផែ សាងសង់ស្ពានថ្នល់ ជាពិសេស ព្រលានយន្តហោះ។

នៅចុងឆ្នាំ១៩៧៨ ប្រទេសកម្ពុជាមានសង្គ្រាមជាមួយប្រទេសវៀតណាមកាន់តែតានតឹងឡើងជារៀងរាល់ថ្ងៃ។ ពេលនោះកម្មករកំពង់ផែកំពង់សោមជាច្រើនត្រូវបានអង្គការជ្រើសរើសមកធ្វើជាយោធាវិញ រួមទាំងរូបខ្ញុំផងដែរ។ ខ្ញុំបានឡើងជិះរថយន្តចាកចេញពីក្រុងកំពង់សោមតាមផ្លូវជាតិលេខ ៤ ហើយឆ្លងកាត់ទីក្រុងភ្នំពេញសំដៅទៅខេត្តកំពង់ចាម។ ខ្ញុំបានទៅដល់ស្រុកអូររាំងឪ និងស្រុកមេមត់ដោយមិនទាន់បានទៅដល់ព្រំដែនផង ក៏ឮដំណឹងថា កងទ័ពវៀតណាមបានវាយចូលដល់ទីក្រុងភ្នំពេញ។

## ព្រឹត្តិការណ៍ថ្ងៃទី ៧ ខែមករា ឆ្នាំ១៩៧៩

នៅពេលកងទ័ពវៀតណាមវាយចូលដល់ប្រទេសកម្ពុជាភ្លាម អង្គភាពរបស់ខ្ញុំបើករថយន្តចេញពីព្រំដែនមកដល់ស្រុកចម្ការលើក៏ឈប់រថយន្ត ហើយនាំគ្នាចុះរត់ចូលព្រៃ ដោយដៃកាន់កាំភ្លើងជាប់ជានិច្ច។ ជួនពេលខ្លះយើងបានបាញ់តបតជាមួយកងទ័ពវៀតណាមថែមទៀត។ ពេលខ្លះខ្ញុំត្រូវហែលឆ្លងទន្លេមេគង្គ រួចបន្តឡើងមកស្រុកខត្តុង្គដោយដើរកាត់បន្ទាយលង្វែកឆ្លងទៅសាលាលេខ ៥ ។ ខ្ញុំបានចូលទៅព្រៃគ្រី ក្នុងទឹកដីខេត្តកំពង់ឆ្នាំង។

ខ្ញុំបានសម្រេចចិត្តនៅជាមួយយោធាខ្មែរក្រហមដដែលដោយមិនហ៊ានត្រឡប់ទៅរកស្រុកកំណើតដើម្បីជួបឪពុកម្ដាយបងប្អូនទេ។ ដោយសារខ្លាចវត្តមានកងទ័ពវៀតណាមចាប់យកទៅសម្លាប់ និងធ្វើទារុណកម្ម។ ខ្ញុំបានរត់ជាមួយអង្គភាពវរសេនាតូចមានប្រហែល ៣៦ នាក់ លាយឡំជាមួយកម្មករផ្សេងៗជាច្រើនទៀត។ នៅពេលរត់ចូលព្រៃ យើងក៏ចាប់ផ្ដើមបែកគ្នាដែរ ដោយនៅសល់សមាជិកកាន់តែតិច។ ខ្ញុំស្នាក់នៅក្នុងព្រៃបានពីរយប់ក៏ចេញដំណើរទៅ ត្បែងខ្ពស់ ភូមិត្រពាំងម្ទេស ត្រពាំងព្រីងក្រាំងស្រម៉រ ត្រៀមវាយជាមួយកងទ័ពវៀតណាមទៀតដោយអង្គភាពរបស់ខ្ញុំដឹកនាំដោយ តាសារឿន។ អង្គភាពរបស់ខ្ញុំវាយបណ្ដើរធ្វើដំណើរទៅដល់ទឹកដីខេត្តពោធិ៍សាត់ និងបានជួបតាឡូន។ យើងបាននាំគ្នាធ្វើដំណើរបន្តទៅមុខទៀត។

នៅខែមិថុនា ឆ្នាំ១៩៧៩ ខ្ញុំបានរស់នៅក្នុងព្រៃ។ ខ្ញុំចាប់ផ្ដើមជួបការលំបាក និងវេទនាខ្លាំង។ ខ្ញុំឃើញយុវនារីប្រាំពីរនាក់អត់បាយ និងបានហូបនាំគ្នាដើរដឹកក្ដួចហូប មានអ្នកខ្លះអស់កម្លាំងផង និងពុលផងក៏ស្លាប់នៅក្នុងព្រៃ។ សាកសពអ្នកទាំងនោះគ្មានអ្នកកប់ឡើយ ព្រោះម្នាក់ៗយកតែរួចខ្លួនប៉ុណ្ណោះ ទោះបងប្អូនក៏មិនអាចជួយគ្នាបានដែរ។ ខ្ញុំបានធ្វើដំណើរបន្តទៀតមានប្រុសមានស្រី។ ខ្ញុំដើរសំដៅទៅព្រំដែនរហូតដល់ផ្លូវបំបែកថ្មបាំងទៅខេត្តកោះកុង។ បន្ទាប់មក យើងបន្តទៅដល់ត្រពាំងរូងទើបបានជួបប្រធានកងពលឈ្មោះ តាសេង។

នៅអំឡុងឆ្នាំ១៩៧៩ ដដែលមានយុវជនយុវនារីជាច្រើនរួមទាំងរូបខ្ញុំផង ស្ម័គ្រចិត្តចូលរួមជាមួយចលនាខ្មែរក្រហមម្តងទៀត ព្រោះខ្ញុំនៅជឿលើខ្មែរក្រហមដែលអប់រំមនោគមន៍វិជ្ជាច្បាស់លាស់។ នៅជំនាន់ខ្មែរក្រហមទោះបីខ្ញុំបែកបាក់ម៉ែឪបងប្អូន ប៉ុន្តែខ្ញុំរស់នៅមានអាហារហូបចុកគ្រប់គ្រាន់ ហើយមេដឹកនាំជំនាន់ខ្មែរក្រហមអប់រំមនោគមន៍វិជ្ជាថា កងទ័ពវៀតណាមចូលមកឈ្លានពានទឹកដីកម្ពុជា។ ខ្ញុំមានការឈឺចាប់ទើបស្ម័គ្រចិត្តចូលធ្វើយោធានៅក្នុងកងពលទី២ ជាមួយតាសេង នៅតំបន់ថ្មបាំង ត្រពាំងរូង ក្នុងទឹកដីខេត្តពោធិ៍សាត់ និងខេត្តកោះកុង។

នៅឆ្នាំ១៩៨១ ខ្ញុំបានផ្លាស់មកនៅជាមួយប្រធានកងពលឈ្មោះ តាយ៉ង់ ប្រធានវរសេនាតូច បងនួន បងឆន។ ខ្ញុំសមរភូមិវាយមួយកងទ័ពវៀតណាម និងកងទ័ពរដ្ឋាភិបាលកម្ពុជានៅម្តុំភ្នំសំព័រ អូរសំឡាញ និងត្បូងក្រពើពីរ។ សង្គ្រាមបានធ្វើឲ្យប្រទេសជាខ្ទេចខ្ទីគ្មានការអភិវឌ្ឍន៍ និងធ្វើឲ្យមនុស្សស្លាប់ជារៀងរាល់ថ្ងៃ។ សង្គ្រាមបានបង្កឲ្យស្លាប់ និងរបួសទាំងកងទ័ពទាំងប្រជាជនស៊ីវិល ជាពិសេសប្រពន្ធកងទ័ពខ្មែរក្រហមដែលរស់នៅជាមួយប្តីនៅសមរភូមិតាមជាយព្រំដែនខ្មែរ ថៃ។

## ព្រឹត្តិការណ៍ក្រោយសមាហរណកម្ម

នៅឆ្នាំ១៩៩៨ មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមួយចំនួនរួមទាំងប្រធានកងពលមានបញ្ហាផ្ទៃក្នុងកាន់តែធ្ងន់ធ្ងរមិនទុកចិត្តគ្នារហូតដល់មានមេដឹកនាំខ្មែរក្រហមមួយចំនួនបាត់ខ្លួនថែមទៀត។ នៅអំឡុងឆ្នាំ១៩៩៨ មេដឹកនាំខ្មែរក្រហមមួយចំនួនធំ និងប្រធានកងពលបានដឹងពីគោលនយោបាយឈ្នះឈ្នះ របស់រាជរដ្ឋាភិបាលកម្ពុជា ដោយអ្នកណាមានតួនាទី និងទ្រព្យសម្បត្តិផ្ទាល់ខ្លួនគឺនៅរក្សាទុកដដែល ទើបចលនាខ្មែរក្រហមបានស្ម័គ្រចិត្តយល់ព្រមទាំងថ្នាក់ដឹកនាំជាន់ខ្ពស់ និងនាយទាហាន។ ចាប់ពីពេលនោះទើបប្រទេសជាតិទាំងមូលបានសុខសប្បាយ។

សព្វថ្ងៃនេះ ខ្ញុំមានអាយុ៦៣ឆ្នាំ មានប្រពន្ធឈ្មោះសៀង បូរ មានកូនចំនួន ៤ នាក់ ក្នុងនោះស្រី១ នាក់ប្រកបមុខរបរធ្វើស្រែចម្ការ នៅឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង។ សព្វថ្ងៃ ចៅៗរបស់បានរៀនសូត្រ ប្រទេសមានសុខសន្តិភាព លែងមានសង្គ្រាមដូចកាលជំនាន់មុន។ ខ្ញុំមានពេលវេលាគ្រប់គ្រាន់ទៅលេងស្រុកកំណើត និងជួបជុំឪពុកម្តាយបងប្អូន។



ទូកនេសាទរបស់ខ្មែរក្រហមនៅកំពង់សោម ក្នុងឆ្នាំ១៩៧៨។ (ហ៊ុនណា បឺយស្ត្រម/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# រស់ ភិរុណ៖ អតីតសន្តិសុខទួលច្រេស នៅស្រុកសំរោង ខេត្តស្វាយរៀង

*រី លក្ខិណា*

ខ្ញុំឈ្មោះ រស់ ភិរុណ អាយុ៦៣ឆ្នាំ។ ខ្ញុំមានស្រុកកំណើតនៅភូមិគោកស្រម៉រ ឃុំសង្កែ ស្រុករំដួល ខេត្តស្វាយរៀង។ សព្វថ្ងៃខ្ញុំរស់នៅភូមិព្រៃម្នាស់ ឃុំព្រៃឈរ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ប្រពន្ធរបស់ខ្ញុំឈ្មោះ អ៊ួង សុខុម។ ខ្ញុំមានកូនចំនួនពីរនាក់ ប្រុសមួយនាក់ និងស្រីមួយនាក់។ ឪពុករបស់ខ្ញុំឈ្មោះ រស់ ជៀក គឺជាមេឃុំសង្កែ។ ឪពុករបស់ខ្ញុំបានយកនារីពេទ្យម្នាក់មកធ្វើជាប្រពន្ធ កាលពីឆ្នាំ១៩៧៣។ ក្រោយមកដោយសារឪពុករបស់ខ្ញុំខ្លាចខ្មែរក្រហមសម្លាប់ គាត់បានភៀសខ្លួនទៅរស់នៅទីរួមខេត្តស្វាយរៀង ដែលគ្រប់គ្រងដោយកងទ័ព លន់ នល់។ នៅឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះ ឪពុករបស់ខ្ញុំក៏ត្រូវខ្មែរក្រហមយកទៅសម្លាប់នៅវត្តកំពង់អំពិល។ ចំណែកម្តាយរបស់ខ្ញុំឈ្មោះ ថាន់ សន កូនបង្កើតទាំងអស់ចំនួន១០នាក់ គឺស្រីចំនួនប្រាំនាក់ និងប្រុសចំនួនប្រាំនាក់។

ខ្ញុំបានចូលរៀននៅអាយុ៧ឆ្នាំ។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី៧ «សង្គមចាស់» នៅសាលាបឋមសិក្សាកំពង់ចក។ ខ្ញុំឈប់រៀននៅពេលកើតមានរដ្ឋប្រហារនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ព្រោះពេលនោះសង្គ្រាមចាប់ផ្តើមកើតឡើង ហើយសាលារៀនត្រូវបានបិទទ្វារ។ បន្ទាប់ពីឈប់រៀនខ្ញុំនៅផ្ទះជួយធ្វើស្រែឪពុកម្តាយ។ ភូមិដែលខ្ញុំរស់នៅគឺជាតំបន់ប្រទាញប្រទង់ព្រោះនៅភាគខាងត្បូងជាតំបន់ លន់ នល់ គ្រប់គ្រង និងភាគខាងជើងជាតំបន់រំដោះរបស់ខ្មែរក្រហម។ កងទ័ព លន់ នល់ បានទទួលជំនួយពីខាងកងទ័ពធីវគី ឬ វៀតណាមខាងត្បូង ចំណែកខាងខ្មែរក្រហមទទួលជំនួយពីកងទ័ពវៀតណាមខាងជើង។



រស់ ភិរុណ អាយុ៦៣ឆ្នាំ សព្វថ្ងៃខ្ញុំរស់នៅភូមិព្រៃម្នាស់ ឃុំព្រៃឈរ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

តាហ្វួយ គឺជាប្រធានយោធាស្រុកសំរោង (ក្រោយពេលខ្មែរក្រហមចូលមកគ្រប់គ្រង ស្រុករំដួលត្រូវបានប្តូរឈ្មោះទៅជាស្រុកសំរោង) ចំណែកគណៈស្រុកសំរោងឈ្មោះ ប៉ូ លីវណ្ណ, ប្រធានកងឈ្លបឈ្មោះ ហាំ សារ៉ន, អនុកងឈ្លប ឈ្មោះ ឌឹក និង សៅ សារ៉ែត គឺជាប្រធានសន្តិសុខស្រុក។ ស្រុកសំរោងស្ថិតនៅក្នុងតំបន់២៣ ហើយមន្ទីរតំបន់២៣ស្ថិតនៅស្រុករមាសហែក។ គណៈតំបន់២៣ ឈ្មោះ ចាន់ សុវណ្ណ។

ក្រោយពីមានការអំពាវនាវពីសម្តេចព្រះ នរោត្តម សីហនុឲ្យកូនចៅចូលព្រៃម៉ាគី។ នៅចុងឆ្នាំ១៩៧០ ខ្ញុំចូលធ្វើជាកងឈ្លប។ ពេលនោះមានអ្នកចូលរួមដំណាលខ្ញុំ

ចំនួន ៣០នាក់ ដែលមានឈ្មោះ រ៉ន គឺជាប្រធានដឹកនាំ។ ពេលដែលចូលកងឈ្លបដំបូង ខ្ញុំហាត់លូន ក្រាប បាញ់កាំភ្លើង និងដោះកាំភ្លើងជាដើម។ ខ្ញុំមិនបានហាត់រៀនច្រើនទេ ព្រោះទាហានធីវគី និងមានរថក្រោះចូលមកអុកឡុកម្តងម្កាល។ នៅវេលាម៉ោងប្រាំពីរយប់ មានការទម្លាក់គ្រាប់បែកនៅតាមមាត់ព្រែកដែលមានព្រៃគុម្ពឬស្សីដុះជុំជិតព្រោះសង្ស័យថា យោធាខ្មែរក្រហមលាក់ខ្លួននៅទីនោះ។ មិនតែប៉ុណ្ណោះនៅភូមិខ្វាងាប់ជាប់នឹងភូមិរបស់ខ្ញុំ ក៏មានការទម្លាក់គ្រាប់បែកជាច្រើនដែរ។ ប៉ុន្តែសំណាងល្អមិនមានប្រជាជនណាស្លាប់ទេ មានតែអ្នករងរបួស និងឆេះផ្ទះប្រជាជនមួយចំនួន។

នៅតំបន់ ២៣ មានចំនួន ៤ វរសេនាតូច។ ចំណែកយោធាស្រុកសំរោងមានមួយវរសេនាតូច ដែលក្នុងមួយវរសេនាតូចមាន ៣-គ ។ អង្គភាពបានចាត់ចែង ៣-គ ថ្មើរជើង និង១-គទៀតស៊ើបការណ៍ សរុបមាន ៤-គ។ នៅពេលមានការប្រយុទ្ធគ្នាទ្រង់ទ្រាយធំ យោធាស្រុកបានមកជួយយោធាតំបន់។

នៅចុងឆ្នាំ១៩៧២ ខ្ញុំចេញមកស្រុកសំរោងដើម្បីធ្វើជាកងការពាររបស់ សៅ សារ៉េត។ ការងាររបស់ខ្ញុំគឺជិះម៉ូតូទៅតាមភូមិស៊ើបការណ៍។ ខ្ញុំតែងតែឌុប សៅ សារ៉េត ទៅតាមភូមិ។ បន្ទាប់មកបានរយៈពេលបីខែខ្ញុំផ្លាស់មកតំបន់វិញ។ នៅដើមឆ្នាំ១៩៧៣ ខ្ញុំបានធ្វើជាកងកាពាររបស់ ចាន់ សុវណ្ណ។ ខ្ញុំធ្វើជាកងការពារបានរយៈពេលបីខែក៏ផ្លាស់មកនៅផ្នែកសន្តិសុខស្រុក វត្តទួលច្រេសវិញ។ នៅឆ្នាំ១៩៧៦ ខ្ញុំផ្លាស់ពីមន្ទីរសន្តិសុខវត្តទួលច្រេស ទៅនៅមន្ទីរសន្តិសុខពពកវិល ដែលមានឈ្មោះ តាសារ៉េត គឺជាអនុ, ឈ្មោះ ដាន គឺជាអ្នកក្តាប់រួមមន្ទីរសន្តិសុខ រួមនឹងការអប់រំ និង តាឈុំ។ ។ ខ្ញុំនៅជាមួយ តាដាន។ តាដាន ធ្លាប់តាមដានសកម្មភាពខ្ញុំដែរដោយសារឪពុករបស់ខ្ញុំមានប្រវត្តិរូបមិនល្អ។ ខ្ញុំមិនប្រចាំការនៅមន្ទីរសន្តិសុខទេ គឺខ្ញុំតែងតែនៅធ្វើការជាមួយ តាដាន ទៅតាមឃុំ ក្នុងស្រុកសំរោង។

មន្ទីរសន្តិសុខវត្តទួលច្រេស ស្ថិតនៅខាងត្បូងវត្តទួលច្រេសនិងមានចម្ងាយ៣០០ម៉ែត្រពីវត្តទួលច្រេស។ នៅទីនោះមានរោងមួយសង់អំពីឈើប្រក់ស្លឹកត្នោត ដែលមានទទឹងប្រាំមួយម៉ែត្រ បណ្តោយដប់បីម៉ែត្រ។ ជញ្ជាំងធ្វើពីដីឥដ្ឋដាន់លាយជាមួយចំបើង។ អ្នកទោសត្រូវបានដាក់ខ្នោះជាប់នឹងគ្រែឬស្សី និងដេកតម្រៀបក្បាលកៀកៗគ្នាបែរទៅទិសខាងលិច ។ នៅក្នុងរោងនោះអាចដាក់អ្នកទោសបានចំនួន២០នាក់ ។ អ្នកទោសទាំងអស់ត្រូវបានដាក់តែខ្នោះជើងតែប៉ុណ្ណោះ។ អ្នកទោសដេកលើគ្រែរនាបឬស្សីសង់ផុតពីដីកម្ពស់ប្រាំមួយតឹក។ នៅក្នុងមន្ទីរសន្តិសុខ ត្រូវបានបែងចែកជាពីរផ្នែក គឺពន្ធនាគារ និងកន្លែងអប់រំ។ កន្លែងអប់រំមានផ្ទះធំ។ ទីតាំងកន្លែងអប់រំស្ថិតនៅខាងកើតពន្ធនាគារចម្ងាយ៣០០ម៉ែត្រ។ អ្នកទោសភាគច្រើនគឺជាគ្រូបង្រៀន ពេទ្យ ទាហាន ហើយកន្លែងអប់រំអាចដាក់អ្នកទោសបានរហូតដល់ ៧០នាក់ ។ នៅពេលព្រឹកគឺឈ្លបបញ្ចេញអ្នកទោសឲ្យធ្វើការ និងដាំត្រកួនរហូតដល់ល្ងាច ទើបឲ្យអ្នកទោសទៅកន្លែងអប់រំវិញដោយឈ្លបដើរតាមក្រោយ។ ក្រុមអ្នកសួរចម្លើយ មានឈ្មោះ រ៉េន, សួន និង សូដាន។



ព្រះវិហារវត្តសង្កែ ក្នុងឃុំសង្កែ ស្រុករំដួល ខេត្តស្វាយរៀង។



(ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ស្តូបតម្កល់អដ្ឋិធាតុជនរងគ្រោះ នៅវត្តកំពង់អំពិល ក្នុងស្រុករំដួល ខេត្តស្វាយរៀង។
(ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រុមចាប់អ្នកទោសមានខ្ញុំ, តាផាន, លី និង សាអែម។

ខ្ញុំមានតួនាទីទៅដឹកអ្នកទោស នៅពេលដែលក្រុមសម្ងាត់របស់ តាផាន រាយការណ៍មក។ តាផាន បញ្ជូនខ្ញុំឲ្យទៅដឹកអ្នកទោសយកមកដាក់មន្ទីរសន្តិសុខ។ ពេលទៅដល់ដំបូង ឈ្លបក្ដួងអ្នកទោសឲ្យលើកដៃ បន្ទាប់មកឲ្យដាក់ដៃទៅក្រោយ រួចហើយឈ្លបយកក្រមា ឬខ្សែត្នោតចងស្ទាបសេកអ្នកទោសនោះ។ ខ្ញុំបានដឹកអ្នកទោសយកមកមន្ទីរសន្តិសុខ។ កាំភ្លើងរបស់ខ្ញុំ មានដូចជា កាំភ្លើងអ៊ីមស៊ី, សេកាសេ និងកាំភ្លើងអាកា។ ខ្ញុំធ្លាប់បានទៅចាប់មនុស្សប្រហែលបីទៅបួននាក់ដែរ។ ខ្ញុំមិនដឹងថាអ្នកដែលខ្ញុំចាប់ប្រព្រឹត្តកំហុសអ្វីទេ។ តាផាន បញ្ជូនឲ្យខ្ញុំទៅចាប់អ្នកទោសនោះមក។ ទោះបីខ្ញុំស្គាល់អ្នកទោសដែលខ្ញុំទៅចាប់ ឬមិនស្គាល់ក៏ខ្ញុំមិនហ៊ាននិយាយជាមួយអ្នកទោសនោះដែរ។ ពេលដែលខ្ញុំដឹកអ្នកទោសមកដល់មន្ទីរសន្តិសុខ ក្រុមខ្ញុំត្រូវប្រគល់អ្នកទោសទៅឲ្យក្រុមអ្នកយាម។ អ្នកយាមបានដឹកដៃអ្នកទោសចូលទៅក្នុងមន្ទីរសន្តិសុខ។ ភាគច្រើនពេលដែលដឹកអ្នកទោសមក ខ្ញុំប្រគល់ឲ្យទៅ វ៉ែន។

ចំពោះអ្នកទោសធ្ងន់ ពេលដែលសួរចម្លើយរួច គឺកងឈ្លបយកទៅសម្លាប់។ បើអ្នកទោសស្រាល សួរចម្លើយរួចយកទៅដាក់កន្លែងអប់រំ ហើយក្រោយមកឈ្លបក៏ដោះលែងឲ្យទៅផ្ទះវិញ។ ទីតាំងសម្លាប់គឺនៅវត្តកំពង់អំពិល ដែលមានចម្ងាយបីទៅបួនគីឡូម៉ែត្រ ពីវត្តទួលច្រេស។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលដែលអង្គការជម្លៀសប្រជាជនមកពីភ្នំពេញ ប្រជាជនមួយចំនួនត្រឡប់មកស្រុកកំណើតវិញ។ ឪពុកខ្ញុំ និងម្ដាយចុងធ្លាប់ធ្វើជាពេទ្យក៏បានវិលត្រឡប់មកស្រុកកំណើតដែរ។ ពេលមកដល់ អង្គការបានស្រាវជ្រាវរកន្ត្រីរាជការ ប៉ូលីស គ្រូបង្រៀន ទាហាន យកទៅដាក់នៅវត្តសង្កែ។ នៅពេលដែលខ្ញុំទៅ



អដ្ឋិធាតុជនរងគ្រោះ នៅវត្តកំពង់អំពិល ក្នុងស្រុករំដួល ខេត្តស្វាយរៀង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ដល់វត្តសង្កែ ខ្ញុំបានជួបឪពុករបស់ខ្ញុំ។ ខ្ញុំនិយាយជាមួយឪពុកខ្ញុំបានតែពីរបីម៉ាត់ប៉ុណ្ណោះ។ ខ្ញុំធ្លាប់ឮខ្មែរក្រហមឃោសនាប្រាប់ប្រជាជនថា បើនរណាពាក់សក្តិប៉ុន្មានសូមឲ្យសម្តែងការស្មោះត្រង់ កុំលាក់លៀម។ បើមានតួនាទីអ្វី ខ្មែរក្រហមបញ្ជូនឲ្យទៅធ្វើការងារកន្លែងដដែលវិញ។ ផ្ទុយទៅវិញអ្នកដែលសារភាពថា ខ្លួនធ្លាប់ធ្វើការងារជារដ្ឋការ ឬមន្ត្រីរាជការ គឺត្រូវបានយកទៅដាក់កន្លែងអប់រំ។ ជួនកាលខ្ញុំដើរកាត់កន្លែងអប់រំ ក៏ឆ្លៀតលួចមើលឪពុកខ្ញុំ ប៉ុន្តែខ្ញុំមិនដែលឃើញឪពុកទេ។

នៅខែមិថុនា ឆ្នាំ១៩៧៥ ខ្ញុំបានសួរទៅ តាផាន «ដូចបាត់ឪខ្ញុំអត់ឃើញនៅកន្លែងអប់រំ?» តាផាន បានឆ្លើយតបមកខ្ញុំថា «ឪឯងបញ្ជូនទៅតំបន់ហើយ អត់មានទុកនៅកន្លែងអប់រំទេ អ្នកទោសធ្ងន់អង្គការបញ្ជូនទៅតំបន់»។ តាផាន ឆ្លើយបែបនេះហើយ ខ្ញុំក៏មិនហ៊ានសួរនាំបន្តទៀតដែរ។ ខ្ញុំសន្និដ្ឋានថាឪពុកខ្ញុំស្លាប់ព្រោះខ្ញុំយល់ច្បាស់អង្គការប្រាកដជាមិនលើកលែងឲ្យគាត់ទេ។

នៅចុងឆ្នាំ១៩៧៦ មានការផ្លាស់ប្តូរមន្ទីរសន្តិសុខ ដោយផ្លាស់ពីវត្តទួលព្រេស មកទីតាំងខាងកើតវត្តពពកវិល។ រយៈពេលដែលរើមន្ទីរសន្តិសុខ ប្រើរយៈពេលអស់មួយខែ។ ខ្ញុំនៅធ្វើការជាសន្តិសុខគុកពពកវិលបានរយៈពេលពីរខែ។ ការហូបចុករបស់ខ្ញុំគឺបានគ្រប់គ្រាន់មួយថ្ងៃហូបពីរពេល គឺពេលថ្ងៃត្រង់ និងពេលល្ងាច។ ពេលខ្វះកម្លាំងមិនមានគោរអូសរទេះ គឺប្រើកម្លាំងអ្នកទោសជាអ្នកអូសរទេះ។

ក្រោយមកខ្មែរក្រហមដកខ្ញុំមកធ្វើជាប្រធាន-គណៈ៣ នៅកងចល័តឃុំសង្កែ។ ការងារដែលខ្ញុំធ្វើគឺជីកប្រឡាយ ជីកព្រែក នៅរដូវប្រាំង ហើយរដូវវស្សាគឺធ្វើស្រែ។ ពេលដែលមកកងចល័តខ្ញុំត្រូវមកហូបបាយនៅសហករណ៍ ហើយខ្ញុំហូបមិនឆ្អែតទេ។ ម្ហូបភាគច្រើនគឺសម្លម្ជូរដើមចេក។

នៅឆ្នាំ១៩៧៧ ខ្ញុំត្រូវកងឈ្លបចាប់ឃុំនៅមន្ទីរសន្តិសុខពពកវិល។ មន្ទីរសន្តិសុខពពកវិល គឺមានរោងមួយសម្រាប់ដាក់អ្នកទោស និងរោងមួយខ្នងទៀតសម្រាប់អប់រំ។ ជុំវិញបរិវេណមន្ទីរសន្តិសុខប្រក់ស័ង្កសី និងមានគ្រែរនាបឫស្សី។ អ្នកទោសនៅក្នុងកន្លែងអប់រំមន្ទីរសន្តិសុខពពកវិល មានប្រហែលពី៥០នាក់ ទៅ៦០នាក់។ មូលហេតុដែលខ្ញុំជាប់នៅគុកពពកវិល គឺនៅពេលខ្ញុំជាប្រធានកងចល័ត ខ្ញុំបានទៅចូលរួមពិធីមង្គលការកូនក្រុមរបស់ខ្ញុំ។ ពេលទៅចូលរួមកម្មវិធីនោះខ្ញុំបានស្រឡាញ់នារីកងចល័ត។ ពេលដឹងដល់អង្គការនៅឃុំស្វាយផ្អែម ឈ្លបបានចាប់ខ្ញុំដាក់វត្តស្វាយផ្អែមអស់មួយយប់។ ស្អែកឡើងឈ្លបបានបញ្ជូនខ្ញុំពីសាលាឃុំស្វាយផ្អែម មកមន្ទីរសន្តិសុខស្រុកមានជ័យថ្មី បច្ចុប្បន្នស្ថិតនៅស្រុក

ស្វាយជ្រុំ ប៉ុន្តែនៅជំនាន់ខ្មែរក្រហមគឺស្ថិតនៅស្រុកមានជ័យថ្មីៗ ខ្ញុំនៅមន្ទីរសន្តិសុខស្រុកមានជ័យថ្មីបានពីរយប់ ទើបឈ្លបបញ្ជូនខ្ញុំមកស្រុករំដួលវិញៗ ឈ្លបមិនធ្វើទារុណកម្មខ្ញុំទេ គ្រាន់តែចងខ្ញុំប៉ុណ្ណោះៗ ចុងក្រោយទើបឈ្លបបញ្ជូនខ្ញុំមកដាក់នៅគុកពពកវិលៗ ពេលមកដំបូងឈ្លបបានដាក់ខ្នោះជើងខ្ញុំរយៈមួយខែ ទើបក្រុមរបស់តាផាន ហៅខ្ញុំទៅសួរចម្លើយៗ កន្លែងសួរចម្លើយមានចម្ងាយសាបសិបម៉ែត្រពីកន្លែងឃុំឃាំងៗ ខ្មែរក្រហមសង់កូនរោងតូចមួយ និងមានកៅអីឈើសម្រាប់ឲ្យខ្ញុំអង្គុយ និងមានតុមួយសម្រាប់កត់ត្រាកំណត់ហេតុៗ នៅពេលសួរចម្លើយឈ្លបមិនដាក់ខ្នោះខ្ញុំទេៗ តាផាន គឺជាអ្នកសួរចម្លើយខ្ញុំផ្ទាល់ៗ ខ្ញុំប្រាប់ការពិតទាំងអស់ដោយមិនមានការលាក់បាំងឡើយៗ តាផាន សួរតែពីរបីដងឲ្យខ្ញុំមកកន្លែងសម្រាកវិញ ហើយជើងរបស់ខ្ញុំត្រូវបានឈ្លបដាក់ខ្នោះវិញៗ រយៈពេលបីខែទើបប្រធានគុកដោះលែងខ្ញុំឲ្យត្រឡប់មកផ្ទះៗ ពេលចេញពីមន្ទីរសន្តិសុខមកវិញ ខ្ញុំនៅកងចល័តដដែល ប៉ុន្តែមិនបានធ្វើជាប្រធានទៀតទេៗ

នៅខែតុលា ឆ្នាំ១៩៧៨ ខ្ញុំរៀបការជាមួយប្រពន្ធខ្ញុំឈ្មោះ អ៊ុង សំអឿនៗ ពេលខ្ញុំរៀបការគឺមាន៨៩គូៗ ខ្ញុំរៀបការរួចហើយ មានទាហានវៀតណាមនៅតាមព្រំដែនវាយលុកចូលមកប្រទេសកម្ពុជាធ្វើឲ្យខ្មែរក្រហមជម្លៀសប្រជាជនចេញទៅតំបន់ផ្សេងៗ ខ្ញុំរួមទាំងម្តាយបងប្អូន និងគ្រួសារ ខាងប្រពន្ធរបស់ខ្ញុំ បានទៅនៅស្រុករមាសហែកៗ ខ្ញុំនៅស្រុករមាសហែកបានរយៈពេលមួយខែ ខ្មែរក្រហមក៏ជម្លៀសប្រជាជនទៅនៅខេត្តពោធិ៍សាត់ៗ យើងបានដើរកាត់ភ្នំឈើកាច់មកជិះស្រឡាងនៅអ្នកលឿងរួចហើយបន្តដំណើរទៅដល់ច្បារអំពៅៗ ពេលសម្រាកនៅច្បារអំពៅមួយយប់ ហើយខ្មែរក្រហមបានចែកក្រមាក្រឡាពណ៌ខៀវ លាយសម្នាក់មួយៗ នៅថ្ងៃបន្ទាប់ខ្ញុំជិះឡានកាត់ក្រុងភ្នំពេញមកជិះរទេះភ្លើងទៅខេត្តពោធិ៍សាត់ៗ នៅខែវិច្ឆិកា ឆ្នាំ១៩៧៨ រទេះភ្លើងបានទៅឈប់នៅខាងកើតស្រុកមោងឫស្សីក្នុងសហករណ៍ព្រៃខ្ជូត ដោយខ្ញុំធ្វើការងារប្រមូតស្រូវ និងជីកប្រឡាយៗ

នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ក្រុងនៅភ្នំពេញត្រូវបានរំដោះ ប៉ុន្តែនៅខេត្តពោធិ៍សាត់ គឺខ្មែរក្រហមនៅគ្រប់គ្រងៗ នៅថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៧៩ មានអ្នកជាំបាយដែលជាអ្នកមូលដ្ឋាននៅក្នុងសហករណ៍ព្រៃខ្ជូត បានប្រាប់ខ្ញុំថា យប់ស្អែកជាវេនរបស់ខ្ញុំដែលខ្មែរក្រហមយកទៅសម្លាប់ៗ ពេលឮដូច្នេះខ្ញុំបានរៀបផែនការរត់នៅវេលាម៉ោង ១០យប់ ជាមួយក្រុមគ្រួសាររបស់ខ្ញុំៗ នៅម៉ោង៩យប់ ខ្ញុំនៅជីកប្រឡាយដដែល រហូតដល់ម៉ោងសម្រាក ខ្ញុំក៏នាំបងប្អូន និងម្តាយខ្ញុំសរុបទាំងអស់៤០នាក់រត់គេចខ្លួនៗ ខ្ញុំមិនដឹងគោលដៅឡើយ រហូតដល់ភ្លឺយើងបានជួបឈ្លបខ្មែរក្រហមៗ ខ្មែរក្រហមដេញបាញ់ ហើយខ្ញុំបានរត់គេចខ្លួន និងបន់ស្រន់ម្តាយឪពុកឲ្យជួយដើម្បីរួចរស់ជីវិតៗ ឈ្លបបានបាញ់ក្រុមរបស់ខ្ញុំស្លាប់ ប៉ុន្តែសំណាងល្អនៅរស់ជីវិតបួននាក់ៗ សាច់ញាតិដែលជម្លៀសពីស្វាយរៀង សរុប៤០នាក់ ម្តាយខ្ញុំ ប្រពន្ធខ្ញុំដែលខ្មែរក្រហមរៀបឲ្យ និងកូនក្នុងផ្ទៃបីខែ បានស្លាប់ទាំងអស់ៗ ខ្ញុំរត់មកទិសខាងកើត ព្រោះគិតថាផ្ទះខ្ញុំនៅខាងកើតៗ ខ្ញុំចំណាយពេលបួនថ្ងៃទើបដើរមកដល់ខេត្តពោធិ៍សាត់ៗ ពេលមកដល់ពោធិ៍សាត់ ខ្ញុំក៏ចូលធ្វើជាកងឈ្លបៗ រយៈពេលពីរខែក្រោយមក ខ្ញុំបានចូលកងទ័ពវៀតណាម ហើយកងទ័ពវៀតណាមបញ្ជូនខ្ញុំមកភ្នំពេញនៅកងជីបេ ផ្នែកវរស្រាវជ្រាវ ដែលមាន តាសុខ សំរេច គឺជាប្រធានវរៗ

នៅចុងឆ្នាំ១៩៧៩ខ្ញុំបានចេញទៅរៀននៅប្រទេសវៀតណាមៗ នៅដើមឆ្នាំ១៩៨១ ខ្ញុំបានត្រឡប់មកភ្នំពេញៗ កងទ័ពដែលត្រឡប់មកពីរៀននៅប្រទេសវៀតណាមបានបែងចែកកម្លាំងតាមខេត្ត និងតាមកងពលៗ ចំណែកអង្គភាពរបស់ខ្ញុំនៅជីតដ្ឋផ្នែកអគ្គសេនាធិការៗ នៅខែមេសា ឆ្នាំ១៩៨១ កងពលធំលេខ២ នៅពេជ្រនិល បានប្តូរទៅភ្នំក្រវាញ ក្នុងខេត្តពោធិសាត់ៗ នៅពេលនោះកងពលធំលេខ២ បានខ្វះកម្លាំង ដូច្នេះក្រសួងការពារជាតិក៏បានជ្រើសរើសខ្ញុំឲ្យទៅប្រចាំនៅភ្នំក្រវាញៗ ខ្ញុំបានស្ម័គ្រចិត្តទៅនៅកងពលធំលេខ ២ នៅលើផ្លូវជាតិលេខ៥៦ ជាប់ព្រំដែនប្រទេសថៃៗ

នៅឆ្នាំ១៩៨៦ អង្គភាពយោធាបានបង្កើតភូមិភាគ៣ ទើបខ្ញុំត្រូវដកមកភូមិភាគ៣ នៅចោមចៅវិញៗ នៅឆ្នាំ២០០២ ខ្ញុំក៏រំសាយត្រឡប់មករស់នៅស្រុកកំណើតរហូតដល់សព្វថ្ងៃៗ







# ការិយាល័យ
# ព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន និស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។





មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសស្នាមក៏ដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។







តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្តនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។







ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល ៖

truthchenda.s@dccam.org

សូមអរគុណ!

# សាលក្រមសំណុំរឿង០០២/០២

## ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្តីខ្មែរក្រហម

ដារ៉ាវឌ្ឍ មេត្តា

(តពីលេខមុន)

### ៥.១.១១. យុវកក

៤០៧. *យុវជនកុម្មុយនីស្តកម្ពុជា(«យុវកក») គឺជាអង្គការស្នូលរបស់បក្សដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ថ្នាក់ដឹកនាំ ប.ក.ក.។ យុវកក គឺជា«ដៃស្តាំ» របស់ ប.ក.ក. ដែលជួយដល់រាល់ភារកិច្ចរបស់បក្សនិងជាធនធានដ៏សំខាន់របស់ «យុទ្ធជន» ទាំងអស់។ លក្ខខណ្ឌតម្រូវនានាសម្រាប់សមាជិកភាពនៃយុវកក បានបង្ហាញនៅក្នុងលក្ខណៈវិនិច្ឆ័យ ទាំង១០ សម្រាប់សមាជិកភាពនៃ ប.ក.ក.។ ទោះបីជាយ៉ាងណាក្តី យុវកកចាំបាច់ត្រូវមានអាយុចាប់ពី១៧ឆ្នាំដល់ ៣០ឆ្នាំ។ យុវកកមានភារកិច្ចក្នុងផ្នែកផ្សព្វផ្សាយការឃោសនាបក្ស អប់រំមហាជន និងលើកកម្ពស់ការការពារកម្ពុជាប្រជាធិបតេយ្យ។*

៤០៨. *ផ្អែកតាម ឌុច យុវកកគឺជាសម្ពន្ធរបស់យុវជន ប.ក.ក. ដែលមានភារកិច្ចធ្វើការជាមួយនឹងប្រជាជនបដិវត្តន៍ ដែលត្រូវបានជ្រើសរើសពីក្នុងចំណោមប្រជាជនចម្រើន។ ពួកគេត្រូវរៀបចំខ្លួននិងត្រូវទទួលខុសត្រូវទៅលើការងារមួយចំនួនមុនពេលក្លាយជាបក្ខជន។ នេះគឺជាអង្គការស្នូលមុនពេលពួកគេត្រូវបានបញ្ចូលទៅក្នុងបក្ស។*

### ៥.២ រចនាសម្ពន្ធរបស់កម្ពុជាប្រជាធិបតេយ្យ

៤០៩. *នៅក្នុងខែមេសា ឆ្នាំ១៩៧៥ នៅពេលក្រុងភ្នំពេញបានធ្លាក់ក្នុងកណ្តាប់ដៃរបស់កងកម្លាំងយោធា ប.ក.ក. ហើយរបប លន់ នល់ បានដួលរលំនោះ រដ្ឋាភិបាលបរទេសបានចាប់ផ្តើមបញ្ជូនការទទួលស្គាល់ការទូតរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា។ ការអញ្ជើញរបស់រដ្ឋាភិបាលអាមេរិកថ្វាយមកសម្តេច នរោត្តម សីហនុឲ្យយាងត្រឡប់មកប្រទេសកម្ពុជាជាបន្តបន្ទាប់និងចូលគ្រងអំណាចពុំទទួលបានជោគជ័យនោះទេ ហើយមន្ត្រីស្ថានទូតសហរដ្ឋអាមេរិកត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៥ ជាមួយនឹងនាយករដ្ឋមន្ត្រីស្តីទី សូខាំ ខូយ។ នៅត្រឹមថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មេដឹកនាំជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរដែលនៅសេសសល់ស្ទើរតែទាំងអស់បានរត់គេចចេញពីប្រទេស ហើយ ប.ក.ក. បុរាណសិរ្សបរួមជាតិកម្ពុជាបានចូលកាន់កាប់អំណាចទាំងស្រុង។*

៤១០. *តាមការពិត រដ្ឋអំណាចនៃរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា ដែលចូលកាន់អំណាចនៅក្នុងប្រទេសកម្ពុជានៅពេលនោះ គឺគ្រាន់តែជារូបភាពបិទបាំងពីខាងក្រៅតែប៉ុណ្ណោះ។ ចំណែក ប.ក.ក. គឺគ្រប់គ្រងប្រទេសពិតប្រាកដ។ សម្តេច នរោត្តម សីហនុ បានឈ្វេងយល់ជាមុនអំពីលទ្ធផលនេះតាំងតែពីរឆ្នាំមុនមកម្ល៉េះ ដោយព្រះអង្គបានថ្លែងប្រាប់អ្នកចូលជួបសន្ទនាជាមួយព្រះអង្គនៅក្នុងប្រទេសចិនថា៖*

> ***ក្រោយពេលសង្គ្រាមចប់ទៅ ខ្ញុំនឹងនៅជានិមិត្តរូបនៃការបង្រួបបង្រួមជាតិ[...]គឺខ្មែរក្រហមនឹងជាអ្នកកាន់អំណាចពិតប្រាកដ។***

៤១១. *នៅក្នុងឆ្នាំ១៩៧៥ អ្នកអត្ថាធិប្បាយមួយរូបបានផ្តល់ការសង្កេតថា គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជាបានត្រួតត្រា ដោយខ្មែរក្រហម ដោយមានតែ«សមាជិកសីហនុនិយមតែពីររូបតែប៉ុណ្ណោះ»*

នៅក្នុងចំណោមសមាជិកគណៈរដ្ឋមន្ត្រីៗ ទោះបីជាទ្រង់មាននាមជាព្រះប្រមុខរដ្ឋក៏ដោយ ក៏សម្តេច សីហនុ មិនបានយាងមកក្រុងភ្នំពេញភ្លាមទេរហូតដល់ខែ កញ្ញា ឆ្នាំ១៩៧៥ ទើបយាងមក ដោយទ្រង់បានចំណាយរយៈពេលប៉ុន្មានខែមុននេះគង់នៅក្នុងទីក្រុងប៉េកាំង និងទីក្រុងព្យុងយ៉ាងៗ

៤១២. ក្នុងខែតុលា ឆ្នាំ១៩៧៥ គណៈកម្មាធិការអចិន្ត្រៃយ៍របស់ ប.ក.ក. បានចាត់តាំងសមាជិកជាន់ខ្ពស់ចំនួន ១៣ រូបឲ្យទទួលខុសត្រូវលើគោលនយោបាយជាក់លាក់មួយចំនួន ក្នុងនោះរួមមាន នួន ជា (ទទួលខុសត្រូវ «ការងារបក្ស សង្គមវប្បធម៌ ឃោសនា និង សិក្សាធិការ») និង ខៀវ សំផន (ទទួលខុសត្រូវ « រណសិរ្ស និងរដ្ឋាភិបាល ពាណិជ្ជកម្មខាងបញ្ជី និង តម្លៃ»)ៗ អៀង សារី ទទួលខុសត្រូវ «ការងារបរទេស ទាំងបក្សទាំងរដ្ឋ» ចំណែក ប៉ុល ពត «ទទួលរួមខាងយោធា និងសេដ្ឋកិច្ច»ៗ កុយ ធួន ហៅ ធុច ទទួលខុសត្រូវ «ពាណិជ្ជកម្មក្នុងប្រទេស និងក្រៅប្រទេស» សុន សេន ទទួលខុសត្រូវ «សេនាធិការ និង សន្តិសុខ», វន វ៉ែត ទទួលខុសត្រូវ «ឧស្សាហកម្ម រទេះភ្លើង និង នេសាទ», អៀង ធីរិទ្ធ ហៅ ភា ទទួលខុសត្រូវ ខាង «វប្បធម៌ សង្គមកិច្ច និងការងារបរទេស», យុន យ៉ាត ហៅ អាត ទទួលខុសត្រូវ «ឃោសនាអប់រំទាំងផ្ទៃក្នុងទាំងខាងក្រៅ» និង នង សួន ហៅ ជ័យ ទទួលខុសត្រូវ ខាង «កសិកម្ម» ។ ផ្អែកលើឯកសារបោះពុម្ពផ្សាយផ្លូវការនានារបស់កម្ពុជាប្រជាធិបតេយ្យថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៥ ខៀវ សំផន បានបង្ហាញសេចក្តីព្រាងរដ្ឋធម្មនុញ្ញថ្មីមួយនៅក្នុងសមាជជាតិក្នុងទីក្រុងភ្នំពេញៗ នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៧៦ រដ្ឋធម្មនុញ្ញថ្មីនេះ(«រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ») បានចូលជាធរមាន ហើយរដ្ឋធម្មនុញ្ញនៃរបបកម្ពុជាប្រជាធិបតេយ្យបានចាប់បដិសន្ធិឡើងពីពេលនោះមកៗ រដ្ឋធម្មនុញ្ញនៃរបបកម្ពុជាប្រជាធិបតេយ្យបានប្រគល់អំណាចនីតិបញ្ញត្តជូនតំណាងប្រជាជន («សភាតំណាងប្រជាជន») ដែលមានសមាជិកជ្រើសតាំងចំនួន ២៥០រូបៗ រដ្ឋាភិបាលត្រូវបានជ្រើសតាំងឡើង ហើយត្រូវទទួលខុសត្រូវចំពោះមុខសមាជិកសភាតំណាងប្រជាជនៗ «តុលាការប្រជាជន» ក៏ត្រូវបានតែងតាំងដោយសភាតំណាងប្រជាជនដែរៗ រដ្ឋធម្មនុញ្ញនៃរបបកម្ពុជាប្រជាធិប-តេយ្យ មានគណៈប្រធានរដ្ឋជំនួសព្រះមហាក្សត្រ ហើយគណៈប្រធានរដ្ឋនេះក៏ត្រូវបានតែងតាំងដោយសភាតំណាងឲ្យកម្ពុជាប្រជាធិបតេយ្យ នៅក្នុងនិងក្រៅប្រទេសៗ

៤១៣. ការបង្កើតឡើងទាំងនេះ គឺគ្រាន់តែជារូបភាពបិទបាំងខាងក្រៅប៉ុណ្ណោះៗ កំណត់ហេតុកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប.ក.ក. បានឆ្លុះបញ្ចាំងអំពីទស្សនៈរបស់គណៈកម្មាធិការនេះថា សភាតំណាងប្រជាជន «គ្មានតម្លៃ» ហើយប្រាប់សមាជិករបស់ខ្លួនឲ្យប្រយ័ត្នដោយ «មិនត្រូវនិយាយលេងពីសភានៅមុខប្រជាជនឲ្យគេឃើញថា យើងបន្លែបន្លប់»ៗ ទោះបីជារដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យបានចែងថា «ការបោះឆ្នោតទូទាំងប្រទេសដោយផ្ទាល់និងដោយសម្ងាត់» ដើម្បីជ្រើសរើសសមាជិកសភាតំណាងប្រជាជន ប៉ុន្តែការបោះឆ្នោតទូទាំងប្រទេសមិនត្រូវបានរៀបចំធ្វើឡើងនោះឡើយៗ យ៉ាងច្រើនណាស់ ការបោះឆ្នោតត្រូវបានរៀបចំធ្វើឡើងនៅតាមកន្លែងមួយចំនួនតូចតែប៉ុណ្ណោះ ហើយយើងមិនដឹងច្បាស់ថា តើអ្នកបោះឆ្នោតត្រូវបានគេផ្តល់ជម្រើសបេក្ខជនសភាពិតប្រាកដឬ ក៏យ៉ាងណានោះទេៗ សាក្សី ប្រាក់ យុត និង អ៊ុង វ៉ែន ពុំបានដឹងថា ពួកគេគឺជាបេក្ខជនសភាតំណាងប្រជាជននោះទេ រហូតទាល់តែពួកគេត្រូវបានថ្នាក់លើខ្លួនជូនដំណឹងថា ពួកគេត្រូវបានតែងតាំងរួចហើយ ហើយសូម្បីតែបន្ទាប់ពីការតែងតាំងនោះហើយ ពួកគេក៏នៅតែមិនយល់ច្បាស់ថាតើពួកគេមានតួនាទី និងការទទួលខុសត្រូវអ្វីខ្លះក្នុងនាមជាសមាជិកសភាតំណាងប្រជាជននោះៗ ពួកគេទាំងពីរពុំចាំបានថាពួកគេធ្លាប់បានចូលរួមប្រជុំសភាតំណាងប្រជាជនអំពីការបោះឆ្នោតអនុម័តច្បាប់អ្វីឡើយៗ ម៉ាត់ លី ដែលជាសមាជិកសភាតំណាងប្រជាជនបានម្ងឹកអំពីការបោះឆ្នោតជ្រើសរើសសមាជិកសភាតំណាងប្រជាជនថា ជារឿងក្លែងក្លាយដោយសារតែមណ្ឌលមួយមានឈ្មោះតែម្នាក់គត់នៅលើសន្លឹកឆ្នោតៗ បន្ទាប់ពីការបោះឆ្នោតសមាជិកសភាតំណាងប្រជាជនត្រូវបានកោះហៅឲ្យចូលរួមប្រជុំមួយ ដែលពេលនោះមានការអានឯកសារដែលត្រូវបានអនុម័តជាមុនទៅហើយ ហើយសមាជិកសភា

តំណាងប្រជាជនត្រូវតែអនុម័តយល់ព្រមៗ

**៤១៤.** នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ក្រោយពីការអះអាងថា មានការបោះឆ្នោតជ្រើសតាំងសភាតំណាងប្រជាជន ប៉ុន្តែមុនសម័យប្រជុំសភាដំបូងនោះ គណៈកម្មាធិការមជ្ឈិមនៃ ប.ក.ក. បានតែងតាំង ខ្ទួន ជា ឲ្យធ្វើជាប្រធានរដ្ឋ ពោលគឺជាប្រធានរដ្ឋរបស់កម្ពុជាប្រជាធិបតេយ្យ។ គណៈកម្មាធិការមជ្ឈិមក៏បានតែងតាំងសមាជិករដ្ឋាភិបាលមួយចំនួនផ្សេងទៀត រួមទាំង ប៉ុល ពត ធ្វើជានាយករដ្ឋមន្ត្រី,អៀង សារី ធ្វើជាឧបនាយករដ្ឋមន្ត្រី ទទួលខាងការបរទេស, វន វេត ឧបនាយករដ្ឋមន្ត្រី ទទួលខាងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង សុន សេន ឧបនាយករដ្ឋមន្ត្រី ទទួលខាងការពារប្រទេស។

**៤១៥.** នៅក្នុងខែមេសា ឆ្នាំ១៩៧៦ សម្តេច នរោត្តម សីហនុ បានប្រកាសលាលែងពីតំណែងជាប្រមុខរដ្ឋ។ ប៉ុន្មានថ្ងៃក្រោយមក សមាជិកនៃរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជាទាំងអស់បានលាឈប់ពីតំណែង ដើម្បីទុកលទ្ធភាពសម្រាប់ការបង្កើតរដ្ឋាភិបាលថ្មី។ ចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៦ សភាតំណាងប្រជាជនបានជួបជុំគ្នាសម័យប្រជុំលើកដំបូងរបស់ខ្លួន ដែលនៅពេលនោះ តាមអំណះអំណាងសភាបានជ្រើសរើសនិងតែងតាំងសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជន ប្រធានគណៈប្រធានរដ្ឋ និងរដ្ឋាភិបាល។ តាមការពិត សភាតំណាងប្រជាជនគ្រាន់តែធ្វើការផ្តល់សច្ចាប័នត្រាលើជម្រើសទាំងឡាយដែល ប.ក.ក. បានសម្រេចរួចហើយតែប៉ុណ្ណោះ។

**៤១៦.** រដ្ឋាភិបាលក៏គ្រាន់តែជាឧបករណ៍ដ៏តូចមួយរបស់ ប.ក.ក. ប៉ុណ្ណោះ។ អ្នកជំនាញ David CHABDER បានពិពណ៌នាថា « រដ្ឋាភិបាលត្រូវបានបង្កើតដោយបក្សកាន់អំណាចនិងបម្រើបក្សកាន់អំណាច» ហើយមិនមានតុល្យភាពនៅក្នុងការគ្រប់គ្រងរបស់ ប.ក.ក. ទេ។



យោធាខ្មែរក្រហមនៅកន្លែងទទួលភ្ញៀវរបស់បក្សកុម្មុនីស្តកម្ពុជា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលបច្ចុប្បន្នក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រដ្ឋមន្ត្រីរដ្ឋាភិបាល និងបុគ្គលិកក្រសួងរាយការណ៍ និងទទួលបានការណែនាំពីគណៈកម្មាធិការអចិន្ត្រៃយ៍នៃ ប.ក.ក.។ កំណត់ហេតុប្រជុំរបស់គណៈកម្មាធិការមជ្ឈិម ប.ក.ក. បានឆ្លុះបញ្ចាំងនូវគំនិតរបស់គណៈកម្មាធិការមជ្ឈិមបក្សថា រដ្ឋាភិបាល «ត្រូវជាអង្គការរបស់បក្សសុទ្ធសាធ» ។ រដ្ឋមន្ត្រីរដ្ឋាភិបាលបានជួបជាមួយ ប៉ុល ពត ដែលនៅពេលនោះបំពេញមុខងារជានាយករដ្ឋមន្ត្រីផងនិងជាលេខាប.ក.ក. ផងនៅក្នុងពេលជួបប្រជុំគណៈរដ្ឋមន្ត្រី។ នៅក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រីលើកទីមួយ ប៉ុល ពតបានបញ្ជាក់ច្បាស់ថា រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យមានមុខងារចម្បងត្រូវអនុវត្តមាគ៌ារបស់ ប.ក.ក.៖

ធាតុពិតរបស់រដ្ឋាភិបាលថ្មីរបស់យើង គឺជារដ្ឋាភិបាលបដិវត្តរបស់កម្មករ-កសិករសុទ្ធសាធជារបស់បក្សកុម្មុយនីស្តកម្ពុជាសុទ្ធសាធ[...] សមាជិករដ្ឋាភិបាលនិងសមាជិករបស់គណៈកម្មាធិការគ្រប់តំបន់ត្រូវក្តាប់ធាតុពិតរបស់រដ្ឋាភិបាលយើង នូវតួនាទីរបស់យើង ហើយខិតខំបំពេញភារកិច្ចឲ្យបានល្អទៅតាមមាគ៌ារបស់បក្ស។ ក្តាប់មាគ៌ារបស់បក្សបានន័យថា ក្តាប់គោលជំហរចាត់តាំងរបស់បក្ស និងក្តាប់សំណូមពរនយោបាយរបស់បក្សលើគ្រប់ផ្នែកដើម្បីអនុវត្តនយោបាយរបស់បក្សឲ្យបានល្អនិងត្រឹមត្រូវ [...] នៅក្នុងក្របខណ្ឌក្រសួងនីមួយៗក៏ដូច្នោះដែរ។ គឺត្រូវខិតខំបំពេញភារកិច្ចតាមមាគ៌ារបស់បក្សឲ្យបានត្រឹមត្រូវ ម៉ត់ចត់និងពេញលេញ [...]

**៤១៧.** ចំពោះស្ថាប័នទីបីរបស់រដ្ឋ ដូចបានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ពោលគឺស្ថាប័នតុលាការ សភាតំណាងប្រជាជនបានអះអាងថា បង្កើតនិងតែងតាំងប្រធាន «គណៈកម្មាធិការតុលាការ» នៅក្នុងសម័យប្រជុំរបស់ខ្លួន ក្នុងខែមេសា ឆ្នាំ១៩៧៦។ ប៉ុន្តែគ្មានប្រព័ន្ធតុលាការណាមួយត្រូវបានបង្កើតនិងដំណើរការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ។

**៤១៨.** មុខតំណែងខ្ពស់ជាងគេបំផុតនៅក្នុងរដ្ឋកម្ពុជាប្រជាធិបតេយ្យ គឺជានាយករដ្ឋមន្ត្រី ប្រធានគណៈប្រធានរដ្ឋ និងប្រធានសភាតំណាងប្រជាជន ត្រូវបានកាន់កាប់ដោយសមាជិកដោយសមាជិកជាន់ខ្ពស់របស់ ប.ក.ក.។ ថ្នាក់ដឹកនាំនិងរដ្ឋមន្ត្រីរបស់រដ្ឋាភិបាលត្រូវបានតែងតាំងដោយ ប.ក.ក. ហើយក៏ត្រូវរាយការណ៍ជូន ប.ក.ក. ផងដែរ។ ស្ថាប័នតុលាការនិងស្ថាប័ននីតិបញ្ញត្តិ មិនបានដំណើរការឡើយ។ សរុបមក យោងតាមសំដីរបស់ ខៀវ សំផន កម្ពុជាប្រជាធិបតេយ្យគឺជាប្រទេសមួយដែល «បក្សជាអ្នកដឹកនាំរដ្ឋ» ។

### ៥.២.១. ក្រសួងនានា និងគណៈកម្មាធិការរបស់កម្ពុជាប្រជាធិបតេយ្យ

**៤១៩.** ដូចបានកត់សម្គាល់ខាងលើ នៅក្នុងខែមេសា ឆ្នាំ១៩៧៦ សភាតំណាងប្រជាជនបានជួបប្រជុំអនុម័តលើរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដោយមានការ



យោធាខ្មែរក្រហមនៅស្តាតអូឡាំពិច។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

តែងតាំង ប៉ុល ពត ជានាយករដ្ឋមន្ត្រី, អៀង សារី ជាឧបនាយករដ្ឋមន្ត្រីទទួលខុសត្រូវខាងផ្នែកការបរទេស, វន វ៉េត ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកខាងសេដ្ឋកិច្ច, សុន សេន ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកខាងការពារជាតិ, ហ៊ូ នឹម រដ្ឋមន្ត្រីទទួលបន្ទុកខាងពត៌មាន និងឃោសនាការ, ជួន ជឿន រដ្ឋមន្ត្រីក្រសួងសុខាភិបាលសាធារណៈ, អៀង ធីរិទ្ធ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច, តូច ភឿន រដ្ឋមន្ត្រីក្រសួងសុខាភិបាលសាធារណការ និង យុន យ៉ាត រដ្ឋមន្ត្រីក្រសួងវប្បធម៌ បណ្តុះបណ្តាល និងអប់រំ។ យ៉ាងណាមិញ នេះគឺជាភស្តុតាងដំបូងដែលបានបង្ហាញអំពីស្ថាប័នទទួលខុសត្រូវដែលនាពេលបច្ចុប្បន្នត្រូវបានចាត់ទុកថាជា «ក្រសួង» ប៉ុន្តែការបែងចែកការទទួលខុសត្រូវទាំងនេះ



មានភវនីយភាពតាំងពីមុនពេលនោះទៀតក៏ដោយក្តី។ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យមិនបានលើកឡើងអំពី «ស្ថាប័ននីតិប្រតិបត្តិ» ដែលត្រូវបានជ្រើសរើសដោយសភាតំណាងប្រជាជន ហើយត្រូវបានទទួលខុសត្រូវចំពោះសកម្មភាពទាំងឡាយរបស់ខ្លួន។ ប៉ុន្តែ មិនមានភស្តុតាងដែលថា សភាតំណាងប្រជាជនបានសម្រេចការងារផ្នែកនីតិប្បញ្ញត្តិណាមួយ និងថាក្រសួងមួយចំនួនមានតែនៅលើក្រដាសប៉ុណ្ណោះនោះទេ។ ទោះបីជាយ៉ាងណា គណៈកម្មាធិការអចិន្ត្រៃយ៍ចេញសេចក្តីសម្រេចលើរាល់គ្រប់កិច្ចការងារ។

**៤២០.** ក្រសួងឃោសនាការនិងអប់រំ៖ នៅក្នុងការប្រជុំសភាតំណាងប្រជាជន កាលពីខែមេសា ឆ្នាំ១៩៧៦ យុន យ៉ាត ត្រូវបានបញ្ជាក់ថា គឺជារដ្ឋមន្ត្រីក្រសួងអប់រំ ចំណែក ហ៊ូ នឹម គឺជារដ្ឋមន្ត្រីក្រសួងឃោសនាការ។ ទោះបីជាយ៉ាងណាក្តី ផ្អែកលើសក្ខីកម្មរបស់សាក្សីនិងឯកសារមួយចំនួនអង្គជំនុំជម្រះយល់ឃើញថា នួន ជា មានការទទួលខុសត្រូវសំខាន់ៗនៅក្នុងវិស័យទាំងអស់នេះ រួមទាំងការទទួលខុសត្រូវលើទស្សនាវដ្តីអប់រំផ្ទៃក្នុងរបស់ ប.ក.ក. គឺជាទស្សនាវដ្តីទង់បដិវត្ត។ ការវិភាគលម្អិតបន្ថែមទៀតលើការទទួលខុសត្រូវរបស់ នួន ជា លើវិស័យទាំងនេះមានចែងក្នុងសាលក្រមនេះត្រង់ផ្នែកស្តីពីតួនាទី និងមុខងាររបស់ នួន ជា។

**៤២១.** ផ្នែកសេដ្ឋកិច្ច៖ នៅក្នុងការប្រជុំនានាពីថ្ងៃទី១៩ ដល់ថ្ងៃទី ២១ ខែមេសា ឆ្នាំ១៩៧៦ គណៈកម្មាធិការអចិន្ត្រៃយ៍បានសម្រេចលើការរៀបចំមន្ទីរ ៨៧០ ឡើងវិញ ដោយបង្កើតគណៈកម្មាធិការនានាដែលទទួលខុសត្រូវលើវិស័យនានាពាក់ព័ន្ធនឹងសេដ្ឋកិច្ចរួមមានពាណិជ្ជកម្ម ថាមពល ដីធ្លី ការដឹកជញ្ជូនដើងគោកការដឹកជញ្ជូនដើងទឹក ឃ្លាំងនៅភ្នំពេញ សាធារណការរថភ្លើង កំពង់ផែ កសិកម្ម ឧស្សាហកម្ម និងវាយនភណ្ឌកាត់ដេរសម្លៀកបំពាក់។ ភស្តុតាងដែលគួរឲ្យជឿជាក់បានមួយចំនួនបានបង្ហាញថាគណៈកម្មាធិការទាំងអស់នេះ ស្ថិតក្រោមការគ្រប់គ្រងរបស់ វន វ៉េត និង ខៀវ សំផន។ ទីមួយគឺកំណត់ត្រានៃកិច្ចប្រជុំរបស់សភាតំណាងប្រជាជន ដែលលើកឡើងថាគណៈកម្មាធិការសេដ្ឋកិច្ចមួយចំនួន (រួម

ទាំងខស្សរាហកម្ម ពាណិជ្ជកម្ម និងថាមពល) ស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច វន វ៉ែត។ ទីពីរ គឺមានទូរលេខជាច្រើនដែលបានផ្ញើពី វ៉ាន់ រិត ដែលបានកាន់តំណែងជាប្រធានគណៈកម្មាធិការពាណិជ្ជកម្ម ហើយទូរលេខទាំងនេះត្រូវបានរាយការណ៍ជូន វន វ៉ែត និង ខៀវ សំផន។ ចំណុចទាំងនេះធ្វើឲ្យសាក្សី សគីម ល្មុត ដែលជាអនុប្រធានធនាគារពាណិជ្ជកម្មនៃកម្ពុជាប្រជាធិបតេយ្យបានសន្និដ្ឋានថា វ៉ាន់ រិត គឺស្ថិតនៅក្រោមបង្គាប់របស់ វន វ៉ែត និង ខៀវ សំផន។ ហេតុដូច្នេះអង្គជំនុំជម្រះសន្និដ្ឋានថា គណៈកម្មាធិការដែលគណៈកម្មាធិការអចិន្ត្រៃយ៍បក្សដាក់ឈ្មោះទាំងនោះ ត្រូវបានបង្កើតឡើងនៅក្នុងក្របខណ្ឌមុខងារសេដ្ឋកិច្ចរបស់ វន វ៉ែត។ លើសពីនេះទៀត អង្គជំនុំជម្រះយល់ឃើញថា ខៀវ សំផន និង វន វ៉ែត បានដឹងលម្អិតអំពីបញ្ហាសេដ្ឋកិច្ចនៃកម្ពុជាប្រជាធិបតេយ្យ ដែលពាក់ព័ន្ធនឹងគណៈកម្មាធិការទាំងនេះ ចាប់ពីឆ្នាំ១៩៧៦ រហូតដល់ចុងឆ្នាំ១៩៧៨។ បន្ទាប់ពី វន វ៉ែត ត្រូវបានគេចាប់ខ្លួននៅចុងឆ្នាំ១៩៧៨ ខៀវ សំផន បានទទួលរបាយការណ៍ទាំងនេះបន្ត។

**៤២២.** ដោយមានលំហូរសាច់ប្រាក់យ៉ាងច្រើនមកពីប្រទេសចិន(១៤០លានយ័ន) គណៈកម្មាធិការពាណិជ្ជកម្មបានបង្កើតធនាគារពាណិជ្ជកម្មក្រៅប្រទេសមួយ នៅក្នុងឆ្នាំ១៩៧៦ ដើម្បីធ្វើពាណិជ្ជកម្មជាមួយប្រទេសដទៃទៀត។ ក្រុមហ៊ុនពាណិជ្ជកម្មបរទេសកម្ពុជា (ក្រុមហ៊ុន FORTRA ) និងក្រុមហ៊ុនពាណិជ្ជកម្មដែលបានចុះបញ្ជីនៅហុងកុង (ក្រុមហ៊ុន REN FUNG) ក៏ត្រូវបានបង្កើតឡើងផងដែរ ដើម្បីសម្រួលដល់ពាណិជ្ជកម្ម។ ក្រុមហ៊ុនទាំងពីរនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការពាណិជ្ជកម្ម និងត្រូវរាយការណ៍ទៅ ខៀវ សំផន ដែលជាអ្នកត្រួតពិនិត្យការទំនាក់ទំនងជាមួយក្រុមហ៊ុនរ៉ុនហ្វុង (REN FUNG) ។

**៤២៣.** សុខ គឺជាប្រធានក្រុមហ៊ុនរ៉ុនហ្វុង (REN FUNG) ចាប់តាំងពីពេលបង្កើតក្រុមហ៊ុនរ៉ុនហ្វុង (REN FUNG) នៅក្នុងខែតុលា ឆ្នាំ១៩៧៦ រហូតដល់ពេលគាត់ត្រូវបានហៅឲ្យត្រឡប់មកភ្នំពេញវិញ។ ជាមួយគ្នានោះផងដែរ គាត់មានជំនួយការម្នាក់ដែលមានឈ្មោះផល វ៉ា ហៅណាត។ ពួកគាត់ទាំងពីរនាក់ត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ ក្នុងខែធ្នូ ឆ្នាំ១៩៧៨ បន្ទាប់មក គ្រិន ប្រធានគណៈកម្មាធិការកំពង់ផែបានក្លាយជាប្រធានក្រុមហ៊ុនរ៉ុនហ្វុង (REN FUNG)។

## ៥.៣ រចនាសម្ព័ន្ធនៃកងកម្លាំងយោធាបក្សកុម្មុយនីស្តកម្ពុជា

### ៥.៣.១. កងទ័ពបដិវត្តន៍កម្ពុជា

#### ៥.៣.១.១. ការបង្កើតកងទ័ពបដិវត្តន៍កម្ពុជា

**៤២៤.** នៅពេល ប.ក.ក. បុរណសិរ្សរួបរួមជាតិកម្ពុជាបានកាន់កាប់ទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងកម្លាំងយោធា ប.ក.ក. ដែលបានវាយប្រយុទ្ធក្រោមស្លាកនៃកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ភូមិភាគ ពុំមែនស្ថិតនៅក្រោមការគ្រប់គ្រងរបស់មជ្ឈិមបក្សទេ។ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៧៥ ប៉ុល ពត បានប្រកាសបង្កើតកងទ័ពបដិវត្តន៍កម្ពុជាថ្មីមួយ («កងទ័ពបដិវត្តន៍កម្ពុជា») ដោយយកកងពលតាមភូមិភាគមួយចំនួនដាក់ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការមជ្ឈិម ជាពិសេស ឲ្យស្ថិតនៅក្រោមការបញ្ជារបស់សេនាធិការដែលដឹកនាំដោយ សុន សេន។ កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥ ដែលមាន នួន ជា និង ខៀវ សំផន ចូលរួមផងដែរនោះ បានបង្ហាញអំពីការរៀបចំទ័ពឡើងវិញក្នុងរយៈពេលខ្លីនោះទេ ពោលគឺបានបន្តធ្វើរហូតដល់ក្នុងអំឡុងត្រីមាសទីបីនៃឆ្នាំ១៩៧៥។ អង្គភាពទាំងឡាយដែលត្រូវបានបង្កើតនៅក្រោមសេនាធិការ(«កងពលមជ្ឈិម»)

នៅពាក់កណ្តាលឆ្នាំ១៩៧៥ ដល់ចុងឆ្នាំ១៩៧៥ រួមមានកងពល១៦៤ ដែលជាកងទ័ពជើងទឹក កងពល១៧០,កងពល២៩០, កងពល៣១០,កងពល៤៥០. កងពល៥០២ ដែលជាកងទ័ពអាកាស,កងពល៧០៣, កងពល៨០១ និងកងពល ២៩០ ។ «កងវរសេនាធំឯករាជ្យ» មួយចំនួនក៏ត្រូវបានបង្កើតឡើងក្រោមសេនាធិការ ដោយកងវរសេនាធំឯករាជ្យនីមួយៗទទួលភារកិច្ចដាក់លាក់។ កងវរសេនាធំឯករាជ្យ រួមមាន

កងវរសេនាធំឯករាជ្យនីមួយៗ ទទួលភារកិច្ចដាក់លាក់ៗ កងវរសេនាធំឯករាជ្យ រួមមាន កងវរសេនាធំ៧៥ (កងកាត់ដេរ) កងវរសេនាធំ១៥២ (កងជើងទឹក) កងវរសេនាធំ៣៧៧(កងកាំភ្លើងធំ) កងវរសេនាធំ៤៨៨ មន្ទីរ៦២ (ផ្នែកភស្តុភារ) មន្ទីរ៦៣ (ផ្នែកភស្តុភារ) និងមន្ទីរសន្តិសុខស-២១ៗ កងពលត្រូវបានរៀបចំនិងកែប្រែឡើងវិញ នៅក្នុងអំឡុងឆ្នាំ១៩៧៧ និង១៩៧៨ៗ នៅពេលនោះកងទ័ពជាច្រើនបានបញ្ជូលទៅភូមិភាគបូព៌ា ដោយដាក់ស្ថិតក្រោមការគ្រប់គ្រងរបស់ទីបញ្ជាការសមរភូមិរបស់ភូមិភាគបូព៌ា ព្រោះការបោសម្អាតនៅភូមិភាគបូព៌ា និងជម្លោះប្រដាប់អាវុធជាមួយនឹងវៀតណាមកាន់តែមានសភាពតានតឹងឡើងៗ។

**៤២៥.** តួនាទីរបស់កងទ័ពបដិវត្តន៍កម្ពុជា ត្រូវបានកំណត់នៅក្នុងមាត្រា ១៩ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យៗ កងទ័ពបដិវត្តន៍កម្ពុជាមានភារកិច្ច «ការពាររដ្ឋអំណាចរបស់ប្រជាជនកម្ពុជាការពារកម្ពុជា [...] ក្នុងបូរណភាពដែនដី» និង «កសាងប្រទេសឲ្យថ្កុំថ្កើន រុងរឿង លើកស្ទួយជីវភាពប្រជាជនឲ្យបានរីកចម្រើន និងសំបូរសប្បាយជាលំដាប់»ៗ ទោះបីជាយ៉ាងណា កងទ័ពបដិវត្តន៍កម្ពុជាគឺជាកងទ័ពរបស់ ប.ក.ក. យ៉ាងពិតប្រាកដ ពុំមែនជាស្ថាប័នរបស់រដ្ឋឡើយៗ លក្ខន្តិកៈនៃ ប.ក.ក. បានចែងថា កងទ័ពបដិវត្តន៍កម្ពុជា «ត្រូវស្ថិតនៅក្រោមការដឹកនាំផ្តាច់មុខដាច់ខាត និងគ្រប់គ្រងផ្នែករបស់បក្សកុម្មុយនីស្តកម្ពុជាៗ ស្រដៀងគ្នានេះដែរ ទស្សនាវដ្តី«ទង់បដិវត្តន៍» របស់ ប.ក.ក. បានចាត់ទុកកងទ័ពបដិវត្តន៍កម្ពុជាថាជា«ឧបករណ៍ផ្តាច់ការរបស់បក្សដ៏បរិសុទ្ធ» ៗ

## ៥.៣.១.២. រចនាសម្ព័ន្ធនៃកងទ័ពបដិវត្តន៍កម្ពុជា

**៤២៦.** ទាំងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យនិងលក្ខន្តិកៈ ប.ក.ក. បានបែងចែកកងទ័ពបដិវត្តន៍កម្ពុជាបីប្រភេទគឺៈ កងទ័ពស្រួច (ពោលគឺពលមជ្ឈិម និងវរសេនាធំឯករាជ្យដែលស្ថិតក្រោមការគ្រប់គ្រងសេនាធិការ នៅក្នុងពាក់កណ្តាលឆ្នាំ១៩៧៥ រហូតដល់ចុងឆ្នាំ១៩៧៥) កងទ័ពតំបន់ (គឺជាកងទ័ពដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ភូមិភាគ តំបន់ និងស្រុក)



យោធាខ្មែរក្រហមនៅស្តាតអូឡាំពិចៗ
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

និងកងឈ្លបតាមមូលដ្ឋាន(គឺកងកម្លាំងនៅថ្នាក់ឃុំ)ៗ ថ្នាក់តំបន់និងថ្នាក់ស្រុក មានកងទ័ពរបស់ពួកគេផ្ទាល់ ដោយឡែកពីកងពលមជ្ឈិម ក្នុងគោលបំណងចម្បងសម្រាប់ទុកការពារទឹកដីរបស់ពួកគេៗ

## ៥.៣.១.២.១. កងទ័ពស្រួចៈ កងពលមជ្ឈិម និងកងវរសេនាធំឯករាជ្យ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់សេនាធិការ

**៤២៧.** ដូចគ្នានឹងរចនាសម្ព័ន្ធរដ្ឋបាលស៊ីវិលនៃ ប.ក.ក. ដែលកងទ័ពបដិវត្តន៍កម្ពុជាត្រូវបានរៀបចំឋានានុក្រមក្នុងទម្រង់ជាពីរ៉ាមីតៗ នៅថ្នាក់លើបំផុត (ទោះបីស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការមជ្ឈិមនិងគណៈកម្មាធិការយោធាក៏ដោយ) មានសេនាធិការៗ

សេនាធិការទទួលខុសត្រូវទាំងស្រុងលើបញ្ជាការរបស់កងពលមជ្ឈិមនិងដោះស្រាយការងារយោធា រួមមាន ការផ្គត់ផ្គង់ភស្តុភារ អាវុធ កម្លាំងទ័ព ទំនាក់ទំនង និងព័ត៌មានៗ យ៉ាងហោចណាស់ សេនាធិការបានរៀបចំវគ្គរៀនសូត្រចំនួនពីរសម្រាប់កងពលមជ្ឈិម និងកងវរសេនាធំឯករាជ្យៗ លើសពីនេះទៀត នៅចំពោះមុខអង្គជំនុំជម្រះមានកំណត់ហេតុនៃកិច្ចប្រជុំមួយចំនួន ដែលបានដឹកនាំដោយលេខា និងអនុលេខាកងពលមជ្ឈិម និងវរសេនាធំឯករាជ្យ នៅក្នុងឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៧ៗ

**៤២៨.** សេនាធិការដឹកនាំដោយ ស៊ុន សេន ហៅ ខៀវ ហៅ បង៨៩ ដែលជាសមាជិកនៃគណៈកម្មាធិការយោធារបស់ ប.ក.ក. និងជាសមាជិកបម្រុងនៃគណៈកម្មាធិការអចិន្ត្រៃយ៍របស់ ប.ក.ក.ៗ អនុប្រធានទីមួយរបស់ ស៊ុន សេន នៅសេនាធិការគឺ ម៉ែន សាន ហៅ ណៃ សារ៉ាន់ ហៅ យ៉ា ដែលបានកាន់តំណែងនេះក្នុងរយៈពេលខ្លី មុនពេលគាត់ក្លាយជាលេខាភូមិភាគឦសានៗ ចំណែកឯអនុប្រធានទីពីរនៅសេធិការគឺ ស៊ាត ឆែ ហៅ ទុំ ហៅ បង៨១ រហូតដល់ពេលដែលគាត់ត្រូវបានគេចាប់ខ្លួននៅក្នុង ខែសីហា ឆ្នាំ១៩៧៧ៗ ពេជ ឆន ហៅ សៅ ហៅ សោម គឺជាជំនួយការដែលមានភារកិច្ចគ្រប់គ្រងខាងរដ្ឋបាលៗ គាត់ទទួលខុសត្រូវលើមន្ទីរ ៦២ ដែលជាអង្គភាពភស្តុភារ របស់កងទ័ពបដិវត្តន៍កម្ពុជា រហូតដល់ពេលដែលគាត់បានបោសសម្អាតនៅដើមឆ្នាំ១៩៧៧ ៗ អង្គជំនុំជម្រះបានកត់សម្គាល់ថា បុគ្គលទាំងបីរូបនេះត្រូវបានចម្លងជូននៅក្នុងឯកសារកំណត់ហេតុកិច្ចប្រជុំជាច្រើន ពោលគឺនៅផ្នែកខាងលើឬផ្នែកខាងក្រោមនៃឯកសារ ហើយពួកគេត្រូវបានហៅថា បង៨៩, បង៨១ និង សោមៗ សមាជិកដ៏ទៃទៀតនៅសេនាធិការ (ដែលត្រូវបានចម្លងជូនជាទៀងទាត់ក្នុងឯកសារ) រួមមានមាស មុត ដែលទទួលខុសត្រូវលើកងទ័ពជើងទឹក និងស៊ូ ម៉េត ដែលទទួលខុសត្រូវលើកងទ័ពអាកាសៗ ចំណែកឯអ៊ិន លន ហៅ ណាត មានតួនាទីជំនួយការនៅសេនាធិការបន្ទាប់ពីគាត់ត្រូវបានគេផ្ទេរចេញពីមន្ទីរសន្តិសុខស-២១ ក្នុងខែមីនា ឆ្នាំ១៩៧៦ៗ សមមិត្ត វ៉ែន ក៏ជាជំនួយការនៅសេនាធិការផងដែរៗ

**៤២៩.** សេនាធិការមានទីតាំងស្ថិតនៅក្នុងអគារមួយនៅក្បែរក្រសួងការបរទេស ស្ថិតនៅលើផ្លូវដែលសព្វថ្ងៃត្រូវបានហៅថាមហាវិថីសហព័ន្ធរុស្ស៊ី ក្នុងទីក្រុងភ្នំពេញៗ សាក្សីមួយចំនួនបានផ្តល់សក្ខីកម្មថា «ក្រសួងការពារជាតិ» ក៏ស្ថិតនៅក្នុងទីតាំងនោះផងដែរៗ លើសពីនេះទៀតអង្គជំនុំជម្រះកត់សម្គាល់ថា ជាញឹកញាប់ ស៊ុន សេន ត្រូវបានគេហៅថា ជាថ្នាក់ដឹកនាំនៃក្រសួងនេះៗ ឌុច បានផ្តល់សក្ខីកម្មថា បើទោះបីជា ស៊ុន សេន ត្រូវបានផ្តល់ឋានៈជារដ្ឋមន្ត្រីនៃក្រសួងការពារប្រទេស ប៉ុន្តែគាត់ក៏នៅមានតួនាទីនៅសេនាធិការផងដែរ ពោលគឺតួនាទីរបស់គាត់នៅសេនាធិការមិនមានការផ្លាស់ប្តូរនោះទេៗ បន្ថែមពីលើនេះ ភស្តុតាងបានបង្ហាញថា តួនាទីរបស់ ស៊ុន សេន ជារដ្ឋមន្ត្រីនៃក្រសួងការពារប្រទេស គឺដូចគ្នានឹងតួនាទីរបស់គាត់នៅខាងសេនាធិការកងទ័ពផងដែរៗ លើសពីនេះទៀត សាក្សី ជង សុជង់ ដែលបានធ្វើការនៅក្នុងអង្គភាពសរសេរជាលេខកូដ និងបកប្រែលេខកូដទូរលេខ នៅសាលសុធារស ក្នុងទីក្រុងភ្នំពេញ ចាប់ពីឆ្នាំ១៩៧៥ មកនោះបានផ្តល់សក្ខីកម្មថាមានកងពលមួយចំនួនដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងការពារប្រទេស ស៊ុន សេន រួមមាន កងទ័ពជើងគោក កងទ័ពជើងទឹក និងកងទ័ពជើងអាកាសៗ ដូចកត់សម្គាល់នៅខាងលើ សេនាធិការមានអំណាចទាំងស្រុងនៅក្នុងការបញ្ជាលើកិច្ចការនានារបស់កងទ័ពៗ ហេតុដូច្នេះអង្គជំនុំជម្រះយល់ឃើញថាក្រសួងការពារប្រទេសមិនមែនជាក្រសួងដាច់ដោយឡែកដែលមិនស្ថិតនៅក្រោម ប.ក.ក. នោះទេៗ ជាក់ស្តែង តួនាទីនេះជាទូទៅត្រូវបានប្រើប្រាស់សំដៅដល់មុខងារយោធានៅសេនាធិការ និងទួនាទីពាក់ព័ន្ធរបស់ ស៊ុន សេន នៅទីនេះៗ

**៤៣០.** នៅក្រោមសេនាធិការផ្ទាល់រួមមាន កងពលមជ្ឈិម និងកងវរសេនាធំឯករាជ្យ ដែលកងនីមួយៗដឹកនាំដោយមេបញ្ជាការកងពលមួយរូប អមដោយមេបញ្ជាការរងដែលមុខងារទាំងពីរនេះត្រូវបានគេហៅថា លេខានិងអនុលេខាកងពលៗ កងពលមជ្ឈិមត្រូវបានបែងចែកជាអង្គភាពតូចៗបន្តទៀតៗ ជាទូទៅកងពលមួយរួមមានកងវរសេនាធំចំនួនបីៗ កងវរសេនាតូចចំនួនបីបង្កើតបាន

ជាកងវរសេនាធំមួយ។ កងអនុសេនាធំចំនួនបីបង្កើតបានជាកងវរសេនាតូចមួយ។ កងអនុសេនាតូច មានកងទ័ពប្រមាណ ១២នាក់ ។ នៅកម្រិតកងអនុសេនាធំនិងថ្នាក់ខាងលើៗ អង្គភាពនីមួយៗ ត្រូវបានដឹកនាំដោយមេបញ្ជាការម្នាក់ (ដែលត្រូវបានហៅថា «ប្រធាន» ឬ «ស្នងការ») អមដោយមេបញ្ជាការរងពីរនាក់។

**៤៣១.** សាក្សីមួយចំនួនបានលើកឡើងថា នៅចន្លោះកងវរសេនាធំនិងកងពលមានថ្នាក់បញ្ជាការមួយកម្រិតទៀត។ ជាពិសេស សាក្សីបញ្ជាក់ថា បីកងវរសេនាធំបង្កើតបានជា«កងពលតូច» ហើយកងពលនីមួយៗមានកងពលតូចប្រមាណចំនួនបី។ រចនាសម្ព័ន្ធអង្គភាពជាក់លាក់អាចមានលក្ខណៈខុសៗគ្នាទៅតាមកងពលនីមួយៗ ទាក់ទិនកងទ័ពតំបន់ ការសន្និដ្ឋានដោយសមហេតុផលអាចទាញចេញពីសំអាងហេតុដូចគ្នានេះផងដែរ។

**៤៣២.** ទោះបីជាភស្តុតាងមិនបានអនុញ្ញាតឲ្យអង្គជំនុំជម្រះកំណត់បាននូវចំនួនជាក់លាក់កងពលនិងកងវរសេនាធំឯករាជ្យក្តី ប៉ុន្តែភស្តុតាងបានបង្ហាញថា យ៉ាងហោចណាស់មានកងពលមជ្ឈិមចំនួន៩ និងកងវរសេនាធំឯករាជ្យចំនួន ៧ ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់សេនាធិការនៃ ប.ក.ក. ចាប់តាំងពីការបង្កើតកងទ័ពបដិវត្តន៍កម្ពុជា ពោលគឺនៅពាក់កណ្តាលឆ្នាំ ១៩៧៥ រហូតដល់ចុងឆ្នាំ១៩៧៥។ ឯកសារមួយរបស់សេនាធិការ ចុះកាលបរិច្ឆេទនៅខែមីនា ឆ្នាំ១៩៧៧ ដែលបានរៀបរាប់អំពីចំនួនកងទ័ពនៅក្នុងកងពល និងកងវរសេនាធំឯករាជ្យនីមួយៗ បានបង្ហាញថាជាមធ្យមកងពលមជ្ឈិមមានកងទ័ពប្រមាណជា៥.០០០នាក់។ ចំណែកឯកងទ័ពនៅក្នុងកងវរសេនាធំឯករាជ្យមានចំនួនខុសគ្នាៗ ដែលអាចមានចំនួនពីតិចជាង១.០០០នាក់ដល់ច្រើនជាង ៣.០០០នាក់ វាអាស្រ័យទៅលើទំហំនៃកងវរសេនាធំនោះ។

### ៥.៣.២.១.១. កងពល១៦៤ (កងទ័ពជើងទឹក)

**៤៣៣.** កងពលមជ្ឈិម១៦៤ គឺជាកងទ័ពជើងទឹករបស់កងទ័ពបដិវត្តន៍កម្ពុជា ដែលមានទីតាំងស្ថិតនៅតំបន់កំពង់សោម និងធ្វើប្រតិបត្តិការនៅតាមតំបន់ឆ្នេររបស់កម្ពុជា។ កងពល១៦៤ គឺជាកងពលដែលធំជាងគេនៅក្នុងចំណោមកងទ័ពស្រួចរបស់កងទ័ពបដិវត្តន៍កម្ពុជា ព្រោះកងពលនេះមានកងទ័ពចំនួន៨.៥៦៨នាក់នៅក្នុងខែមីនា ឆ្នាំ១៩៧៧។ មេបញ្ជាការកងពល១៦៤ គឺ មាស មុត ដែលជាសមាជិករបស់សេនាធិការផងដែរ។ អនុប្រធានកងពលនេះគឺ ហឹង ឌឿន ហៅ ឌឹម រហូតដល់ពេលដែលគាត់ត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខស-២១ នៅខែមេសា ឆ្នាំ១៩៧៧។

### ៥.៣.១.២.១.២. កងពល១៧០

**៤៣៤.** កងពលមជ្ឈិម១៧០ គឺជាអតីតកងពលរបស់ភូមិភាគបូព៌ា។ កងពលនេះមានទីតាំងស្ថិតនៅតំបន់ភ្នំពេញ។ ចាន់ ចក្រី ហៅ មាន គឺជាមេបញ្ជាការកងពល ១៧០ រហូតដល់ពេលដែលគាត់ត្រូវបានចាប់ខ្លួននៅក្នុងខែឧសភា ឆ្នាំ១៩៧៦។ គាត់ត្រូវបានជំនួសដោយ កែ សុខ ហៅ សមមិត្ត សុខ។ សមមិត្ត គាត គឺជាមេបញ្ជាការរង។ នៅក្នុងខែមីនា ឆ្នាំ១៩៧៧ កងពល១៧០ មានកងទ័ពចំនួនប្រមាណជា៦.០០០នាក់។

### ៥.៣.១.២.១.៣. កងពល២៩០

**៤៣៥.** កងពលមជ្ឈិម ២៩០ ស្ថិតក្រោមការបញ្ជារបស់ សំ ហួយ ហៅ មាស តាល់ ហៅ សមមិត្ត តាល់ រហូតដល់ពេលដែលគាត់ត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ នៅខែ ឧសភា ឆ្នាំ១៩៧៨។ កងពល២៩០ មានកងទ័ពចំនួនប្រមាណ ៥.០០០ នាក់នៅក្នុងខែមីនា ឆ្នាំ១៩៧៧។ កងពល២៩០ បានឈរជើងនៅក្នុងភូមិភាគបូព៌ា (ខេត្តព្រៃវែង) នៅជុំវិញទន្លេមេគង្គ។

**៤៣៦.** កងពលមជ្ឈិម ៣១០ បានឈរជើងនៅភូមិភាគឧត្តរ ។ ស្បូវ ហ៊ី ហៅ អឿន គឺជាលេខាកងពល។ យឹម ឈឿន ហៅ រឿង គឺជាអនុលេខាកងពល។ ពួកគាត់ទាំងពីរត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរសន្តិសុខស-២១ នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៧។ ក្រោយការបោសសម្អាតនៅភូមិភាគឧត្តរ កងពល៣១០ បានប្តូរឈ្មោះ

ទៅជាកងពល២០៧ ទោះបីជាយ៉ាងណាក្តីភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ មិនបានបង្ហាញកាលបរិច្ឆេទជាក់លាក់នៃការប្តូរឈ្មោះកងពលនេះទេ។ យឹម ញ៉ឹ ដែលជាអតីតអនុលេខាកងពល ៣០៧ របស់មជ្ឈិម បានចូលកាន់តំណែងជំនួស អឿន ធ្វើជាលេខាកងពល ៣១០ ( ដែលជាកងពលនេះ នៅក្នុងអំឡុងមួយបានប្តូរឈ្មោះទៅជាកងពល ២០៧) បន្ទាប់ពី អឿន ត្រូវបានគេបោសសម្អាត។ អត្ថិភាពនៃកងពល ៣១០ នៅបន្តមានរហូតដល់ខែមិថុនា ឆ្នាំ១៩៧៧។ ដោយសារមានកងទ័ពចំនួន៦.០៨៤នាក់ កងពលនេះគឺជាកងពលមជ្ឈិមធំពីរបន្ទាប់ពីកងទ័ពជើងទឹក។

## ៥.៣.១.២.១.៥. កងពល៤៥០ ដែលក្រោយមកក្លាយជាកងពល៦០៣

**៤៣៧.** កងពលមជ្ឈិម៤៥០ ក៏មកពីភូមិភាគឧត្តរដែរ។ សមមិត្ត សួង គឺជាលេខាកងពល៤៥០ រហូតដល់ពេលដែលគាត់ត្រូវបានចាប់ខ្លួននិងបញ្ជូនទៅមន្ទីរសន្តិសុខស-២១ នៅដើមឆ្នាំ១៩៧៧។ កងពល៤៥០ បានក្លាយជាកងពល ៦០៣ នៅអំឡុងខែមីនា ឆ្នាំ១៩៧៧ នៅពេលដែលកងពលត្រូវបានផ្លាស់ទីនៅភូមិភាគបូព៌ា។ នៅពេលឈរជើងនៅក្នុងភូមិភាគបូព៌ាកងពល ៦០៣ ស្ថិតក្រោមការបញ្ជារបស់សមមិត្ត វិន។ ទោះបីជាយ៉ាងណានៅចំពោះមុខអង្គជំនុំជម្រះមិនមានភស្តុតាងគ្រប់គ្រាន់ក្នុងការកំណត់ទីតាំងនៃទីបញ្ជាការកងពល ៦០៣ ឲ្យបានច្បាស់លាស់នោះទេ។ កងពល៤៥០ មានអត្ថិភាពនៅក្នុងខែមីនា ឆ្នាំ១៩៧៧ ហើយកងពលនេះមានកងពលចំនួន៥.២៥៩នាក់។

## ៥.៣.១.២.១.៦. កងពល ៥០២ (កងទ័ពអាកាស)

**៤៣៨.** កងពល ៥០២ ជាកងទ័ពអាកាស ដែលដំបូងឡើយគឺជាកងពលមួយរបស់ភូមិភាគនិរតី ស្ថិតក្រោមការគ្រប់គ្រងរបស់តាម៉ុក។ បន្ទាប់មក នៅក្នុងខែកក្កដា ឆ្នាំ១៩៧៥ កងពលនេះបានក្លាយជាកងពលមជ្ឈិម។ មេបញ្ជាការកងពល ៥០២ គឺ ស៊ូ ម៉េត ដែលជាសមាជិកមួយរូបផងដែរនៅក្នុងសេនាធិការ។ កងពល ៥០២ ទទួលខុសត្រូវលើការដ្ឋានសាងសង់ប្រលានយន្តហោះយោធាកំពង់ឆ្នាំង។ នៅក្នុងខែមីនា ឆ្នាំ១៩៧៧ កងពលនេះមានកងទ័ពចំនួន៥.៥៨៣នាក់។

## ៥.៣.១.២.១.៧. កងពល៧០៣

**៤៣៩.** កងពលមជ្ឈិម ៧០៣ ពីមុនមកគឺជាកងពលលេខ ១២ នៃភូមិភាគពិសេសដែលត្រូវបានរំលាយបន្ទាប់ពីការកាន់កាប់ទីក្រុងភ្នំពេញ នៅក្នុងខែមេសា ឆ្នាំ១៩៧៥។ នៅក្នុងខែកក្កដា ឆ្នាំ១៩៧៥ កងពលលេខ ១២ បានក្លាយជាកងពលមជ្ឈិម៧០៣។ អ៊ិន លន ហៅ ណាត គឺជាមេបញ្ជាការកងពល៧០៣ ចាប់ពីពេលដែលកងពលនេះត្រូវបានបង្កើតឡើង រហូតដល់ពេលគាត់ក្លាយជាប្រធានមន្ទីរសន្តិសុខស-២១ ឬនៅពេលដែលគាត់ត្រូវបានផ្ទេរទៅខាងសេនាធិការ នៅក្នុងខែមីនា ឆ្នាំ១៩៧៦។ ទាក់ទងនឹងបញ្ហានេះ ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះមិនមានភាពច្បាស់លាស់នោះឡើយ។ ឌុច បានបញ្ជាក់ថា ណាត មិនមែនជាមេបញ្ជាការកងពល៧០៣ ទៀតនោះទេនៅពេលដែលគាត់បានក្លាយជាប្រធានមន្ទីរសន្តិសុខស-២១។ ប៉ុន្តែនៅក្នុងអំឡុងពេលដែលគាត់កាន់តួនាទីជាប្រធានមន្ទីសន្តិសុខស-២១ មានទូរលេខមួយផ្ញើពី ឌុច ទៅ ណាត ដោយ ឌុច បានហៅគាត់ថា «បង០៣» ។ បើយោងតាម ឌុច វាគឺជាអក្សរកាត់សម្រាប់ហៅកងពល ៧០៣។ អង្គជំនុំជម្រះយល់ឃើញថា ការរៀបចំនេះគួរជឿជាក់បានថា ណាត នៅតែរក្សាប្រើប្រាស់ឈ្មោះ « បង ០៣ » បើទោះបីជាគាត់លែងកាន់តំណែងជាមេបញ្ជាការកងពល ៧០៣ ហើយក៏ដោយ។ ជាចុងក្រោយ ណាត លែងមានតួនាទីជាមេបញ្ជាការកងពល៧០៣ នៅពេលដែលគេបានផ្ទេរគាត់ទៅធ្វើការជាជំនួយការសេនាធិការ នៅក្នុងខែមីនា ឆ្នាំ១៩៧៦។ សមមិត្ត ពីន(ហៅ ខឹម ពីន) នៅភូមិភាគពិសេសគឺជាអ្នកជាអ្នកកាន់តំបន្តពី ណាត ជាមេបញ្ជាការកងពល៧០៣។ មេបញ្ជាការរងកងពលគឺ យឹម ញ៉ឹ រហូតដល់យ៉ាងយោចណាស់ត្រឹមខែកុម្ភៈ ឆ្នាំ១៩៧៧នៅពេលដែល យឹម ញ៉ឹ ទៅកាន់តំណែងជំនួស អឿន ជាលេខាកងពលមជ្ឈិម ៣១០ ។ កងពលនេះឈរជើងនៅបឹងត្របែក នៅក្នុងក្រុងភ្នំពេញ ហើយមានកង

**(តនៅលេខក្រោយ)**

# វេទិកាប្រវត្តិសាស្ត្រគ្រួសារនៅខេត្តត្បូងឃ្មុំ
## សង្ខេបសាច់រឿង

*ឡុង ដានី, សុខ វណ្ណៈ, រី លក្ខិណា និង គាត ស្រីឡែន*

**ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១**

ពេលរសៀល ម៉ោង១ និង៣០ នាទី ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានចុះទៅកាន់ភូមិស្រែតាពិច ឃុំដាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ក្រុមការងារបានជួបជាមួយនឹងមេភូមិស្រែតាពិចឈ្មោះ ឈន ឆាង ភេទប្រុស អាយុ៥២ឆ្នាំ គឺជាជនជាតិស្ទៀង។ បន្ទាប់មកក្រុមការងារបានជួបសម្ភាសន៍ជាមួយក្រុមគ្រួសាររបស់មេភូមិ ដែលមានសមាជិក ៧នាក់ (ប្រុស២នាក់ ស្រី៥នាក់) ក្នុងនោះមានកូនរបស់ ឈន ឆាង ២នាក់ ស្រីម្នាក់ និងប្រុសម្នាក់។ ដោយសារនៅក្នុងរបបខ្មែរក្រហម ឆាង នៅជាកុមារ ទើបគាត់ទៅអញ្ជើញម្ដាយមីងរបស់គាត់មកចូលរួម និងចែករំលែកបទពិសោធន៍ដែលគាត់បានឆ្លងកាត់ជំនាន់ខ្មែរក្រហម។ ម្ដាយមីងរបស់គាត់ឈ្មោះ វ៉ិត ស៊ិន អាយុ៧២ឆ្នាំ គឺជាជនជាតិស្ទៀង។



ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មជួបជាមួយមេភូមិស្រែតាពិចឈ្មោះ ឈន ឆាង (រូបខាងឆ្វេង)។ (គាត ស្រីឡែន/មជ្ឈមណ្ឌលឯកសារកម្ពុជា)



វ៉ិត ស៊ិន អាយុ៧២ឆ្នាំ គឺជាជនជាតិស្ទៀង នៅឃុំដាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (គាត ស្រីឡែន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

**វ៉ិត ស៊ិន** បានរៀបរាប់ថា គាត់មានស្រុកកំណើតនៅភូមិដាំផ្ដិន ក្រោយមកផ្លាស់មករស់នៅភូមិស្រែតាពិច។ ឪពុករបស់គាត់ឈ្មោះ វ៉ិត និងម្ដាយឈ្មោះ ហួយ។ ស៊ិន មិនបានរៀនច្រើនទេ ព្រោះនៅក្នុងភូមិមានត្រឹមតែថ្នាក់ទី៣។ ពីដើមផ្ទះរបស់ស៊ិន ប្រក់ស្លឹកទ្រាំង និងមានផ្ទះប្រហែលជា១០ផ្ទះទេ មិនមានផ្ទះច្រើនដូចបច្ចុប្បន្នទេ។ នៅពេលដែលមានរដ្ឋប្រហារទម្លាក់សម្ដេចសីហនុ ស៊ិន ក៏បានឃើញវត្តមានរបស់ទាហានអាមេរិកចូលមកក្នុងភូមិ និងមានយន្តហោះទម្លាក់គ្រាប់បែក។ ព្រោះតែទាហានអាមេរិកដឹងថាមានកងទ័ពយៀកកុងលាក់ខ្លួននៅក្នុងភូមិ ទើបមានការទម្លាក់គ្រាប់បែកនៅក្នុងភូមិ។ គណៈឃុំដាំតាម៉ៅឈ្មោះតាភូមិ តែគាត់ក៏ត្រូវគេចាប់យកទៅរៀនសូត្រ។ ស៊ិន ត្រូវជម្លៀសទៅស្រុក

សំបូរខេត្តក្រចេះ ពេលដែលខ្មែរក្រហមចោទថាកងទ័ពបូព៌ាក្បត់ ក្រោយមកខ្មែរក្រហមបានជម្លៀសប្រជាជនបន្តរហូតដល់ស្រុកបារាយណ៍ ខេត្តកំពង់ធំ នៅពេលខ្មែរក្រហមជម្លៀស គឺ ស៊ិន កំពុងតែមានផ្ទៃពោះ។ នៅមុនពេលខ្មែរក្រហមជម្លៀសអ្នកភូមិ ខ្មែរក្រហមបាននិយាយប្រាប់ថា វៀតណាមនឹងមកបាញ់សម្លាប់បើមិនជម្លៀស។ នៅពេលខ្មែរក្រហមដួលរលំ ស៊ិន ក៏បានត្រឡប់មកស្រុកកំណើតវិញ ដោយចំណាយរយៈពេល២ខែទើបមកដល់ស្រុកកំណើត។ ភូមិស្រែតាពិច គឺជាភូមិមួយមានផ្ទៃដីធ្វើស្រែច្រើនជាងភូមិដ៏ទៃនៅក្នុងឃុំជាំតាម៉ៅ។ ចំពោះឈ្មោះភូមិស្រែតាពិចវិញ កាលពីដើមមានម្ចាស់ស្រុកម្នាក់ឈ្មោះតាពេជ្រ ដែលគាត់មានដីស្រែនៅទីនេះ បន្ទាប់មកកន្លែងដីស្រែតាពិច បានក្លាយទៅភូមិស្រែតាពិច។ បន្ទាប់ពីពិភាក្សាជាមួយក្រុមគ្រួសារ ពូ ឈន ឆាង រួចក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មក៏ចេញពីភូមិមកកាន់មជ្ឈមណ្ឌលឯកសារកោះថ្ម និងបានបោសសម្អាតបន្ទប់មជ្ឈមណ្ឌល ដើម្បីត្រៀមទទួលឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកមកទស្សនកិច្ចនៅថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០២១។

## ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១

វេលាម៉ោង៩ព្រឹក ក្រុមការងាររបស់មជ្ឈមណ្ឌលកោះថ្មបានធ្វើដំណើរទៅកាន់ភូមិស្រែតាពិច ដើម្បីសម្ភាសន៍ក្រុមគ្រួសាររបស់ជនជាតិស្ទៀង។ ពេលទៅដល់ភូមិ ក្រុមការងារបានរកលោកមេភូមិជួយជូនទៅកាន់ផ្ទះរបស់ក្រុមគ្រួសារ ដែលមានវ័យចំណាស់ និងមានបទពិសោធន៍ឆ្លងកាត់របបខ្មែរក្រហម។





១- ដ្ឋិច គាន់ អាយុ៥៧ឆ្នាំ គឺជាជនជាតិស្ទៀង នៅឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
២- រូបរាប់ពីឆ្វេង៖ ប្តីរបស់ ដ្ឋិច គាន់ ឈ្មោះ ឡុក ង៉ោល, ដ្ឋិច គាន់, កូនស្រីរបស់គាត់ពីរនាក់ និង រី លក្ខិណាក្រុមការងារមជ្ឈមណ្ឌលកោះថ្ម។ អំឡុងពេលឈរឈ្មោះជាតំណាងរាស្ត្រក្នុងរបបសាធារណរដ្ឋខ្មែររបស់ លន់ នល់។
(គាត ស្រីឡែន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅម៉ោង៩ និង១០នាទី ក្រុមការងារបានជួបសម្ភាសន៍ជាមួយក្រុមគ្រួសារអ៊ំស្រីឈ្មោះ ដ្ឋិច គាន់ អាយុ៥៧ឆ្នាំ ជាជនជាតិស្ទៀង និងមានប្តីឈ្មោះ ឡុក ង៉ោល អាយុ៦៨ឆ្នាំ។ ដ្ឋិច គាន់ បានរៀបរាប់ថា ឪពុករបស់ខ្ញុំឈ្មោះ ដ្ឋិច ម្តាយឈ្មោះ យោយ អឹម។ ខ្ញុំមានបងប្អូនចំនួន៥នាក់។ កាលពីក្មេង ខ្ញុំ អត់សូវបានរៀនសូត្រទេ និងតែងតែនិយាយភាសាស្ទៀងជាមួយឪពុកម្តាយ រាល់ការទំនាក់ទំនងជាមួយអ្នកជិតខាងក៏ប្រើភាសាស្ទៀងដែរ។ តែដល់ជំនាន់ខ្មែរក្រហម គឺមេកងហាមមិនឲ្យនិយាយភាសាស្ទៀង បើនិយាយគឺត្រូវយកទៅកសាង។ នៅពេលខ្មែរក្រហមកាន់កាប់អំណាចនៅឆ្នាំ១៩៧៥ ខ្ញុំជាកងកុមារ ត្រូវរៀនពេលព្រឹកដោយថាតាមគ្រូ អត់បានរៀនសរសេរឡើយ។ បន្ទាប់ពីរៀនរយៈពេលប្រមាណ២ម៉ោង ត្រូវសម្រាកហូបបាយ ដោយខ្មែរក្រហមវៃជួងឲ្យកុមារៗហូបបាយមុនចាស់ៗ។ ពេលព្រឹកហូបបបរខាប់ និងពេលល្ងាចហូបបាយ។ នៅពេលរសៀលកុមារត្រូវជួយមើលប្អូនតូចៗ និងពេលខ្លះទៀតត្រូវខ្មែរក្រហមចាត់តាំងឲ្យទៅកាប់ដើមទន្ទ្រានខេត្ត កើបអាចម៍គោដើម្បីធ្វើជាជីដាក់តាមវាលស្រែ។ ឪពុករបស់ខ្ញុំត្រូវខ្មែរក្រហមចាត់តាំងឲ្យទៅលើកប្រឡាយនៅស្រុកទឹកជ្រៅ ចំណែកម្តាយខ្ញុំត្រូវទៅធ្វើចំការរួម។ ក្រោយមកប្រជាជននៅក្នុងភូមិរបស់ខ្ញុំ ក៏ត្រូវខ្មែរក្រហម

ជម្លៀសទៅនៅភូមិស៊ីងត្រី ឃុំដាំក្រវៀន។ ពេលទៅដល់ភូមិស៊ីងត្រីដំបូង ខ្មែរក្រហមអនុញ្ញាតឲ្យដាំបាយហូបនៅតាមផ្ទះ តែត្រូវចិញ្ចឹមសត្វដាក់រួម ក្រោយមកទើបត្រូវបង្ខំឲ្យហូបនៅតាមសហករណ៍។ ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យកាប់ដំបូក។ នៅពេលនោះមេកងឈ្មោះតាជា តែងតែប្រាប់ថា អនាគតយើងសប្បាយហើយ ព្រោះមានអគ្គិសនីភ្លឺទាំងយប់ ទាំងថ្ងៃ ភ្ជួររាស់ប្រើសុទ្ធតាក់ទ័រ លែងប្រើកម្លាំងគោ ក្របីទៀតហើយ។ ពេលដែលមេកងប្រាប់ដូច្នេះ គឺក្នុងចិត្តរបស់ខ្ញុំសប្បាយត្រេកអរណាស់។ ក្រោយមកខ្មែរក្រហមបានជម្លៀសចេញពីឃុំដាំក្រវៀន ទៅកាន់ស្រុកស្នួល ព្រោះតែខ្មាចវៀតណាមចូលមក។ ពេលទៅដល់ភូមិមួយក្នុងស្រុកស្នួល គឺមានមនុស្សស្លាប់ច្រើនណាស់ ទី១ ដោយសារអត់អាហារ ទី២ ដោយសារកើតជំងឺគ្រុនចាញ់។ ឪពុករបស់ខ្ញុំបានស្លាប់ដោយសារជំងឺគ្រុនចាញ់ និងអត់អាហារ។ របបអាហារនៅស្រុកស្នួល ខេត្តក្រចេះមានការខ្វះខាតច្រើន ខ្មែរក្រហមបានចែករបបអាហារពោតស្ងោរមួយកាវសម្រាប់មនុស្សម្នាក់ក្នុងមួយពេល។ បន្ទាប់ពីឪពុកខ្ញុំបានស្លាប់បាត់ ខ្មែរក្រហមបានបន្តជម្លៀសក្រុមគ្រួសារខ្ញុំទៅកាន់ភូមិចង្អប ក្នុងស្រុកសំបូរទៀត។ ការងាររបស់ខ្ញុំនៅតែក្នុងកងកុមារដដែល ដោយខ្ញុំត្រូវសែងអាចម៍គោដាក់ស្រែ បង្គីមួយសែងគ្នាពីរនាក់ និងដើរយកលាមកមនុស្សតាមផ្ទះ ទៅលាយជាមួយនឹងដីដំបូកដើម្បីធ្វើជាជី។ ក្រោយមកខ្មែរក្រហមឲ្យខ្ញុំទៅយាមទំនប់ពេលយប់ បើទំនប់ធ្លាយគឺបិទទំនប់ តែខ្ញុំអត់ហ៊ានដេកនៅទំនប់ទេ ខ្លាចខ្មាសុី លួចរត់មកដេកជាមួយម្តាយនិងបងៗវិញ។ ក្រោយមកខ្មែរក្រហមានជម្លៀសក្រុមគ្រួសារខ្ញុំទៅកាត់ភូមិភាគកណ្តាល ដោយធ្វើដំណើរតាមកាណូតមកកាន់ស្រុកស៊ីងត្រង់ និងបន្តទៅស្រុកបារាយណ៍ ខេត្តកំពង់ធំ។ នៅពេលកងទ័ពវៀតណាម និងកងទ័ពរណសិរ្សរំដោះជាតិកម្ពុជាចូលមកដល់ ក្រុមគ្រួសារខ្ញុំបានធ្វើដំណើរត្រឡប់មកស្រុកកំណើតវិញ។ នៅតាមផ្លូវខ្ញុំ និងបងៗបានដើរបួតស្រូវ បុកនឹងដីយកមកដាំបាយហូប។ ពេលមកដល់ស្រុកកំណើត ខ្ញុំអត់បានចូលមករស់នៅស្រុកកំណើតទេ គឺរស់នៅភូមិស្រែតាពិច ព្រោះមានដីសម្រាប់ធ្វើស្រែស្រាប់ ហើយក៏បានបន្តរស់នៅភូមិស្រែតាពិចរហូតដល់សព្វថ្ងៃ។

---

ម៉ោង១០ និង៤៥នាទី ក្រុមការងារបានជួបជាមួយនឹងក្រុមគ្រួសាររបស់អ៊ំស្រី លិ ស៊ុម អាយុ៦៨ឆ្នាំ ជាជនជាតិស្មៀង។ ស៊ុម មានបងប្អូន៣នាក់ ស្រីទាំងបីនាក់។ ស៊ុមមានកូន៦នាក់ ស្រី៣នាក់ ប្រុស៣នាក់ សព្វថ្ងៃនៅសល់តែកូនប្រុសម្នាក់។ អ៊ំស្រី លិ ស៊ុម បានរៀបរាប់ថា ខ្ញុំមានស្រុកកំណើតនៅភូមិដាំផ្តិន ឃុំដាំតាម៉ៅ ស្រុកមេមត់ ខេត្តកំពង់ចាម។ សព្វថ្ងៃរស់នៅភូមិស្រែតាពិច ឃុំដាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ពីដើមផ្ទះរបស់ខ្ញុំបានសង់ឡើងជាខ្ទមតូចប្រក់ស្លឹកទ្រាំង និងប្រកបមុខរបរដាំស្រូវ។ ក្រុមគ្រួសារខ្ញុំដាំស្រូវនៅកន្លែងចំការដដែលរយៈពេល៣ទៅ៤ឆ្នាំ ត្រូវប្តូរទៅដាំកន្លែងផ្សេងពីព្រោះកន្លែងចំការចាស់ផ្តល់ផលមិនល្អ។ កាលពីជំនាន់លន់ នល់ ខ្ញុំធ្លាប់បានឃើញទាហានអាមេរិកកាំងចូល



លិ ស៊ុម អាយុ៦៨ឆ្នាំ គឺជាជនជាតិស្មៀង នៅនៅភូមិស្រែតាពិក ឃុំដាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(គាត ស្រីឡែន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

មកភូមិដែរ តែដោយសារខ្លាចខ្ញុំ និងអ្នកភូមិផ្សេងទៀត បានរត់ចូលទៅពួននៅក្នុងព្រៃ។ ពេលមានទម្លាក់គ្រាប់បែក ខ្ញុំ និងក្រុមគ្រួសារបានចូលក្នុងព្រៃ និងលាក់ខ្លួនក្នុងរណ្ដៅត្រង់សេ គឺមិនហ៊ាននៅក្នុងភូមិឡើយ។ ពេលខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមក៏បានជម្លៀសប្រជាជនពីភ្នំពេញ មករស់នៅភូមិតាអឹម។ ចំណែកក្រុមគ្រួសារខ្ញុំក៏ត្រូវជម្លៀសទៅភូមិតាអឹមដែរ។ ប្រជាជនដែលជម្លៀសមកពីភ្នំពេញបានស្លាប់ច្រើន ពីព្រោះកើតជំងឺគ្រុនចាញ់។ ប្រធានភូមិមានឈ្មោះ ឈុំ។ ការហូបចុកមិនគ្រប់គ្រាន់ទេ ហូបបបរតែមួយវែក និងជួនកាលកន្លះវែកបាយក្នុងមួយពេល។ ចំណែកការងារវិញ គឺខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យស្ទូងស្រូវតាំងពីព្រឹករហូតដល់ល្ងាច និងមានពេលខ្លះត្រូវស្ទូងស្រូវទាំងយប់ទៀត បើសិនជាចំពេលខែភ្លឺ។ ចំណែកប្ដីខ្ញុំត្រូវបានខ្មែរក្រហមបញ្ជូនទៅធ្វើជាកងទ័ព និងបានបាត់ដំណឹងរហូតដល់សព្វថ្ងៃ។ នៅក្នុងភូមិរបស់ខ្ញុំ ខ្មែរក្រហមមិនបានសម្លាប់ប្រជាជនទេ ប៉ុន្តែ ពេលជម្លៀសទៅខេត្តក្រចេះ ទើបមានការសម្លាប់ប្រជាជន។ ក្រោយមកខ្មែរក្រហមជម្លៀសក្រុមគ្រួសារខ្ញុំ និងអ្នកភូមិទៅស្រុកសំបូរ ម្ដាយខ្ញុំបានស្លាប់នៅស្រុកសំបូរ ដោយសារខ្វះអាហារហូបចុក។ នៅស្រុកសំបូរបានមួយវស្សា ខ្មែរក្រហមក៏បន្តជម្លៀសទៅស្រុកតាំងគោក ខេត្តកំពង់ធំទៀត។ ខ្ញុំ និងក្រុមគ្រួសារបានរស់នៅស្រុកតាំងគោកបានមួយរយៈពេល ទើបកងទ័ពវៀតណាមចូលមករំដោះ។ ប្រជាជនទាំងអស់នាំគ្នាត្រឡប់មកស្រុកកំណើតវិញ ខ្ញុំ និងក្រុមគ្រួសារបានធ្វើដំណើរមកវិញដោយថ្មើរជើងខ្លះ និងសុំឡានកងទ័ពវៀតណាមជិះខ្លះ។ ពេលមកដល់ស្រុកកំណើត រដ្ឋអំណាចបានចែករបបដី ១០ម៉ែត្រ គុណនឹង ១០០ម៉ែត្រក្នុងម្នាក់សម្រាប់ធ្វើស្រែចិញ្ចឹមជីវិត។

ពេលសម្រាកហូបបាយថ្ងៃត្រង់រួច ក្រុមការងារក៏បានធ្វើដំណើរមកមជ្ឈមណ្ឌលឯកសារកោះថ្ម ដើម្បីជួបជាមួយនឹងអគ្គរក្សរបស់លោកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក។ បន្ទាប់ពីជួបអគ្គរក្សរួច ក្រុមការងារក៏បានចុះទៅកាន់ភូមិស្រែតាពិច ដើម្បីបន្តការងារទៀត។

វេលាម៉ោង២ និង១៥នាទី ក្រុមការងារបានជួបជាមួយនឹងក្រុមគ្រួសារលោកតា យោយ គឹម ភូមិស្រែតាពិច។ លោកតាមានអាយុ៧៩ឆ្នាំ ជាជនជាតិស្មៀង។ ខ្ញុំមានស្រុកកំណើតនៅភូមិព្រែកកាតែខាងកើត ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម។ សព្វថ្ងៃខ្ញុំរស់នៅភូមិស្រែតាពិច ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ប្រពន្ធខ្ញុំឈ្មោះ ឌី ទី អាយុ៧១ឆ្នាំ។ ខ្ញុំមានកូន៤នាក់ ប្រុសទាំង៤នាក់ ស្លាប់អស់២នាក់ នៅក្នុងរបបខ្មែរក្រហម ដោយសារអត់អាហារ។ ឪពុកខ្ញុំឈ្មោះ យោយ និងម្ដាយឈ្មោះ ភឹម។ ខ្ញុំមានបងប្អូន២នាក់ ស្រីមួយ ប្រុសមួយ។ កាលពីក្មេងៗខ្ញុំរៀនបានត្រឹមថ្នាក់ទី៣ នៅសាលាបឋមសិក្សាកន្ទួត ស្ថិតនៅក្នុងសង្កាត់ជាំតាម៉ៅ។ នៅក្នុងជំនាន់បារាំងចូលមកកាប់ដីដាំកៅស៊ូ ប្រជាជននៅក្នុងភូមិកាតែខាងកើតមិនហ៊ានរស់នៅជិតបារាំង ព្រោះខ្លាចគោ ក្របី ចូលទៅស៊ីកៅស៊ូរបស់បារាំង ធ្វើឲ្យមានការ



យោយ គឹម, ប្រពន្ធ និងចៅៗរបស់គាត់ នៅភូមិស្រែតាពិក ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
(គាត ស្រីឡែន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខូចខាត មិនមានប្រាក់សងបារាំង ក៏ភៀសខ្លួនពីភូមិចូលទៅរស់នៅក្នុងព្រៃ និងមករស់នៅភូមិព្រែកតាពូកដែលមានចម្ងាយឆ្ងាយពីចំការកៅស៊ូរបស់បារាំង។ ពេលខ្ញុំនៅក្មេង ខ្ញុំធ្លាប់បានឃើញជនជាតិបារាំងមកសាលាសង្កាត់



សាលារៀននៅក្នុងភូមិស្រែតាពិក ឃុំដាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (គាត ស្រីឡែន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ដាំតាម៉ៅ ហើយខ្ញុំបានសួរព្រះសង្ឃថាជាជនជាតិអី បានមាឌធំ ប្រមុះធំ? ព្រះសង្ឃបានប្រាប់ខ្ញុំថាជាពួកបារាំង។ ពីជំនាន់មុនជនជាតិស្ទៀងរកស៊ីបោចវល្លិ ដាំស្រូវ និងចាប់សត្វព្រៃធ្វើម្ហូប។ នៅខែប្រាំង ជនជាតិចាមតែងតែយកត្រី ប្រហុកមកដូរជាមួយនឹងស្រូវ។ នៅឆ្នាំ១៩៧០ ខ្ញុំរៀបការបានរយៈពេល៣ខែ ទាហានលន់ នល់ បានចូលមកក្នុងភូមិជ្រើសរើសបុរសៗទៅធ្វើជាទាហានយាមប្រចាំការនៅព្រំដែនកម្ពុជា-វៀតណាម ត្រង់តំបន់ចាន់មូល។ ពេលយាមនៅព្រំដែន ខ្ញុំបានឃើញមានការទម្លាក់គ្រាប់បែក នៅខាងព្រំដែនវៀតណាមត្រង់ទន្លេចាម។ នៅពាក់កណ្ដាលឆ្នាំ១៩៧០ ខ្ញុំត្រឡប់មកភូមិវិញ និងបានឃើញទាហានអាមេរិកកាំងចូលក្នុងភូមិជាមួយទាហានធីវគី។ ពេលដែលមានវត្តមានទាហានអាមេរិក ក៏មានការទម្លាក់គ្រាប់បែកបេ៥២ដែរ។ នៅចំការខ្ញុំរាល់ថ្ងៃនៅសេសសល់រណ្ដៅបេ ៥២ ជាច្រើនរណ្ដៅ។ នៅពេលខ្មែរក្រហមទទួលបានជ័យជម្នះនៅឆ្នាំ១៩៧៥ ក្រុមគ្រួសារខ្ញុំ និងអ្នកភូមិផ្សេងទៀតបានភៀសខ្លួនទៅនៅភូមិភ្នំ ពីព្រោះភូមិរបស់ខ្ញុំកើតមានជំងឺអាសន្នរោគ។ រស់នៅភូមិភ្នំបានបន្តិច ខ្ញុំ និងអ្នកភូមិបានចុះមកនៅភូមិព្រែកតាពូកវិញ ព្រោះនៅលើភូមិភ្នំអត់មានប្រភពទឹកប្រើប្រាស់។ មុនដំបូងខ្មែរក្រហមចាត់តាំងប្រជាជនឲ្យធ្វើក្រុមប្រវាស់ដៃ ដែលមាន ១២ គ្រួសារក្នុងមួយក្រុម ពេលដែលបានផលចែកគ្នាតាមគ្រួសារនីមួយៗ។ ក្រោយមកខ្មែរក្រហមបង្ខំឲ្យដាក់រួម ដែលធ្វើឲ្យខ្ញុំហូបមិនឆ្អែត។ ក្រោយមកខ្មែរក្រហមជម្លៀសខ្ញុំ និងអ្នកភូមិទៅរស់នៅភូមិស៊ឹងត្រី ឃុំដាំក្រវៀន។ ខ្ញុំត្រូវចាត់តាំងឲ្យធ្វើស្រែ ចំណែកប្រពន្ធខ្ញុំបិទភ្លឺស្រែ និងកាស់គល់។ កាលពីជំនាន់ខ្មែរក្រហម ឃុំដាំក្រវៀន ស្ថិតនៅក្នុងស្រុកត្រមូង តំបន់២១។ អេង ជាប្រធានសង្កាត់នៅដាំក្រវៀន។ នៅឆ្នាំ១៩៧៨ ខ្មែរក្រហមបានជម្លៀសខ្ញុំ និងអ្នកភូមិទៅស្រុកស្នួល ខេត្តក្រចេះ។ បន្ទាប់មកបញ្ជូនចេញពីស្នួលទៅថ្មក្រែ និងដឹកតាមកាណូតពីថ្មក្រែទៅស្រុក ស៊ីងត្រង់ ភូមិភាគកណ្ដាលបន្តទៀត។ ខ្ញុំ និងក្រុមគ្រួសារបានរស់នៅក្នុងភូមិស្វាយភ្លើង ស្រុកបារាយណ៍។ ពេលកងទ័ពវៀតណាមចូលមកដល់ ខ្ញុំសប្បាយចិត្តណាស់ ព្រោះបានត្រឡប់មកផ្ទះវិញ និងលែងអត់បាយទៀត ហើយ។ ខ្ញុំ និងក្រុមគ្រួសារបានធ្វើដំណើររយៈពេល១០ថ្ងៃទើបមកដល់ស្រុកកំណើត និងបានផ្លាស់មករស់នៅភូមិស្រែតាពិចរហូតដល់សព្វថ្ងៃ។

ពេលបញ្ចប់ការផ្សាររនៅភូមិស្រែតាពិច ក្រុមការងារបានបន្តដំណើរមកសាលាឃុំដាំតាម៉ៅ ដើម្បីជួបជាមួយលោកមេឃុំ ឈ្មោះ ពៅ ដូរ។ ក្រុមការងារបានណែនាំខ្លួន និងគោលបំណងដែលចុះមកធ្វើការនៅក្នុងឃុំដាំតាម៉ៅ។ លោកមេឃុំបានស្គាល់មជ្ឈមណ្ឌលឯកសារតាំងពីជំនាន់ដែលមជ្ឈមណ្ឌលឯកសារកម្ពុជា បានអញ្ជើញមេឃុំទូទាំងប្រទេសទៅទស្សនកិច្ចនៅសាលាក្ដីខ្មែរក្រហម គុកទួលស្លែង និងបឹងជើងឯក។ ដោយសារលោកមេឃុំស្គាល់មជ្ឈមណ្ឌលតាំងពីយូរមកហើយនោះ គឺគាត់មានភាពរាក់ទាក់ និងសហការយ៉ាងល្អក្នុងការងារជាមួយក្រុមការងារយើង។ ក្រុមការងារក៏បានណាត់ជួបសម្ភាសន៍ជាមួយក្រុមគ្រួសារលោកមេឃុំនៅថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ២០២១។



ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម ជួបជាមួយលោកមេឃុំដាំតាម៉ៅឈ្មោះ ពៅ ដូរ។ (គាត ស្រីឡែន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

## ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០២១

វេលាម៉ោង៩ និង៣០នាទីព្រឹក ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម បានបន្តធ្វើដំណើរទៅកាន់ភូមិស្រែតាពិចដើម្បីសម្ភាសន៍ជនជាតិស្មៀងទៀត។ ក្រុមការងារបានជួបជាមួយលោកតាម្នាក់ដែលអង្គុយនៅរោងខាងមុខផ្ទះ កំពុងស្តាប់វិទ្យុ។ ក្រុមការងារបានអង្គុយសំណេះសំណាលជាមួយនឹងលោកតា និងសួរនាំរកកូនប្រុសចៅរបស់លោកតា។ ក្រុមការងារបានចាប់ផ្តើមសម្ភាសន៍លោកតា ក៏ដូចជាឲ្យលោកតាចែករំលែកបទពិសោធន៍ដែលធ្លាប់បានឆ្លងកាត់ជំនាន់ខ្មែរក្រហមទៅកាន់កូន និងចៅរបស់លោកតា។ ខ្ញុំឈ្មោះ ងោះ សៀន មានអាយុ៧៧ឆ្នាំ។ ខ្ញុំជាជនជាតិស្មៀង។ ស្រុកកំណើតរបស់ខ្ញុំនៅភូមិព្រែកកាតែ ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តកំពង់ចាម។ សព្វថ្ងៃខ្ញុំរស់នៅភូមិស្រែតាពិច ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានបងប្អូន៨នាក់ ស្រី២នាក់ និងប្រុស៦នាក់។ ខ្ញុំមានឪពុកឈ្មោះ ភិ ងោះ និងម្តាយឈ្មោះ ម៉ុន។ ខ្ញុំមានប្រពន្ធឈ្មោះ ឈុំ សារុំ និងមានកូន ៨នាក់ ស្រី៥នាក់ និងប្រុសចំនួន ៣ នាក់។ កូនខ្ញុំស្លាប់អស់ ២នាក់ ម្នាក់ដោយសារអត់បាយ និងម្នាក់ទៀតលាប់ជំងឺគញ្ជ្រិល។ កាលពីក្មេងៗខ្ញុំមិនបានរៀនសូត្រទេ ព្រោះសាលារៀននៅឆ្ងាយពីភូមិរបស់ខ្ញុំ។ ដោយសារអត់ បានទៅរៀន ខ្ញុំនៅផ្ទះជួយធ្វើស្រែចំការ ជាមួយម្តាយឪពុករបស់ខ្ញុំ។ នៅសម័យបារាំង ខ្ញុំមានអាយុប្រហែល៨ឆ្នាំ ខ្ញុំធ្លាប់ឃើញបារាំងចូលមកធ្វើចំការកៅស៊ូនៅខ្ជាយ។ ភូមិខ្ជាយនៅឆ្ងាយពីភូមិរបស់ខ្ញុំ ជាហេតុធ្វើឲ្យមិនប៉ះពាល់ដល់ដីស្រែចំការរបស់ខ្ញុំទេ។ ពេលដែលជនជាតិបារាំងចូលមកភូមិរបស់ខ្ញុំម្តងៗ បារាំងអត់មានបានធ្វើបាបប្រជាជនទេ។ ឆ្នាំ១៩៧០ ជាឆ្នាំដែលកើតមានរដ្ឋប្រហារទម្លាក់ សម្តេច នរោត្តម សីហនុ ខ្ញុំបានផ្លាស់ប្តូរភូមិទៅនៅភូមិជាំផ្តិន។ នៅឆ្នាំ១៩៧២ ខ្ញុំបានរៀបការ។ ឆ្នាំ១៩៧៥ ខ្ញុំបន្តរស់នៅភូមិជាំផ្តិន ទោះបីជាខ្មែរក្រហមចូលទៅកាន់កាប់ភូមិរបស់ខ្ញុំក៏ដោយ។ ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យធ្វើជាប្រធានសហករណ៍។ ការងាររបស់ខ្ញុំ គឺចាំមើលអ្នកណាដែលធ្វើខុស ណែនាំអត់ស្តាប់ នៅតែបន្តធ្វើកំហុសទៀត ខ្ញុំបានរាយការណ៍ទៅឲ្យឈ្លបឃុំ បើឈ្លបឃុំណែនាំនៅតែមិនស្តាប់ទៀត ឈ្លបស្រុកនឹងយកទៅរៀនសូត្រ ហើយមិនដែលឃើញត្រឡប់មកវិញទេ។ ឆ្នាំ១៩៧៧ ខ្ញុំនិងអ្នកភូមិទាំងអស់ត្រូវខ្មែរក្រហមជម្លៀសទៅស្រុកស្នួល។ ខ្ញុំនៅស្រុកស្នួលបានរយៈពេលខ្លីតែមួយសប្តាហ៍ កូនខ្ញុំក៏អត់អាហារស្លាប់នៅនឹងស្រុកស្នួល។ ខ្ញុំក៏ត្រូវជម្លៀសទៅខាងស្ទឹងត្រង់ ដោយជិះកាណូត។ ពេលទៅដល់ស្ទឹងត្រង់ អ្នកភូមិមានសណ្តានចិត្តល្អ បានឲ្យអំពៅខ្ញុំហូប។ នៅពេលដែលវៀតណាមចូល ខ្ញុំក៏ត្រឡប់មកស្រុកកំណើតវិញ។ ពេលមកដល់ស្រុកកំណើត កូនរបស់ខ្ញុំម្នាក់ទៀតបានស្លាប់ ដោយសារលាប់ជំងឺគញ្ជ្រិល។ ពេលមកដល់ស្រុកកំណើត ខ្ញុំក៏ផ្លាស់មករស់នៅភូមិស្រែតាពិច ព្រោះមានដីស្រែ និងមានប្រឡាយទឹកដែលខ្ញុំធ្លាប់លើកកាលពីជំនាន់ប៉ុល ពត។ ទំនប់មានឈ្មោះថា ទំនប់ឈ្នែង។




១- ងោះ សៀន មានអាយុ៧៧ ឆ្នាំ រស់នៅភូមិស្រែតាពិច ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
២- កូនរបស់ ងោះ សៀន នៅក្នុងវេទិកាប្រវត្តិសាស្ត្រគ្រួសារ។
៣- ងោះ សៀន ជាមួយកូន និងចៅៗរបស់គាត់ នៅក្នុងវេទិកាប្រវត្តិសាស្ត្រគ្រួសារ។ (គាត ស្រីឡែន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

## ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១

ខ្ញុំឈ្មោះ រិទ្ធ ស៊ាង អាយុ៧៧ឆ្នាំ ។ ខ្ញុំមានស្រុកកំណើតនៅភូមិព្រែកតាពូក ឃុំដាំតាម៉ៅ ស្រុកមេមត់ ខេត្តកំពង់ចាម។ សព្វថ្ងៃខ្ញុំរស់នៅភូមិស្រែតាពិច ឃុំដាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ឪពុករបស់ខ្ញុំឈ្មោះ រិទ្ធ និងម្តាយឈ្មោះទេព។ ខ្ញុំមានបងប្អូន៤នាក់ ស្រី៣នាក់ និងប្រុសម្នាក់។ កាលពីក្មេងៗខ្ញុំអត់បានរៀន ព្រោះជួយធ្វើស្រែចំការឪពុកម្តាយ។ ក្នុងភូមិខ្ញុំពីដើម មានតែប្រជាជនពី ៣០ ទៅ ៤០ គ្រួសារ។ របរដែលអ្នកភូមិរបស់ខ្ញុំ ក៏ដូចជាឪពុកម្តាយរបស់ខ្ញុំធ្វើគឺ កាប់ដីដាំស្រូវ ដាំសណ្តែក។ ពេលកាប់ឈើដើម្បីធ្វើចំការ គឺធ្វើរយៈពេលបីឆ្នាំ ទើបប្តូរទៅកាប់មួយកន្លែងទៀត។ រយៈពេលមួយឆ្នាំ ទើបខ្ញុំបានទៅផ្សារមេមត់ម្តង ដើម្បីទិញប្រហុក អំបិល និងថ្នាំ។ ពេលឈឺថ្កាត់ម្តងៗ មិនមានពេទ្យដូចបច្ចុប្បន្នទេ គឺប្រើតែឫសឈើ ដូចជាស្តៅ ជាដើម។ កាលពីឆ្នាំ ១៩៧០ ខ្ញុំធ្លាប់បានឃើញកប៉ាល់ហោះរបស់អាមេរិកមកទម្លាក់គ្រាប់បែក នៅជិតៗភូមិរបស់ខ្ញុំ តែអត់មានទម្លាក់មកលើផ្ទះប្រជាជនទេ តែក៏ធ្វើឲ្យខ្ញុំមានអារម្មណ៍ភ័យខ្លាចដែរ ពេលដែលកប៉ាល់ហោះមកម្តងៗ។ បន្ទាប់ពីទាហានអាមេរិកកាំងដកចេញ ខ្ញុំក៏ត្រូវជម្លៀសទៅនៅភូមិដាំផ្តិន ដើម្បីធ្វើស្រែប្រវាស់ដៃរយៈពេល១ឆ្នាំ។ ខ្ញុំរៀបការនៅអាយុ១៩ឆ្នាំ មិនមានធ្វើពិធីធំដុំទេ គ្រាន់តែកាប់ជ្រូក ហូបជុំគ្នា មិនមានមេក្រូទេ តែនៅតែរក្សាលក្ខណៈប្រពៃណីដដែល។ នៅពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះទូទាំងប្រទេស ខ្ញុំបានកូនមួយ។ ខ្មែរក្រហមបានឲ្យខ្ញុំប្រូតស្រូវ ដកស្ទូង។ ចំណែកប្តីរបស់ខ្ញុំ គឺកាប់ចំការ។ ពេលដែលជម្លៀសទៅក្រចេះ និងបន្តទៅស្ទឹង ត្រង់ គឺខ្ញុំជិះកាណូត។ ខ្ញុំចាំបានថា គឺខែប្រូតដែលខ្ញុំទៅដល់ស្រុកចំការលើ។ ទៅដល់ស្រុកចំការលើបានមួយរយៈ កងទ័ពវៀតណាមក៏ទៅរំដោះពួកខ្ញុំ ហើយពួកខ្ញុំក៏ត្រឡប់មកស្រុកកំណើតវិញ តែដោយសារតែភូមិ ចាស់របស់ខ្ញុំ មិនមានលក្ខណៈអំណោយផលដល់ការដាំស្រូវ ខ្ញុំក៏ផ្លាស់មករស់នៅភូមិស្រែតាពិច ដែលមានប្រព័ន្ធភ្លឺស្រែរួចជាស្រេច។ តាមចាស់ៗនិយាយថា ដីស្រែទាំងអស់ជារបស់តាម្នាក់ឈ្មោះ ពិច ទើបគេហៅស្រែតាពិច ជាប់រហូតមកដល់សព្វថ្ងៃ។



រិទ្ធ ស៊ាង អាយុ៧៧ឆ្នាំ រស់នៅភូមិស្រែតាពិច ឃុំដាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (គាត ស្រីឡែន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

## ថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០២១

ខ្ញុំឈ្មោះ ឡុង យំ អាយុ៧២ឆ្នាំ ជាជនជាតិស្ទៀង។ ខ្ញុំមានស្រុកកំណើតនៅភូមិទន្លូង ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម។ ឪពុករបស់ខ្ញុំឈ្មោះ ឡុង និងម្តាយឈ្មោះ ប្រាញ់។ ខ្ញុំមានបងប្អូនស្រី២នាក់។ ប្តីរបស់ខ្ញុំឈ្មោះ ម៉ម។ ស្រុកកំណើតរបស់ខ្ញុំនៅព្រែកតាពូក ឃុំដាំតាម៉ៅ។ ខ្ញុំមានកូន៧នាក់ សព្វថ្ងៃនៅសល់តែកូនស្រីម្នាក់ ស្លាប់អស់៦នាក់។ កាលពីក្មេងៗខ្ញុំរៀនបានតិចតួចណាស់ ព្រោះតែគ្មានសាលារៀន និងត្រូវជួយម្តាយឪពុកធ្វើស្រែចំការ។ ខ្ញុំរៀបការនៅអាយុ ១៥ឆ្នាំ។ ខ្ញុំធ្លាប់ពុតែចំការកៅស៊ូរបស់បារាំង តែអត់ដែលបានឃើញជនជាតិបារាំងទេ ឃើញតែកម្មករដែលជាជនជាតិខ្មែរ ចាម និងយួន។



ឡុង យំ អាយុ៧២ឆ្នាំ គឺជាជនជាតិស្ទៀង រស់នៅភូមិស្រែតាពិច ឃុំដាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (គាត ស្រីឡែន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ទាហានអាមេរិកបានចូលមកក្នុងភូមិរបស់ខ្ញុំដើម្បីស្វែងរកកងទ័ពយៀកកុង តែទាហានអាមេរិកកាំងអត់ដែលធ្វើបាបប្រជាជនទេ ទាល់តែមានរាយការណ៍ថាមានកងទ័ពយៀកកុងចូលមកក្នុងភូមិ ទើបមានយន្តហោះមកទម្លាក់គ្រាប់បែកៗ ការទម្លាក់គ្រាប់របស់យន្តហោះអាមេរិក ធ្លាប់ឆេះផ្ទះប្រជាជនក្នុងភូមិរបស់ខ្ញុំអស់ ២ផ្ទះ តែអត់មានត្រូវប្រជាជនទេៗ ពេលដែលយន្តហោះមកម្ដងៗ ឪពុកម្ដាយខ្ញុំតែងតែឲ្យខ្ញុំពួននៅក្នុងត្រង់សេៗ ពេលឃើញយន្តហោះធ្វើឲ្យខ្ញុំមានអារម្មណ៍ភ័យខ្លាចៗ ក្រោយពេលដែលឃើញមានយន្តហោះមកទម្លាក់គ្រាប់ទៀត ឪពុកម្ដាយរបស់ខ្ញុំក៏ផ្លាស់ទីលំនៅមករស់នៅភូមិដាំដ្តិនៗ ខ្ញុំក៏ចូលធ្វើស្រែប្រវាស់ដៃ ដោយឪពុករបស់ខ្ញុំធ្វើជាប្រធានភូមិៗ ក្រោយមកពេលដែលបាយរួម ខ្ញុំក៏ត្រូវជម្លៀសមករស់នៅភូមិអន្លាំៗ ដោយសារខ្ញុំមានកូននៅតូចៗ ខ្មែរក្រហមអត់មានឲ្យខ្ញុំធ្វើការងារអ្វីទេ នៅផ្ទះមើលកូនៗ ចំណែកប្ដីរបស់ខ្ញុំទៅលើកដី ធ្វើជាអាងនៅបឹងក្រចាប់ៗ នៅភូមិរបស់ខ្ញុំក៏មានប្រជាជន១៧ មេសា ជម្លៀសមកដែរ តែភាគច្រើនស្លាប់ដោយសារគ្រុនចាញ់ និងមិនមានអាហារហូបចុកគ្រប់គ្រាន់ៗ មេភូមិរបស់ខ្ញុំក្នុងជំនាន់ខ្មែរក្រហមឈ្មោះ ជា ប៉ុន្តែ ជា ស្លាប់ពេលដែលជម្លៀសទៅក្រចេះ ដោយសារអត់បាយៗ គណៈឃុំឈ្មោះ តាផូៗ ក្រោយមកក៏មានការជម្លៀសប្រជាជនទាំងអស់ចេញពីភូមិ ឲ្យទៅតំបន់



ចៅៗរបស់ ឡុង យ៉ំៗ (គាត ស្រីឡែន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រចេះ ព្រោះខ្លាចវៀតណាមឃើញចាប់វះពោះញាត់ស្មៅៗ ដោយសារការភ័យខ្លាច ខ្ញុំចេះតែទៅតាមខ្មែរក្រហមៗ ទៅដល់ក្រចេះខ្ញុំនៅក្នុងកងចល័ត ស្ទូងស្រែ និងបិទភ្លឺស្រែៗ ខ្ញុំបានស្លាប់ប្អូនម្នាក់នៅក្រចេះ ដោយសារធ្វើជាយោធារបស់ខ្មែរក្រហមៗ ខ្ញុំរស់នៅក្រចេះបានមួយខែ ក៏ជម្លៀសបន្តមកទៀតដោយជិះកាណូតឆ្លងមកស្ទឹងត្រង់ៗ នៅស្ទឹងត្រង់បានមួយរយៈ កងទ័ពវៀតណាមក៏រំដោះបាន ខ្មែរក្រហមរត់អស់ ទើបខ្ញុំត្រឡប់មកស្រុកកំណើតវិញ ដោយជិះឡានវៀតណាមនិងដើរៗ ខ្ញុំធ្លាប់ប្រាប់រឿងរ៉ាវដល់ចៅៗដែរ តែក្មេងៗមិនជឿ ថាជំនាន់ខ្មែរក្រហម ហូបចុកមិនគ្រប់គ្រាន់ៗ ពេលដែលប្រាប់ចៅ ហើយចៅមិនជឿ ខ្ញុំក៏លែងរំលឹកពីរឿងខ្មែរក្រហមបន្តទៅទៀតៗ

ខ្ញុំឈ្មោះ ហ៊ិន យាន អាយុ៦០ឆ្នាំ ជាជនជាតិស្ទៀងៗ ខ្ញុំមានស្រុកកំណើតនៅភូមិបេងកោង ឃុំទន្ទុង ស្រុកមេមត់ ខេត្តកំពង់ចាមៗ សព្វថ្ងៃខ្ញុំរស់នៅភូមិស្រែតាពិច ឃុំដាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំៗ ឪពុករបស់ខ្ញុំឈ្មោះ ហ៊ិន ស្លាប់នៅរំលេច ខេត្តក្រចេះ ដោយសារអត់បាយៗ ម្ដាយឈ្មោះ ហើង ស្លាប់នៅក្រែក ដោយសារតែឈឺៗ បងប្អូនរបស់ខ្ញុំ៣នាក់ ប្រុស២នាក់ និងស្រីម្នាក់ៗ ប្អូនរបស់ខ្ញុំស្លាប់ដោយសារតែធ្វើជាយោធារបស់ខ្មែរក្រហមៗ សព្វថ្ងៃនៅសល់តែ ២នាក់ ៗ ប្រពន្ធរបស់ខ្ញុំឈ្មោះ ឈុំ ហ៊ុម អាយុ៦១ឆ្នាំៗ ខ្ញុំមានកូន៤នាក់ ស្រី



ហ៊ិន យាន អាយុ៦០ឆ្នាំ គឺជាជនជាតិស្ទៀង រស់នៅភូមិស្រែតាពិច ឃុំដាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំៗ
(គាត ស្រីឡែន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

១នាក់ និងប្រុស៣នាក់ៗ កាលពីក្មេងៗ ខ្ញុំមិនបានរៀនសូត្រទេ ព្រោះតែភូមិរបស់ខ្ញុំគ្មានសាលារៀន ក៏គ្មានវត្តអារាមដែរៗ នៅក្នុងភូមិរបស់ខ្ញុំមានផ្ទះប្រហែលជា ៥០ផ្ទះ ដែលសង់ពីឫស្សីៗ មេព្រៃមិនឲ្យកាប់ឈើធំៗទេ ចង់កាប់ឈើធ្វើផ្ទះទាល់តែសុំច្បាប់អនុញ្ញាតៗ ខ្ញុំធ្លាប់ឃើញទាហានអាមេរិកកាំងចូលមកក្នុងភូមិរបស់ខ្ញុំ តែអាមេរិកកាំងអត់មានធ្វើបាបប្រជាជនទេៗ យៀកកុងមានចូលមកក្នុងភូមិរបស់ខ្ញុំដែរ ដោយមកដូរមាន់ជាមួយនឹងអង្រឹងៗ ពេលដែលបាយរួម ខ្ញុំនៅជាកងកុមារ ខ្ញុំអត់ស្គាល់ឈ្មោះប្រធានកងតូច កងធំទេ ៗ ខ្ញុំបានរៀនអក្សរនៅជំនាន់ខ្មែរក្រហមដែរ តែអត់ចេះទេៗ ក្រោយពីសម្រាករៀន ខ្ញុំទៅកើបអាចម៍គោ កាប់ទន្រ្ទានខេត្ត មកធ្វើជាជីៗ ខ្ញុំរៀបការនៅឆ្នាំ១៩៨២ៗ អ៊ំស្រី ហ៊ុម គាត់បានប្រាប់ថា កាលពីពេលដែលជម្លៀសអ្នក ១៧មេសា មកពីភ្នំពេញ មករស់នៅភូមិរបស់ខ្ញុំនៅជាំផ្តិន មានការស្លាប់ច្រើនដោយសារតែអត់បាយ ហើយខ្មែរក្រហមតឹងរ៉ឹងណាស់ចំពោះអ្នក១៧ មេសាៗ មុនដំបូងខ្មែរក្រហមចាត់តាំងខ្ញុំឲ្យធ្វើជាកងចល័ត ក្រោយមកបានឲ្យខ្ញុំទៅធ្វើការនៅរោងចក្រកាត់ដេរ គឺដេរក្រមានៅភូមិថ្មពេជ្រ ស្រុកស្នួលៗ ប្រធានក្រុមរបស់ខ្ញុំឈ្មោះសាអែមៗ ខ្ញុំចាំឈ្មោះគណៈស្រុកឈ្មោះ ស្រេង, គណៈតំបន់ឈ្មោះ សុទ្ធ និងគណៈភូមិភាគឈ្មោះ សោ ភឹមៗ នៅពេលដែលមានការចាប់គណៈៗ នៅក្នុងស្រុកត្រមូង ខ្ញុំក៏ត្រូវខ្មែរក្រហមជម្លៀសទៅខេត្តក្រចេះ ដោយប្រាប់ថា បើរស់នៅស្រុកត្រមូងបន្តទៀតវៀតណាមនឹងចាប់ដាំតែអុងៗ ដោយមើលឃើញសភាពការណ៍មិនស្រួល ពេលដែលខ្មែរក្រហមសួរថា មិត្តនារីធ្វើអីនៅស្រុកត្រមូង? ខ្ញុំឆ្លើយ



ហ៊ិន យាន រួមជាមួយប្រពន្ធ និងចៅរបស់គាត់នៅក្នុងវេទិកាប្រវត្តិសាស្ត្រគ្រួសារៗ (គាត ស្រីខ្លួន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ថា មិនបានធ្វើការងារអ្វីទេ ខ្ញុំឈឺ នៅដេកពេទ្យព-១ (ស្រុកក្រូចឆ្មារ)ៗ ខ្មែរក្រហមមិនជឿទេបានបន្តសំណួរទៀតថា ដេកពេទ្យអី មានសាច់ ហើយមុខឡើងក្រហម? ខ្ញុំឆ្លើយថា ដោយសារត្រូវថ្នាំៗ ខ្មែរក្រហមក៏លែងសួរខ្ញុំតទៅទៀតៗ ប៉ុន្តែអ្នកដែលអត់ព្រមទៅតាមខ្មែរក្រហមជម្លៀសទៅក្រចេះ រត់ត្រឡប់មកស្រុកវិញ ត្រូវខ្មែរក្រហមបាញ់ចោល ដូច្នេះគ្មានអ្នកស្រុកណាហ៊ានរត់ត្រឡប់មកវិញ ឬរត់ចូលព្រៃទេៗ ខ្ញុំជម្លៀសទៅដល់ឃ្សឹម, ស្វាយជ្រះ ក្នុងស្រុកស្នួល ខេត្តក្រចេះៗ ទៅដល់ស្វាយជ្រះ ខ្មែរក្រហមឲ្យពួកខ្ញុំលើកទំនប់ៗ ពេលដែលមានយន្តហោះទម្លាក់គ្រាប់នៅស្ពានគេ និងតាមវាលស្រែ ធ្វើឲ្យប្រជាជនរត់ជ្រួលច្របល់ ទើបត្រូវរបួស និងស្លាប់ៗ ខ្ញុំក៏ត្រូវជម្លៀសបន្តទៀតរហូតដល់ស្រុកស្ទឹងត្រង់ ទើបមានកងទ័ពវៀតណាមទៅទាន់ទើបខ្ញុំត្រឡប់មកស្រុកកំណើតវិញៗ

**ពាក្យស្លោកផ្នែកដឹកនាំធ្វើការងារ**
**«បដិសេធ កម្មាភិបាលអាក្រក់ ដែលមិនព្រមកែប្រែ កំចាត់អាជ្ញានិយម ការិយាល័យនិយម នាម៉ឺននិយម ឱកាសនិយម»**

# របាយការណ៍ និងបទសម្ភាសន៍សង្ខេប ក្នុងវេទិកាប្រវត្តិសាស្ត្រគ្រួសារ

## នៅស្រុកគិរីវង់ ខេត្តតាកែវថ្ងៃទី៨ ដល់ ១១ ខែកុម្ភៈ ឆ្នាំ២០២១

*លី កុកឆាយ, មីន សាណាស់, កែវ សុភី និង ផាត ចាន់សុនិតា*



ផែនទីបង្ហាញ ទីតាំងទំនប់ ប្រឡាយក្នុងរបបខ្មែរក្រហម ពីឆ្នាំ១៩៧៥ ដល់១៩៧៩ ។ (លី កុកឆាយ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

វេទិកាប្រវត្តិសាស្ត្រគ្រួសារ គឺជាកម្មវិធីចុះទៅតាមផ្ទះសួរសុខទុក្ខ និងសម្ភាសន៍អ្នករស់រានមានជីវិតពីសម័យខ្មែរក្រហម។ កម្មវិធីនេះ បង្កើតឡើងក្នុងគោលបំណងផ្តល់ឱកាសដល់ឪពុកម្តាយបានចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួន ដែលធ្លាប់បានឆ្លងកាត់នៅក្នុងសម័យកាលសង្គ្រាមទៅកាន់កូនៗរបស់គាត់ ដើម្បីពង្រីកចំនេះដឹងបន្ថែមទៀតទៅលើមុខវិជ្ជាប្រវត្តិសាស្ត្រនៅតាមសាលា និងពង្រឹងនូវយុត្តិធម៌ ព្រមទាំងការចងចាំសម្រាប់យុវជនជំនាន់ក្រោយ។

ចាប់ពីថ្ងៃទី៨ ដល់ ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២១ ក្រុមការងារការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម ខេត្តតាកែវ បង្កើតឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជាបានទៅជួបជនរងគ្រោះពីរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងឃុំអង្គប្រាសាទ ស្រុកគិរីវង់ ខេត្តតាកែវ ដើម្បីបានសិក្សាអំពីរឿងរ៉ាវដែលគាត់បានជួបប្រទះនៅក្នុងសម័យខ្មែរក្រហម។

ព្រឹកថ្ងៃទី៨ ក្រុមការងារ រួមមានលី កុកឆាយ, មីន សាណាស់, ផាត ចាន់សុនីតា និងកែវ សុភី បាន

ធ្វើដំណើរពីភ្នំពេញ ទៅខេត្តតាកែវ ដើម្បីធ្វើវេទិកាប្រវត្តិសាស្ត្រគ្រួសារ ជាមួយប្រជាពលរដ្ឋជាជនរងគ្រោះនៃរបបខ្មែរក្នុងឃុំអង្គប្រាសាទ និងឃុំរាមអណ្តើក ស្រុកគីរីវង់ ខេត្តតាកែវ។ ស្រុកគីរីវង់ (១០៩) ជាស្រុកមួយក្នុងខេត្តតាកែវ ស្ថិតក្នុងតំបន់១៣ ភូមិភាគនិរតីក្នុងរបបខ្មែរក្រហម។ ស្រុកនេះមានសណ្ឋានដីហ៊ុំព័ទ្ធដោយជួរភ្នំ និងព្រំប្រទល់ជាប់នឹងខេត្ត គិញ បៀន ប្រទេសវៀតណាម។ ក្នុងរបបខ្មែរក្រហម ប្រជាជនក្នុងតំបន់នេះត្រូវបានគេបញ្ជូនទៅជីកទំនប់ប្រឡាយតាមទីតាំងជាច្រើន ហើយទំនប់ប្រឡាយមួយចំនួនត្រូវប្រជាជនប្រើប្រាស់ដើម្បីស្រោចស្រប ដីស្រែដល់សព្វថ្ងៃនេះ។ ខាងក្រោមនេះ គឺជាប្រវត្តិរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលបានរៀបរាប់ទៅកាន់កូនចៅ និងក្រុមការងារនៃមជ្ឈមណ្ឌលឯកសារកម្ពុជានៅតាមផ្ទះរបស់គាត់៖

## ថ្ងៃទី ៩ | ក្រុមការងារបានសម្ភាសន៍ជាមួយ | ម៉ូវ ងីម និង កូនស្រីគាត់ ឌាយ ញ៉ិន



បន្ទាប់មកនៅថ្ងៃរសៀលក្រុមការងារបន្តសម្ភាសន៍ជាមួយអ៊ុំប្រុស ប៉ុម ភន ដោយមានខ្លឹមសារសង្ខេបដូចខាងក្រោម៖

**ឌាយ ញ៉ិន** ភេទស្រី អាយុ៥៣ឆ្នាំ គឺជាអ្នករស់រានមានជីវិតម្នាក់ពីរបបខ្មែរក្រហមបច្ចុប្បន្នរស់នៅភូមិភ្នំលន្ទះ, ឃុំអង្គប្រាសាទ, ស្រុកគីរីវង់, ខេត្តតាកែវ បានរៀបរាប់បន្ថែមពីលើលោកយាយ ម៉ូវ ងីម ដែលត្រូវជាម្តាយរបស់គាត់ថា "នៅព្រលប់ថ្ងៃមួយ ប្រធានកងឈ្មោះ ទីបានមកហៅឪពុករបស់ខ្ញុំទៅប្រជុំកសាង ដោយហេតុផលគាត់សុំច្បាប់ទៅលេងសាច់ញាតិហួសថ្ងៃ។ បន្ទាប់ពីបាត់ដំណឹងគាត់ហើយក៏មានអ្នកជិតខាងម្នាក់បានមកប្រាប់ថា ឪពុករបស់ខ្ញុំជាប់ឃុំឃាំងនៅវត្តព្រះធាតុរហូតដល់ថ្ងៃដែលវៀតណាមចូលមក ទើបខ្មែរក្រហមបានសម្លាប់ឪពុករបស់ខ្ញុំ។ ចាប់តាំងពីពេលនោះមក ខ្ញុំនឹងម្តាយរបស់ខ្ញុំពុំដែលបានជួបមុខឪពុកទៀតទេ។ ខ្ញុំមានការសោកស្តាយជាខ្លាំង នៅពេលដែលប្រទេសជិតត្រូវបានរំដោះទាំងស្រុងទៅហើយ ប៉ុន្តែឪពុករបស់ខ្ញុំមិនមានឱកាសបានរួចរស់ជីវិត។ ក្រោយមក ខ្ញុំបានស្គាល់ឃាតករដែលសម្លាប់ឪពុករបស់ខ្ញុំ ដោយគាត់ជាអ្នករស់នៅក្នុងស្រុកជាមួយខ្ញុំ។ របប ប៉ុល ពត បានដួលរលំ ខ្ញុំនិងបងប្អូនរបស់ខ្ញុំបីនាក់ទៀតបានក្លាយជាក្មេងកំព្រារស់នៅជាមួយម្តាយ។ ម្តាយរបស់ខ្ញុំត្រូវធ្វើការងារស្រែចំការភ្ជួររាស់សព្វគ្រប់បែបយ៉ាងតែម្នាក់ឯង ដើម្បីចិញ្ចឹមកូនៗដែលនៅតូចៗ។



**ប៉ុម ភន** ភេទប្រុស អាយុ ៧២ឆ្នាំ មានស្រុកកំណើតភូមិភ្នំលន្ទះ ឃុំអង្គប្រាសាទ ស្រុកគីរីវង់ ភន មានឪពុកឈ្មោះ ប៉ុម ពិន និង ម្តាយ ឈ្មោះ ហ៊ិន ឈិន និងមានបងប្អូនចំនួន៥នាក់ ប្រុស២ ស្រី៣ ក្នុងនោះស្លាប់បងប្រុសម្នាក់ដែលគាត់បម្រើការជាទាហាន លន់ នល់។ កាលពីកុមារភាព ភន ចូលរៀននៅវត្តទេពប្រណម្យ ពីថ្នាក់កុមារដ្ឋានដល់ថ្នាក់ទី៧ចាស់ ។ ឆ្នាំ១៩៧២ ភូមិភ្នំលន្ទះ ស្ថិតក្រោយការគ្រប់គ្រងកងទាហានរំដោះ។ ឆ្នាំ១៩៧៥ ខ្មែរក្រហមបានគ្រប់គ្រងប្រទេសទាំងមូលភូមិភ្នំលន្ទះ ក៏ត្រូវកងកម្លាំងអាវខ្មៅរៀបចំ បង្កើតទៅជាសហករណ៍ ដើម្បីត្រៀមទទួលប្រជាជន១៧មេសា ដោយមានការប្រមូលទ្រព្យសម្បត្តិប្រជាជនទុកជារបស់រួម ហូបរួម បង្កើតទៅកងចល័ត លើកភ្លឺស្រែ និងជីកប្រឡាយ។ ការរស់នៅគ្មានសិទ្ធិ

សេរីភាព មានការតាមដានពីសំណាក់ឈ្លបភូមិ។ ឆ្នាំ១៩៧៧-១៩៧៨ ភន និងប្រជាពលរដ្ឋក្នុងភូមិត្រូវខ្មែរក្រហមជម្លៀស ឲ្យចេញទៅស្រុក១០៥ រហូតដល់ជ័យជម្នះក្នុងថ្ងៃ៧មករា ឆ្នាំ១៩៧៩ ទើបប្រជាពលរដ្ឋទាំងអស់អាចវិញត្រឡប់មកស្រុកកំណើតវិញ និងកសាងជីវិតសារជាថ្មី។

| ថ្ងៃទី ១០ | ក្រុមការងារបាន សម្ភាសន៍ជាមួយ | នាក់ សុភាព, ម៉ក់ សាវ៉ាន់ និង រាម ស៊ុំ |
|---|---|---|



## ដោយមានខ្លឹមសារសង្ខេបដូចខាងក្រោម៖

**នាក់ សុភាព** មានអាយុ៦៧ឆ្នាំ ស្រុកកំណើតនៅភូមិភ្នំលន្ទះ ឃុំអង្គប្រាសាទ ស្រុកគីរីវង់ ខេត្តតាកែវ បច្ចុប្បន្ននៅភូមិពោធិ៍តាម៉ុក ឃុំអង្គប្រាសាទ ស្រុកគីរីវង់ ខេត្តតាកែវ។ ឪពុកឈ្មោះ នាក់ យន់ មានម្ដាយឈ្មោះភួន អេង មានបងប្អូនចំនួន ៨នាក់ស្រី៤ ប្រុស៤ក្នុងនោះ ស្លាប់២នាក់ដោយកងទ័ពរំដោះយកទៅរៀនសូត្រនៅខេត្តកំពត ។ គាត់បានរៀបការនៅចុងឆ្នាំ១៩៧២ មានប្រពន្ធឈ្មោះ ស៊ុំ ទូច សព្វថ្ងៃអាយុ ៦៨ឆ្នាំ។ មានកូន៨នាក់។ ឆ្នាំ១៩៧២ ចលនាយោធាខ្មែរក្រហមបានចូលកាន់កាប់ភូមិដ្ឋាន រួមបង្កើតជាក្រុមសាមគ្គី។ ឆ្នាំ១៩៧៥ ខ្មែរក្រហមដណ្ដើមបានជ័យជម្នះពីរបប លន់ នល់ ក៏បង្កើតជារោងបាយសហករណ៍ ដើម្បីត្រៀមទទួលប្រជាជនថ្មី។ ខណៈនោះប្រជាជនត្រូវបែងចែកជា៣ប្រភេទ ប្រជាជនត្រៀម ប្រជាជនពេញសិទ្ធ ប្រជាជនថ្មី រាល់របស់របរទាំងអស់ត្រូវប្រមូលចូលសហករណ៍។ សុភាព ត្រូវអង្គការចាត់តាំងឲ្យឡើងត្នោត ដើម្បីធ្វើជាស្ករផ្គត់ផ្គង់ជូនតំបន់។ ឆ្នាំ១៩៧៧ អង្គការចាប់ផ្ដើមជម្លៀសប្រជាជនក្នុងស្រុក១០៩ ទាំងអស់ ទៅរស់នៅក្នុងស្រុក ១០៥ ( ស្រុកកោះអណ្ដែត) ពេលនោះគេឲ្យគាត់ទៅជីកទំនប់ ប្រឡាយ និងមានការតាមដានពីគណៈឃុំជាបន្តបន្ទាប់រហូតដល់ថ្ងៃរំដោះ៧មករា ឆ្នាំ១៩៧៩។



**ម៉ក់ សាវ៉ាន់** ភេទស្រី អាយុ៦៣ឆ្នាំ រស់នៅក្នុងភូមិស្វាយធំ ឃុំអង្គប្រាសាទ ស្រុកគីរីវង់ ខេត្តតាកែវ គាត់បានរៀបរាប់អំពីបទពិសោធន៍របស់គាត់ប្រាប់កូនចៅរបស់គាត់ និងក្រុមការងារនៃមជ្ឈមណ្ឌលឯកសារកម្ពុជាថា៖ "នៅក្នុងរបបខ្មែរក្រហមខ្ញុំធ្វើជាប្រធានកងនារីនៅសហករណ៍ក្នុងភូមិស្វាយធំ។ ជារៀងរាល់សប្ដាហ៍ អង្គការតែងតែបើកអង្គប្រជុំ ដោយខ្ញុំត្រូវឡើងនិយាយប្ដេជ្ញាចិត្តបម្រើអង្គការឲ្យបានល្អ។ នៅឆ្នាំ១៩៧៦ អង្គការបានឲ្យខ្ញុំប្ដេជ្ញាចិត្តជាមួយបុរសម្នាក់ ដែលត្រូវជាប្ដីរបស់ខ្ញុំនាពេលបច្ចុប្បន្ន។ ក្រោយមកទៀត ខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យធ្វើការរែកដីដំបូកធ្វើជីនៅសហករណ៍ស្រុក១០៩។ ស្ថានភាពរស់នៅរបស់ខ្ញុំពេលនោះលំបាកវេទនា ដោយខ្ញុំត្រូវធ្វើការងារលើសកម្លាំង និងហូបចុកមិនគ្រប់គ្រាន់។ ថ្ងៃមួយនៅពេលខ្ញុំ និងអ្នកផ្សេងទៀតកំពុងដកសំណាបកងទ័ពវៀតណាមក៏ចូលមកដល់ ខ្ញុំនិងអ្នកឯទៀតក្នុងភូមិត្រូវកងទាហានខ្មែរក្រហមជម្លៀសឡើងទៅភ្នំដីរមៀល។



***រាម ស៊ុំ*** *ភេទស្រី មានអាយុ ៧៣ឆ្នាំ ទីកន្លែងកំណើតនៅភូមិត្រពាំងឬស្សី ឃុំរាមអណ្តើក ស្រុកគិរីវង់ ខេត្តតាកែវ។ បច្ចុប្បន្ន ស៊ុំ មានទីលំនៅក្នុងភូមិស្វាយធំ ឃុំអង្គប្រាសាទ ស្រុកគិរីវង់ ខេត្តតាកែវ ។ ស៊ុំ មានឪពុកឈ្មោះ រាម សំ និងម្តាយឈ្មោះ ព្រំ សៀង និងមាន បងប្អូនចំនួន៥នាក់ ប្រុស២នាក់ ស្រី៣នាក់។ កាលពីកុមារភាព ស៊ុំ ចូលរៀននៅសាលាបឋមសិក្សាកុសមៈ រួចបន្តចូលទៅអនុវិទ្យាល័យឈូកក្នុងខេត្តកំពតបានត្រឹមថ្នាក់ទី៦។ ឆ្នាំ១៩៦៨ ស៊ុំ បានរៀបការជាមួយ អ៊ុង ទន ដែលមានជាងកាត់ដេរ ព្រមទាំងមានកូនពីរនាក់។ ឆ្នាំ១៩៧០ ទន ដែលត្រូវជាប្តីរបស់ ស៊ុំ បានចូលបម្រើឲ្យទ័ពរបស់ លន់ នល់។ ឆ្នាំ១៩៧២ កងខ្មែររំដោះបានចាប់ ទន យកទៅកសាងរៀនសូត្រ តែតាមការពិតទាហានទាំងនោះយក ទន ទៅសម្លាប់ ដោយសារជាប់ទិន្នាការជាមន្ត្រីសាធារណៈរដ្ឋ។ បន្ទាប់ពីការស្លាប់របស់ ទន ឪពុកម្តាយរបស់ ស៊ុំ សម្រេចចិត្តលួចចេញពីភូមិកំណើតទៅរស់នៅខាងស្រុក ឈូក ខេត្តកំពត។ ក្នុងចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩ ខ្មែរក្រហមរំដោះបានទីក្រុងភ្នំពេញទាំងស្រុង គ្រួសារ ស៊ុំ ក៏ចូលក្នុងនាមប្រជាជនថ្មី ដែលត្រូវទៅ ធ្វើការលើស និងធ្ងន់ធ្ងរជាងប្រជាជនមូលដ្ឋាន។*

## ថ្ងៃទី ១១ | ក្រុមការងារបានសម្ភាសន៍ជាមួយ

## អឹម លាភ និង ប៉ែន ផាន បន្ទាប់មកនៅថ្ងៃរសៀល ក្រុមការងារបន្តសម្ភាសន៍ជាមួយ សូ ម៉ន និងវ៉ាន់ មឿន ៖



***អឹម លាភ*** *ភេទ ប្រុស មានអាយុ៦២ឆ្នាំ រស់នៅភូមិរនាមត្នោត ឃុំអង្គប្រាសាទ ស្រុកគិរីវង្ស ខេត្តតាកែវ។ លាភ មានឪពុកឈ្មោះ អឹម ខាត់ និងម្តាយឈ្មោះ យ៉ែម ម៉ៅ ព្រមទាំងមានបងស្រីម្នាក់។ ក្នុងសម័យសង្គមរាស្ត្រនិយម លាភ បានចូលរៀននៅសាលាក្នុងវត្តទេពប្រណម្យត្រឹមថ្នាក់ទី៩ ក៏ឈានដល់ឆ្នាំ ១៩៧០ មានរដ្ឋប្រហារទម្លាក់សម្តេចឪ ស្ថានភាពក្នុងភូមិមានភាពវឹកវរ ព្រមទាំងសាលាក៏បិទ។ នាពេលនោះប្រជាជនក្នុងភូមិក៏ចាប់ផ្តើមចូលធ្វើជាទាហានរបស់កងទ័ពរំដោះ ដើម្បីប្រយុទ្ធប្រឆាំងនិងរបស់សាធារណៈរដ្ឋ ដែលគ្រប់គ្រង ដោយសេនាប្រមុខ លន់ នល់។ ឆ្នាំ១៩៧២ ដល់ឆ្នាំ១៩៧៥ ឪពុកម្តាយរបស់ លាភ មានការព្រួយបារម្ភណ៍ខ្លាចកងទ័ពខ្មែររំដោះចាប់កូនប្រុសឲ្យចូលបម្រើជាទាហានក៏បញ្ជូនឲ្យបួសជាព្រះសង្ឃក្នុងវត្ត ទេពប្រណម្យ និងមកបន្តការសិក្សានៅទីក្រុងភ្នំពេញ ក្នុងនាមជាព្រះសង្ឃស្នាក់នៅវត្តបទុម។ ថ្ងៃ ១៧ មេសា ឆ្នាំ១៩៧៥ ជាថ្ងៃដែលខ្មែរក្រហមបានវាយយកបានទីក្រុងភ្នំពេញទាំងមូល ព្រមទាំងបង្ខំជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ក្នុងនោះក៏មានព្រះសង្ឃ លាភ មួយអង្គដែរឲ្យចេញមកស្រុកកំណើតខ្លួនវិញ។ ប្រហែលជាមួយខែក្រោយមក ព្រះសង្ឃ លាភ បានមកដល់វត្តស្រុកកំណើតនៅភូមិស្វាយធំ រួចមកគង់ក្នុងវត្តទេពប្រណម្យ បានប្រហែលជាមួយខែ អង្គការចាប់ផ្តើមចាត់តាំងឲ្យព្រះសង្ឃទាំងអស់សឹកដោយប្រើភាសាថា ព្រះសង្ឃ គឺជាឈ្លើងសង្គម។ បន្ទាប់ពីសឹក លាភ ក៏ត្រូវអង្គការចាត់ចូល ទ ជាជំពូកជន ១៧មេសា ខុសគ្នាពីឪពុកម្តាយ លាភ ដែលជាប្រជាជនមូលដ្ឋាន។ មួយវិញទៀត លាភ ត្រូវអង្គការចាត់តាំងឲ្យធ្វើការងារទាំងថ្ងៃទាំងយប់ លើសពីប្រជាជនឯទៀត ដោយគ្មានពេលវេលាបានជួបជុំក្រុមគ្រួសារ។ ឆ្នាំ១៩៧៧ អ្នកដែលមានឈ្មោះ ថា១៧មេសា ទាំងអស់ក្នុងភូមិត្រូវជម្លៀសជាលើកទីពីរ ឲ្យមករស់នៅធ្វើការក្នុងស្រុក ១០៥ (ត្រាំកក់) រហូតដល់ ថ្ងៃ៧មករា ឆ្នាំ១៩៧៩។ ក្រោយមក លាភ បានរៀបការជាមួយប្រពន្ធឈ្មោះ ម៉ួង យ៉ាត រស់នៅភូមិជាមួយគ្នា និងមានកូនចំនួន៦នាក់។*



**ប៉ែន ផាន** ភេទប្រុស អាយុ៧៨ឆ្នាំ រស់នៅក្នុងភូមិភ្វាស ឃុំអង្គប្រាសាទ ស្រុកគិរីវង់ ខេត្តតាកែវ បានរៀបរាប់អំពីបទពិសោធន៍របស់គាត់ប្រាប់កូនចៅរបស់គាត់ និងក្រុមការងារនៃមជ្ឈមណ្ឌលឯកសារកម្ពុជាថា៖ នៅពេលខ្មែរក្រហមកាន់អំណាច ខ្ញុំត្រូវបានឲ្យទៅធ្វើការដឹកប្រឡាយ រែកទំនប់នៅតាមសហករណ៍ ១០៩ ចាប់ពីឆ្នាំ១៩៧៥ ដល់ ១៩៧៩។ នៅថ្ងៃមួយ អ្នកជិតខាងរបស់ខ្ញុំម្នាក់ឈ្មោះ ចឹក ក្របី បាននិយាយថា ខ្ញុំខំរត់គេចពីបដិវត្តន៍នៅប្រទេសចិនមករស់នៅខ្មែរបែរជាត្រូវមកជួបនឹងសង្គមបែបនេះទៀត។



**សូ ម៉ន** ភេទ ប្រុស មានអាយុ៦៦ឆ្នាំ រស់នៅភូមិភ្វាស ឃុំអង្គប្រាសាទ ស្រុកគិរីវង់ ខេត្តតាកែវ។ ម៉ន មានឪពុកឈ្មោះ សូ ទឹម និងម្តាយឈ្មោះ ណៅម អែន។ ម៉ន មានបងប្អូនបង្កើតចំនួន ៤នាក់ ( ប្រុស២ ស្រី២) ។ ១៩៧២ ដល់ឆ្នាំ១៩៧៤ គាត់បានទៅរស់នៅខាងជួរភ្នំដំរីរមៀល ស្រុកឈូក ខេត្តកំពត។ ឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមវាយរំដោះបានទីក្រុងភ្នំពេញ គាត់ក៏ត្រូវវិញមករស់នៅក្នុងភូមិកំណើតវិញ ដោយខណៈនោះ ភូមិត្រូវខ្មែរក្រហមរៀបចំទៅជាសហករណ៍រួចទៅហើយ។ ម៉ន ត្រូវចាត់ចូលក្នុងក្រុមប្រជាជនថ្មី ដែលគ្មានសិទ្ធិពេញលេញដូចអ្នកមូលដ្ឋាន។ ម៉ន ត្រូវអង្គការចាប់បញ្ជូនឲ្យទៅធ្វើការ ដឹកទំនប់ ជីកប្រឡាយនៅតាមការដ្ឋានជុំវិញស្រុក១០៩។ ឆ្នាំ១៩៧៧ ម៉នបានអង្គការចាត់តាំងឲ្យប្តេជ្ញា ជាមួយនារី ម៉ម យឿន ដែលជាប្រជាជនមូលដ្ឋាន រួមទាំងគូរដទៃទៀតចំនួន១០គូរ។ ឆ្នាំ១៩៧៨ ម៉ន និងក្រុមគ្រួសារ ត្រូវបានកងទ័ពជម្លៀសឲ្យចេញទៅរស់នៅស្រុក១០៥ ព្រោះពេលនោះកងទ័ពខ្មែរក្រហមត្រូវធ្វើសង្គ្រាមជាមួយទ័ពវៀតណាម។



**ខាំន់ មឿន** ភេទប្រុស អាយុ៦២ឆ្នាំ រស់នៅភូមិរាមអណ្តើក ឃុំរាមអណ្តើក ស្រុកគិរីវង់ ខេត្តតាកែវ បានរៀបរាប់អំពីខ្សែរជីវិតរបស់គាត់ថា៖

“កាលពីកុមារភាពខ្ញុំបានចូលរៀននៅសាលាសុបិណដល់ថ្នាក់ទី៧ នៅក្នុងសម័យសង្គមរាស្ត្រនិយម។ ក្រោយមក ខ្ញុំបានបួសធ្វើជាព្រះសង្ឃរហូតដល់ឆ្នាំ១៩៧២។ បន្ទាប់ពីសឹកខ្ញុំបានចូលជាមួយចលនាទាហានស្រោចស្រង់របស់ខ្មែរក្រហម ដើម្បីប្រយុទ្ធគ្នាជាមួយកងទ័ព លន់ នល់។ ក្រោយមក នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាច ខ្ញុំត្រូវបានបញ្ជូនឲ្យទៅធ្វើជាយោធាការពារព្រំដែនទឹកនៅកំពង់សោម។ នៅទីនោះខ្ញុំត្រូវទៅរស់នៅលើកោះសេះ និងកោះថ្មី។ ចំពោះរបបអាហារខ្ញុំមានការហូបចុកគ្រប់គ្រាន់ ប៉ុន្តែខ្ញុំត្រូវរស់នៅព្រាត់ប្រាស់ពីគ្រួសារ។ ទិដ្ឋភាពនៅពេលដែលថ្ងៃលិចបានធ្វើឲ្យខ្ញុំមានអារម្មណ៍ថាឯកោយ៉ាំងខ្លាំង។ បន្ទាប់ពីទៅរស់នៅលើកោះសេះបានមួយឆ្នាំអង្គការបានបញ្ជូនខ្ញុំឲ្យមកហាត់រៀនបាញ់កាំភ្លើងសម្រាប់បាញ់យន្តហោះធំនៅអូរបែកក្អម។ មួយឆ្នាំក្រោយមក ខ្ញុំត្រូវបានបញ្ជូនឲ្យទៅការពារនៅកោះខកញ៉ាតី ហើយកងទ័ពវៀតណាមក៏បានចូលមកប្រយុទ្ធគ្នាជាមួយក្រុមកងពល់របស់ខ្ញុំ។ ក្រោយពីប្រយុទ្ធគ្នាបានបន្តិចកងទ័ពខាងខ្មែរក្រហមបាក់ទ័ពរត់ខ្ចាត់ខ្ចាយអស់។ ខ្ញុំ នឹងអ្នកនៅក្នុងកងពលជាមួយគ្នា៤ទៅ៥នាក់បានរត់គេចតាមព្រៃកញ្ចៅទៅដល់ភ្នំឪរ៉ាល់ រហូតដល់ឆ្នាំ១៩៨១ ទើបខ្ញុំត្រឡប់មករស់នៅស្រុកកំណើតវិញ។

«ផេះផង់ធូលី»

# រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

# លី យូស៊ីប និង លី ស្មែល ៖ អ្នកនេសាទ

***គង់ សារីហ្វាស ម្តាយរបស់ពួកគេបាន រៀបរាប់ថា ៖***

កាលពីខ្ញុំនៅក្មេង ខ្ញុំរស់នៅជាមួយបងស្រីរបស់ខ្ញុំនៅទីក្រុងភ្នំពេញ ហើយបានលក់នំនៅពេលទំនេរ។ បុរសម្នាក់តែងតែមកទិញនំរបស់ខ្ញុំជាញឹកញាប់។ ពេលខ្លះគាត់បានទិញនំគ្រប់មុខតែម្តង។ ថ្ងៃមួយ គាត់បានស្នើសុំចាស់ទុំឲ្យចូលមកសុំភ្ជាប់ពាក្យស្ដីដណ្ដឹងខ្ញុំរៀបការ។ អស់រយៈពេល៨ខែ ទើបខ្ញុំយល់ព្រមតាមសំណើសុំរបស់គាត់។ ខ្ញុំមានអាយុ១៣ឆ្នាំ ហើយមិនទាន់ចេះចង់សក់នៅឡើយ។ បន្ទាប់ពីពួកយើងបានភ្ជាប់ពាក្យរួច គាត់បានព្យាយាមជំរុញខ្ញុំឲ្យរៀបការឆាប់តាមដែលអាចធ្វើទៅបាន ប៉ុន្តែខ្ញុំបានប្រាប់ទៅគាត់វិញថា ខ្ញុំមិនទាន់ចង់រៀបការទេ ទាល់តែខ្ញុំរៀនចេះធ្វើម្ហូប។

នៅពេលដែលពួកយើងបានភ្ជាប់ពាក្យរួច គាត់ធ្វើការជាជាងមាស ចំណែកឯខ្ញុំត្បាញហូលនៅផ្ទះរបស់ខ្ញុំ។ គ្រួសាររបស់គាត់មានជីវភាពសមរម្យបង្គួរ ព្រោះពួកគេគឺជាអ្នកជំនួញ។ បន្ទាប់ពីពួកយើងរៀបការរួច ពួកយើងបានរស់នៅផ្ទះជាមួយបងស្រីរបស់ខ្ញុំអស់រយៈពេលមួយឆ្នាំ។ ខ្ញុំឈប់លក់នំ ហើយចាប់ផ្តើមត្បាញសំណាញ់ សម្រាប់បង់ត្រីជំនួសវិញ។ បើទោះបីជាយ៉ាងនេះក្តី ពួកយើងសន្សំបានប្រាក់កម្រៃខ្លះៗ ដោយពួកយើងមានអាហារសម្រាប់ហូបគ្រប់គ្រាន់រាល់ថ្ងៃ។



គង់ សារីហ្វាស និងកូនស្រីទាំងបីនាក់ នៅខេត្តកណ្ដាល ឆ្នាំ១៩៦៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កូនប្រុសរបស់ខ្ញុំ យូស៊ីប និង ស្មាអែល រស់នៅទីក្រុងភ្នំពេញក្នុងអំឡុងដើមទសវត្សរ៍ឆ្នាំ១៩៧០ ពួកគេទាំងពីរនាក់គឺជាអ្នកនេសាទ។ ស្មាអែល មានសក់រួញស្រស់ស្អាត ដោយមិនចាំបាច់សិតសក់។ គាត់សង្ហារជាង យូស៊ីប បងប្រុសរបស់គាត់។ យូស៊ីប មានការភ័យខ្លាចចំពោះសក់រួញ ដូច្នេះគាត់តែងតែសិតវាចុះក្រោមជាច្រើនដងរៀងរាល់ថ្ងៃ។

កូនប្រុសរបស់ខ្ញុំទាំងពីរអ្នកគឺជាអ្នកសិក្សា ហើយជាសិស្សដែលមានភាពឆ្លាតវៃ ជាពិសេស ស្មាអែល។ ពួកគេអាចអាន និងសរសេរអក្សរខ្មែរ, ចាម (ភាសានៃសហគមន៍ចាមនៃប្រទេសកម្ពុជា) អារ៉ាប់ និងម៉ាឡេស៊ី។ ស្មាអែល ក៏បានរៀនវេទមន្តជាមួយគ្រូនៅភ្នំពេញផងដែរ។ គាត់រៀនអំពីរបៀបបំបាំងខ្លួន និងរបៀបបញ្ចៀសគ្រាប់កាំភ្លើងជាដើម។

កូនប្រុសរបស់ខ្ញុំទាំងពីរ ស្មាអែល មិនដែលភ័យខ្លាចនឹងអ្វីទេ មិនថាខ្មោច ឬក៏គ្រាប់កាំភ្លើង នៅពេលដែល យូស៊ីប ភ័យខ្លាចនឹងអ្វីៗគ្រប់យ៉ាង។ ខ្ញុំចងចាំបានយ៉ាងច្បាស់នៅថ្ងៃដែល ស្មាអែល យកសម្លៀកបំពាក់របស់ខ្ញុំមកពាក់

លើខ្លួនៗ គាត់បាននិយាយថា ខ្ញុំចង់ស្លៀកសម្លៀកបំពាក់របស់ម៉ែ ព្រោះខ្ញុំមានអារម្មណ៍ភ័យខ្លាចដែលខ្ញុំអាចនឹងត្រូវព្រាត់ប្រាស់ពីម៉ែៗ ខ្ញុំមានអារម្មណ៍ពិបាកចិត្តចំពោះពាក្យសំដីរបស់កូនប្រុសខ្ញុំៗ វាហាក់ដូចជាប្រផ្នូលដែលបង្ហាញថាថ្ងៃណាមួយកូនប្រុសរបស់ខ្ញុំទាំងពីរ និងខ្ញុំត្រូវព្រាត់ប្រាស់គ្នាៗ

ពួកយើងក៏បានត្រឡប់ទៅភូមិឃ្លាំងស្បែក នៅក្នុងខេត្តកណ្ដាល អំឡុងពេលសម័យ លន់ នល់ៗ នៅក្នុងឆ្នាំ១៩៧៣ ជម្លោះកាន់តែខ្លាំងឡើងនៅទីនេះ ដូច្នេះពួកយើងបានជួលឡានមួយគ្រឿងទៅប្រាំងចំរេះៗ អ្នកភូមិទាំងអស់បានចាកចេញអស់ហើយនៅតែគ្រួសាររបស់ខ្ញុំៗ ប៉ុន្តែ នៅពេលនោះប្តីរបស់ខ្ញុំមានអារម្មណ៍សោកស្តាយដែលត្រូវបាត់បង់ផ្ទះរបស់គាត់ ដូច្នេះគាត់ក៏បានយកកូនរបស់ខ្ញុំទាំងបី រួមមាន យូស៊ីប ស្មាអែល និងកូនស្រីរបស់ខ្ញុំម៉ារី ឲ្យទៅនៅឃ្លាំងស្បែក ដូច្នេះគាត់អាចរកចាប់ត្រីបានៗ គាត់បាននិយាយថាវាមិនមានបញ្ហាចំពោះគាត់ទេពេលធ្វើការនៅប្រាំងចម្រេះៗ

បន្ទាប់មក ខ្ញុំក៏បានទៅឃ្លាំងស្បែក ដូច្នេះខ្ញុំក៏បានស្នើសុំប្តីរបស់ខ្ញុំ និងកូនត្រឡប់មកវិញៗ បើទោះបីជាយ៉ាងណាក៏ដោយ គាត់បាននិយាយថា កូនប្រុសទាំងពីរមិនត្រឡប់មកវិញទេ ប៉ុន្តែខ្ញុំក៏បានសុំយក ម៉ារី ត្រឡប់មកជាមួយខ្ញុំៗ ពួកយើងបានចាកចេញ ហើយមកដល់ប្រាំងចំរេះនៅពេលល្ងាចៗ នៅព្រឹកថ្ងៃបន្ទាប់ ផ្លូវទាំងអស់ត្រូវបានបិទ ហើយខ្ញុំក៏មិនដែលបានឃើញប្តី និងកូនប្រុសទាំងពីររបស់ខ្ញុំទៀតដែរៗ

ម៉ារី និងខ្ញុំ បានត្រឡប់ទៅភ្នំពេញ ហើយស្នាក់នៅជាមួយប្អូនប្រុសរបស់ខ្ញុំដែលជាវរសេនីយ៍ឯកនៅក្នុងជួរកងទ័ពៗ គាត់បានប្រាប់ពួកយើងឲ្យរៀបចំអីវ៉ាន់ ហើយចាកចេញពីទីក្រុង ពីព្រោះស្ថានការណ៍នៅទីក្រុងភ្នំពេញកាន់តែអាក្រក់ៗ មុនពេលចាកចេញ ខ្ញុំចង់ត្រឡប់ទៅឃ្លាំងស្បែកស្វែងរកប្តី និងកូនប្រុសទាំងពីររបស់ខ្ញុំ ប៉ុន្តែ យោធាខ្មែរក្រហមមិនអនុញ្ញាតទេៗ ដូច្នេះប្អូនប្រុស ប្អូនស្រីរបស់ខ្ញុំ និងខ្ញុំ បានចាកចេញពីភ្នំពេញទៅខេត្តតាកែវៗ

នៅក្នុងខេត្តតាកែវ ពួកយើងបានរស់នៅក្នុងភូមិផ្សេងៗក្នុងស្រុកបាទីៗ កន្លែងដែលពួកយើងទៅដល់ ខ្មែរក្រហមមិនអនុញ្ញាតឲ្យពួកយើងរស់នៅជាមួយសហគមន៍ចាមទេ ហើយមានតែពួកយើងតែប៉ុណ្ណោះដែលជាជនជាតិចាមនៅក្នុងភូមិៗ ពួកយើងមានការលំបាកយ៉ាងខ្លាំងទាក់ទងនឹងការហូបចុកដោយសារសាសនារបស់ពួកយើងមិនអនុញ្ញាតឲ្យបរិភោគសាច់ជ្រូកៗ ប្រជាជនខ្លះមានចេតនាមិនល្អដោយព្យាយាមបង្ខំឲ្យយើងហូបសាច់ជ្រូកៗ

នៅក្នុងស្រុកបាទី អង្គការបានបង្ខំខ្ញុំឲ្យរែកដីៗ ខណៈនោះភ្នែកទាំងគូរបស់ខ្ញុំឡើងហើម ហើយស្បែករបស់ខ្ញុំចាប់



លី ម៉ារី (រូបខាងឆ្វេង), គង់ សារីហ្វាស និង កូនស្រីបីនាក់របស់នាង នៅឆ្នាំ១៩៧២ៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





*លី យូស៊ីប ឆ្នាំ១៩៧២ និង លី ស្មាអែល ភ្នំពេញ ឆ្នាំ១៩៧២។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*



*លី ស្មាអែល ភ្នំពេញ ឆ្នាំ១៩៧២។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ផ្ដើមមានព័ណ៌លឿង។ កូនស្រីរបស់ខ្ញុំពិបាកក្នុងការចំណាំខ្ញុំ។ បន្ទាប់មក អង្គការបានបញ្ជូនឲ្យ ម៉ារី ចូលក្នុងកងកុមារ។ ឃើញខ្ញុំឈឺ កូនស្រីរបស់ខ្ញុំក្លាហានទៅប្រាប់ប្រធានកងថា មិនគួរបន្តឲ្យខ្ញុំទៅធ្វើការច្រើនទៀតនោះទេ ដោយលើកហេតុផលថា ខ្ញុំគឺជាស្ត្រីដែលមានវ័យចំណាស់។ ពួកយើងសំណាងណាស់ព្រោះអង្គការបានឲ្យយើងជួសជុលមងបង់ត្រីជំនួសវិញ។ ពួកយើងតែងតែទទួលបានត្រីច្រើនសម្រាប់ហូប ព្រោះអ្នកនេសាទតែងតែលួចត្រីឲ្យយើង។

នៅក្នុងឆ្នាំ១៩៧៨ ពួកយើងសម្រេចចិត្តរត់ទៅឲ្យឆ្ងាយ ព្រោះពួកយើងមិនអាចទ្រាំនឹងភាពអត់ឃ្លានបានយូរជាងនោះទៀតទេ។ ប៉ុន្តែកម្មាភិបាលបានចាប់ពួកយើងបាន ហើយបានបញ្ជូនពួកយើងឲ្យទៅរស់នៅភូមិផ្សេង ជាទីកន្លែងដែលខ្មែរក្រហមចាត់តាំងឲ្យ ម៉ារី ទៅហាលសណ្ដែក។ នាងមិនអាចធ្វើការងារនេះបាន ហើយក៏បានដួលសន្លប់។ ឃើញដូច្នេះ ប្រធានកងបានបញ្ជូននាងទៅដាក់គុករយៈពេលខ្លី ហើយក៏បានដោះលែងនាងវិញ។ ប៉ុន្តែ បន្ទាប់មក ប្រធានភូមិចាស់របស់ពួកយើងបានសរសេរសំបុត្រស្នើសុំឲ្យពួកយើងត្រឡប់ទៅវិញ។ ខ្ញុំបដិសេធមិនត្រឡប់ទៅវិញ ហើយប្រាប់ទៅកម្មាភិបាលនោះថាពួកគេគួរតែសម្លាប់ខ្ញុំចោលទៅ ប្រសើរជាងបញ្ជូនខ្ញុំឲ្យត្រឡប់ទៅវិញ។ គាត់ក៏បានប្រាប់វិញថា អង្គការត្រូវការខ្ញុំត្រឡប់ទៅជួសជុលមងសម្រាប់បង់ត្រី ព្រោះមានតែពួកយើងប៉ុណ្ណោះដែលជាជនជាតិចាមនៅក្នុងភូមិ។

នៅពេលអ្នកភូមិ ដែលជាអ្នកត្រូវបានជម្លៀសក្នុងពេលដំណាលគ្នាជាមួយកូនប្រុសរបស់ខ្ញុំត្រឡប់មកផ្ទះវិញ ពួកគេបានប្រាប់ខ្ញុំថា ពួកគេបានឃើញក្មេងប្រុសពីរនាក់ដែលមានសម្បុរស្បែកស្រដៀងជនជាតិវៀតណាមរួមនឹងស្ត្រីដ៏ស្រស់ស្អាតមួយរូប។ ពួកគេព្យាយាមស្វែងរកម្ដាយរបស់ពួកគេ។ អ្នកភូមិម្នាក់បាននិយាយថា គាត់បានឃើញពួកគេទាំងបីនាក់ត្រូវបានអង្គការនាំយកទៅសម្លាប់។ អ្នកភូមិក៏បានពណ៌នាពីរូបរាងបុគ្គលិកលក្ខណៈរបស់ពួកគេ។ ពួកគេនិយាយថា បុរសម្នាក់មានសក់រួញ ហើយម្នាក់ទៀតមានសក់ត្រង់។ នៅពេលឮដូច្នេះខ្ញុំមានអារម្មណ៍ខូចចិត្តយ៉ាងខ្លាំង ដោយខ្ញុំដឹងថាគឺជាកូនប្រុសរបស់ខ្ញុំ។

បើទោះបីជាប្រជាជនមូលដ្ឋានប្រាប់ខ្ញុំថា ស្មាអែល និង យូស៊ីប ត្រូវបានអង្គការសម្លាប់។ ខ្ញុំនៅតែមានអារម្មណ៍ថា ស្មាអែល ប្រហែលជានៅរស់ ប៉ុន្តែ យូស៊ីប ប្រហែលជាត្រូវស្លាប់ព្រោះមុខរបស់គាត់នៅក្នុងរូបថតមានសភាពស្លេកណាស់។ ខ្ញុំបានទៅរកគ្រូ ទាយពីដោតវាសនារបស់ពួកគេ គ្រូទាយបានប្រាប់ខ្ញុំថា កូនប្រុសរបស់ខ្ញុំទាំងពីរនាក់នៅរស់រានមានជីវិត។ ក្នុងចំណោមពួកគេទាំងពីរមានម្នាក់ពិការជើងមួយចំហៀង ប៉ុន្តែពួកគេនឹងត្រឡប់មកផ្ទះវិញនៅក្នុងខែចែត្រ។ ខ្ញុំបានរង់ចាំពួកគេអស់រយៈពេលជាច្រើនខែនៃខែចែត្ររហូតមកដល់សព្វថ្ងៃ។

**ប៉ាង ពីច័ន្ទ និង ទេនី ខកហ្គៀល**

រូបក្របមុខ៖

កងចល័តនារីកំពុងលើកភ្លឺស្រែនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៥-១៩៧៩ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ ៖

កងចល័តនារីចេញទៅធ្វើការនៅតាមការដ្ឋានការងារក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ១៩៧៥-១៩៧៩ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 255, March 2021 ◆ Funded by USAID

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.